ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 13-Dec-2012, 11:08
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១២**

**ម៉ោង ០៩: ០៣នាទី**

**សវនាការលើកទី១៣៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម យូរ ឧត្តរា

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ាត់

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់

*(Mr. Tarik ABDULHAK)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ(*Mr Jasper PAUW*)

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក គឹម ម៉េងឃី

លោកស្រី ស៊ីន សុវ៉ន

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

លោក អេម៉ានូអែល ហ្សាកូមី

*(Mr.Emanuel JACOMY)*

លោកស្រី អ៊ីសាបែល ឌៀរ៉ង់

*(Ms. Isabelle DURAND)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីនូហ្ស៊ី | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ហ៊ុន ឈុនលី (TCW-247) | ខ្មែរ |
| លោក ខាំ ផាន់ ហៅ ផាន វ៉ាន (TCW-307) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ហ៊ុន ឈុនលី** (TCW-247)

សួរដោយលោក ម៉ែខល កាណាវាស ផ្តើមពី៖ ............................................................ទំព័រ ៤

**ការសួរសំណួរទៅសាក្សី៖ លោក ខាំ ផាន់ ហៅ ផាន វ៉ាន** (TCW-307)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី៖.......................................................................ទំព័រ ៣៣

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្តើមពី៖ ....................................................ទំព័រ ៣៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ។ ដូចអង្គជំនុំជម្រះបានជម្រាបជូនភាគី និងសាធារណជនហើយថា ដំណើរការសវនាការនៅថ្ងៃនេះ គឺបន្តស្តាប់សក្ខីកម្មសាក្សី ហ៊ុន ឈុនលី បញ្ចប់ ហើយនិងស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-307។

លោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ ដោយមូលហេតុសុខភាព។ សាក្សីដែលត្រូវផ្តល់សក្ខីកម្មបន្តថ្ងៃនេះ គឺលោក ហ៊ុន ឈុនលី លោកមានវត្តមាននៅក្នុងសាលសវនាការ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្ទាប់ គឺសាក្សីដែលមានរហស្សនាម TCW-307។ សាក្សីរូបនេះបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់បានដឹង គឺគាត់មិនមានចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូប ឬដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលបានទទួលស្គាល់នោះទេ។ សាក្សីរូបនេះបានធ្វើសម្បថនៅចំពោះមុខរូបលោកតាដំបងដែកកាលពីពេលព្រឹកមិញរួចហើយ។ សាក្សីរូបនេះមានមេធាវីប្រឹក្សាឈ្មោះ លោកមេធាវី ម៉ម រិទ្ធា។ ហើយសាក្សីរូបនេះក៏មានវត្តមាននៅបន្ទប់រង់ចាំផងដែរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយមុននឹងផ្តល់វេទិកាជូនក្រុមមេធាវីការពារក្តីលោក អៀង សារី ក្នុងការមានឱកាសក្នុងការសួរដេញដោលចំពោះសាក្សី លោក ហ៊ុន ឈុនលី អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីមានឱកាសសេចក្តីសម្រេចផ្ទាល់មាត់ទៅលើបញ្ហាមួយពាក់ព័ន្ធជាមួយនឹងសំណើសុំរបស់លោក អៀង សារី អ៎!មេធាវីរបស់លោក អៀង សារី ។

សូមអញ្ជើញលោក ស្រីចៅក្រម ស៊ីលវៀ ខាតរាយច៍!

[០៩:០៥:៥០]

**ចៅក្រម ស៊ីលវៀ ខាតរ៉ាយច៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសាលាដំបូងបានប្រជុំពិភាក្សាទៅលើសំណើរបស់ក្រុមមេធាវីការពារក្តី អៀង សារី ស្នើសុំឱ្យមានសវនាការផ្ទាល់មាត់ដើម្បីលើកឡើងអំពីភាពអាចទទួលយកបាននៃការកំណត់ត្រា ប្រតិ -- កំណត់ត្រាខ្សែអាត់នៃជនជាប់ចោទ ព្រមទាំងគ្រូពេទ្យព្យាបាលរបស់គាត់នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម។ អង្គជំនុំជម្រះយល់ឃើញថា ការបើកសវនាការផ្ទាល់មាត់គឺមិនចាំបាច់ ដោយសារតែខ្លួនបានស្នើសុំនូវសំណើជាលាយលក្ខណ៍អក្សរ ដែលដកស្រង់នូវលិខិតយុត្តិកម្មសមស្របរួចមកហើយ។

អង្គជំនុំជម្រះសាលាដំបូងក៏បានកត់សម្គាល់ផងដែរថា សេចក្តីរបស់អង្គបុរេជំនុំជម្រះថ្ងៃ១១ មិថុនា ឆ្នាំ២០១០ មិនបានផ្តល់នូវការណែនាំទាក់ទងទៅនឹងការអនុវត្តជាក់ស្តែងនៅត្រង់ចំណុចនេះឡើយ។ ហេតុដូច្នេះហើយ អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ថា មេធាវីការពារក្តី អៀង សារី ត្រូវសុំការអនុញ្ញាតដើម្បីបន្តការថតសំឡេង-រូបភាពរបស់ជនជាប់ចោទ ដោយយោងតាមវិធាន៩២ ហើយនិងស្នើសុំឱ្យ -- ហើយស្នើសុំឱ្យមានការបើកសវនាការដោយផ្ទាល់មាត់នោះ គឺត្រូវបដិសេធ។

សូមអរគុណលោកប្រធាន។

[០៩:០៧:១៣]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីចៅក្រម។ ជាបន្តអង្គជំនុំជម្រះសូមប្រគល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី ហ៊ុន ឈុនលី។

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។ សូមជម្រាបសួរអស់លោក លោកស្រីទាំងអស់ នៅក្នុងនិងក្រៅសវនាការ។ មុនពេលដែលខ្ញុំធ្វើការសាកសួរ ខ្ញុំចង់បញ្ជាក់ទៅលើបញ្ហាថតសំឡេង-រូបភាពនេះ គឺការថតសំឡេងដើម្បីឱ្យមានតម្លាភាពនៅលើព្រឹត្តិការណ៍ដែលកើតឡើងនៅបន្ទប់ឃុំខ្លួនខាងក្រោម ទាក់ទងនឹងជនជាប់ចោទ ក៏ដូចជាវេជ្ជបណ្ឌិតព្យាបាល។ នៅពេលដែលយើងធ្វើដំណើរជាលាយលក្ខណ៍អក្សរមួយនោះ គឺថាខាងព្រះរាជអាជ្ញាបានឆ្លើយតប

ហើយយើងបានធ្វើការសម្រេច ២, ៣ឆ្នាំ ក្រោយមក -- ២, ៣ខែ ក្រោយមក (សូមកែតម្រូវ) ២, ៣ សប្តាហ៍ក្រោយមក គឺមានការថតចម្លងបន្ត។ ហេតុដូច្នេះ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចថា ការថតសំឡេង-រូបភាពនោះ មិនអាចទទួលយកបាននោះ គឺថាតុលាការអាចកម្ទេចចោលនូវកាសែតថតសំឡេង-រូបភាពនោះ។ ប៉ុន្តែយើងគួរតែមិនត្រូវបានរារាំងមិនឲ្យធ្វើការថតសំឡេងបែបនេះឡើយ។

[០៩:០៨:៣១]

ដូច្នេះ ខ្ញុំចង់បញ្ជាក់ថា ការកត់ត្រារបស់ខ្ញុំគឺវាច្បាស់លាស់។ ហើយសម្រេចដោយការចេញជាអ៊ីម៉ែលមកពួកយើង ដោយបញ្ជាក់ថាមិនមានឯកសារគិតយុត្តិ ហើយនិងសេចក្តីបែបនេះ នេះ គឺសេចក្តីសម្រេចថ្ងៃនេះ គឺវាអាចប៉ះពាល់ទៅដល់គោលដៅដែលយើងត្រូវអនុវត្តនៅថ្ងៃអនាគត។ ប៉ុន្តែចំពោះការដែលយើងតម្រូវឲ្យយើងធ្វើការស្នើសុំការអនុញ្ញាត យើងសូមបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងថាការថតសំឡេងនិងរូបភាពទាំងអស់នោះ នឹងមិនត្រូវបានចាក់រំលែកទៅដល់សាធារណជនឡើយ។ ហើយយើងនឹងផ្តល់នូវកាស្សែតថតសំឡេង-រូបភាព នៅចុងនៃថ្ងៃនីមួយៗជូនអង្គជំនុំជម្រះសាលាដំបូង។ ដូច្នេះ ខ្ញុំគិតថានេះជាមធ្យោបាយដែលយើងអាចធ្វើបាន គឺការថតសំឡេង ហើយយើងអនុញ្ញាតឲ្យអង្គជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការបំផ្លាញកាស្សែតថតសំឡេង-រូបភាពនោះ ប្រសិនបើយល់ថាចាំបាច់។

ដូច្នេះនេះមិនមែនជាការជំទាស់ ឬក៏ជាអ្វីនោះឡើយ វាគ្រាន់តែជាការលើកឡើងនូវគោលជំហររបស់មេធាវីការពារក្តី ដើម្បីបង្ហាញថាកូនក្តីរបស់យើងមិនមានលទ្ធភាពក្នុងការតាមដានកិច្ចដំណើរការនីតិវិធី។ ដូច្នេះគាត់គឺនឹងមិនអាច នឹងមិនទទួលបាននូវសិទ្ធិ ទទួលបានការជម្រះដោយយុត្តិធម៌នោះឯង។

[០៩:០៩:៥១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមលើកឡើងដោយសង្ខេប។ ទាក់ទងទៅនឹងការស្តាប់សក្ខីកម្ម យើងសូមស្នើថា ចម្លើយតបបឋមចំពោះសំណើរបស់លោកមេធាវីការពារក្តី អៀង សារី កាលពីម្សិលមិញ ឬពេលយប់នោះ គឺថាយើងនឹងមិននិយាយលម្អិតទៅលើបញ្ហាគតិយុត្តិនោះឡើយ។ គឺយើងនិយាយអំពីការសន្ទនាជាមួយនឹងវេជ្ជបណ្ឌិត ក៏ដូចជាការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។ ដោយ

និយាយបែបនេះ គឺថាអង្គជំនុំជម្រះបញ្ជាឲ្យបញ្ឈប់ការថតចម្លង ហើយសំណើបណ្ដោះអាសន្នរបស់ខាងមេធាវី ស្នើសុំឲ្យមានការថតចម្លងហ្នឹង គឺស្ថិតក្នុងឆន្ទានុសិទ្ធិ គឺស្ថិតក្នុងដៃរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេច ក្នុងការបញ្ជូននូវកាស្សែតថតសំឡេង-រូបភាពទៅអង្គជំនុំជម្រះ ហើយអង្គជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការប្រើប្រាស់។ នេះគឺជាអ្វីដែលយើងចង់ស្នើ។

[០៩:១១:១៤]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១១:៥៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានសម្រេចរួចហើយលើបញ្ហានេះ។ អង្គជំនុំជម្រះមិនពិចារណាលើបញ្ហានេះទៀតទេ។ រងចាំរហូតដល់បញ្ហានេះត្រូវបានរៀបចំឡើងដោយភាគីពាក់ព័ន្ធតាមអនុស្សរណៈអង្គជំនុំជម្រះ។ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី ដែលនៅចំពោះមុខនេះ។

[០៩:១២:៣២]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ សូមអរគុណលោក លោកស្រីចៅក្រម ដែលបានឆ្លើយតបចំពោះសំណើរបស់យើងបានភ្លាមៗ។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោក លោកស្រីចៅក្រម អ៎! លោកសាក្សី ខ្ញុំឈ្មោះ ម៉ៃខល កាណាវាស ហើយនិងរួមជាមួយមេធាវី អាង ឧត្ដម ជាមេធាវីការពារក្ដីឲ្យលោក អៀង សារី។ យើងសូមជម្រាបសួរដល់លោកសាក្សីផងដែរ។ ជាដំបូង ខ្ញុំសូមចាប់ផ្ដើមដោយសារសួរអំពីគុណវុឌ្ឍិរបស់លោកវេជ្ជបណ្ឌិត។ ខ្ញុំសូមធ្វើការសាកសួរលោក ថាតើនៅពេលណាដែលលោកបញ្ចប់ការសិក្សាពីសាលាពេទ្យ ហើយតើនៅឆ្នាំណាដែលលោកបានបញ្ចប់ការសិក្សារបស់លោកពីសាកលវិទ្យាល័យវេជ្ជសាស្ត្រសុខាភិបាលនោះ?

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ខ្ញុំបានចេញពីមហាវិទ្យាល័យវេជ្ជសាស្ត្រភ្នំពេញនៅឆ្នាំ១៩៦៧ បន្ទាប់ពីធ្វើកម្មសិក្សា២០ខែ

នៅមន្ទីរពេទ្យកាល់ម៉ែត។ នៅឆ្នាំ១៩៦៧នោះ ខ្ញុំក៏សុំទៅធ្វើការ -- ត្រូវចាត់តាំងឲ្យទៅធ្វើការនៅខេត្តបាត់ដំបង គឺនៅមន្ទីរពេទ្យបាត់ដំបង ពីឆ្នាំ១៩៦៧ ដល់ឆ្នាំ១៩៧៣។ ដល់ពាក់កណ្ដាលឆ្នាំ១៩៧៣ ទើបខ្ញុំត្រូវបានកំណែនចូលធ្វើជាពេទ្យទាហាននៅមន្ទីរពេទ្យយោធា ខេត្តបាត់ដំបង រហូតដល់៧៥។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំចង់សួរលោកមួយដំណាក់កាលម្ដងៗ តើលោកទៅរៀនសាលាពេទ្យហ្នឹងអស់រយៈពេលប៉ុន្មានឆ្នាំ? តើលោកចំណាយពេលប៉ុន្មានដើម្បីបញ្ចប់ការសិក្សាវិជ្ជាពេទ្យរបស់លោក?

[០៩:១៤:៣២]

**ឆ៖** ខ្ញុំចំណាយពេលជាង៧ឆ្នាំ ដើម្បីបញ្ចប់ការសិក្សាជាវេជ្ជបណ្ឌិត។

**ស៖** សូមអរគុណលោក។ តើលោកទទួលបានជំនាញអ្វីដែរ? ថាតើលោកសិក្សានៅសាលាពេទ្យហ្នឹងទទួលបានជំនាញអ្វីដែរ?

**ឆ៖** ខ្ញុំជាគ្រូពេទ្យទូទៅ ហៅថាជាជំនាញទូទៅ។

**ស៖** មូលហេតុដែលខ្ញុំសួរលោកអំពីសំណួរនេះ ព្រោះថា នៅពេលដែលលោកផ្ដល់សក្ខីកម្មលោកបានជម្រាបមកយើងថា ក្នុងនាមជាវេជ្ជបណ្ឌិតពីឆ្នាំ៦៧ ដល់៧៣ នៅមន្ទីរពេទ្យស៊ីវិល បន្ទាប់មកលោកត្រូវបានគេផ្ទេរទៅពេទ្យយោធា ដែលលោកនៅពេលនោះ គឺជា១ លោកបាននិយាយថា លោកជាគ្រូពេទ្យធម្មតាមិនមែនជាវេជ្ជបណ្ឌិតដែលភាសាអង់គ្លេស គេហៅថា "*មេឌិក*" មិនមែន "*ហ្វីស៊ីសៀន*" នោះ។ តើលោកអាចបញ្ជាក់បានទេ ថាតើវាមានមូលហេតុអ្វីដែរ គឺមានបញ្ហានេះកើតឡើង?

**ឆ៖** ខ្ញុំជាវេជ្ជបណ្ឌិតផ្នែកជំងឺទូទៅ។

**ស៖** នៅពេលដែលលោកផ្ដល់សក្ខីកម្មកាលពីសប្ដាហ៍មុនដែលថា លោកជាគ្រូពេទ្យធម្មតាមិនមែនជាវេជ្ជបណ្ឌិតនៅមន្ទីរពេទ្យយោធាពីឆ្នាំ៧៣ ដល់៧៥ នោះ ថាតើលោកនិយាយដោយការភ័ន្តច្រឡំឬមួយក៏មានការភ័ន្តច្រឡំយ៉ាងដូចម្ដេចដែរ?

[០៩:១៦:២៣]

**ឆ៖** ខ្ញុំមិនមានការភ័ន្ត--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកខាងតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថាវីក៖**

ខ្ញុំសូមជំទាស់ទោះបីថា ខ្ញុំមិនត្រូវការជំទាស់ក៏ដោយ។ ខ្ញុំគិតថានេះប្រហែលជាមានការបញ្ហានៅក្នុងការបកប្រែ ដូច្នេះហើយយើងអាចនឹងអានជាភាសាខ្មែរដើម្បីឲ្យយើងយល់ច្បាស់ថា តើគាត់ប្រើប្រាស់ពាក្យជាភាសាខ្មែរយ៉ាងដូចម្ដេចដែរ ដើម្បីកុំឲ្យមានបញ្ហាលើការបកប្រែ? ដូច្នេះនៅពេលដែលយើងមើលទៅលើការនិយាយជាភាសាខ្មែរ ដោយមិនមើលទៅលើការបកប្រែភាសា គឺយើងអាចដឹងច្បាស់ថា តើមានវាបញ្ហាអ្វីកើតឡើងចំពោះការប្រើប្រាស់ពាក្យទាំងអស់នេះ។

[០៩:១៧:០៦]

**លោក ម៉ែខល កាណាវាស៖**

ខ្ញុំសូមថ្លែងអំណរគុណចំពោះសហព្រះរាជអាជ្ញាដែលផ្ដល់នូវការណែនាំ ប៉ុន្តែខ្ញុំចង់ធ្វើការសាកសួរមួយជំហានម្ដងៗ គឺថាសាក្សីអាចសរសេរសៀវភៅបានលម្អិតចាប់តាំងពីឆ្នាំ៦៣ អំ! ៦៥ មកម្ល៉េះ។ ដូច្នេះខ្ញុំគ្រាន់ចង់ឲ្យគាត់បញ្ជាក់អំពីអ្វីដែលគាត់បាននិយាយពីសប្ដាហ៍មុន។ ហើយខ្ញុំចង់សាកសួរគាត់ថាតើការពីសប្ដាហ៍មុនគាត់បាននិយាយឬក៏អត់ថា គាត់គឺជាគ្រូពេទ្យធម្មតានៅក្នុងមន្ទីរពេទ្យយោធា គឺមិនមែនវេជ្ជបណ្ឌិតនោះ។

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ខ្ញុំជាវេជ្ជបណ្ឌិតធ្វើការនៅមន្ទីរពេទ្យស៊ីវិល ក្រោយមកខ្ញុំផ្លាស់ទៅធ្វើការជាវេជ្ជបណ្ឌិតនៅមន្ទីរពេទ្យយោធា គឺក្នុងឋានៈបច្ចេកទេសគឺអត់មានការផ្លាស់ប្ដូរទេ។

[០៩:១៨:០៨]

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំសូមធ្វើការដកស្រង់ គឺថ្ងៃសុក្រទី៧ ខែ១០ គឺនៅទំព័រទី៧ ដូច្នេះខ្ញុំសូមធ្វើការអានជាភាសាអង់គ្លេស ដោយសារខ្ញុំប្រើប្រាស់ភាសាអង់គ្លេស។ ខ្ញុំមិនដឹងថាតើភាសាខ្មែរគេនិយាយយ៉ាងដូចម្ដេចទេ។ គឺបាននិយាយថា "ខ្ញុំក្លាយជាវេជ្ជបណ្ឌិតនៅឆ្នាំ៦៧ ហើយដែលមានការចាត់តាំងពីរដ្ឋាភិបាល ខ្ញុំត្រូវបានគេចាត់តាំងទៅធ្វើការនៅពេទ្យស៊ីវិលនៅខេត្តបាត់ដំបង។ បន្ទាប់មក -- បន្ទាប់ពីខ្ញុំចាកចេញពីនោះមក គឺខ្ញុំបន្តធ្វើការនៅមន្ទីរពេទ្យស៊ីវិលរហូតដល់ឆ្នាំ៧៣ គឺពាក់កណ្ដាលឆ្នាំ៧៣។ ហើយក្រោយមកនៅចុង៧៣ ខ្ញុំត្រូវបានគេស្នើសុំឲ្យចាកចេញចូលទៅមន្ទីរពេទ្យយោធា ធ្វើការគ្រូពេទ្យធម្មតានៅមន្ទីរពេទ្យយោធា"។ គឺផ្នែកបន្ទាប់នេះ គឺមើលមិនដាច់នោះឡើយ "ហើយខ្ញុំនៅទីនោះ

រហូតដល់ឆ្នាំ៧៥ គឺពី៧៣ ដល់៧៥"។ តើលោកចាំទេថា គេសួរសំណួរបែបនេះ ហើយផ្ដើមនៅចម្លើយបែបនេះ? តើលោកសាក្សីចាំដែរឬទេ?

[០៩:១៩:២៨]

**ឆ៖** បាទ ការបកប្រែនេះមានការលម្អៀងៗបន្តិច គឺថាទោះបីខ្ញុំទៅមន្ទីរពេទ្យ ផ្លាស់ទៅមន្ទីរពេទ្យយោធាក៏ដោយខ្ញុំនៅតែជាវេជ្ជបណ្ឌិតដដែល។

**សៈ** សូមអរគុណលោកសាក្សី។ ខ្ញុំគិតថាប្រហែលជាប្រមាណថ្ងៃមុននៅថ្ងៃ០៦ ខែធ្នូ ឆ្នាំ២០១២ លោកបាននិយាយនៅចំណុចប្រហាក់ប្រហែលគ្នានេះ សង្ឃឹមថាលោកអាចជួយយើងបាន គឺនៅទំព័រទី៧៦ ជួរ២១ លោកបាននិយាយប្រាប់ខ្ញុំថា -- លោកនិយាយប្រាប់ថា "ខ្ញុំមិនធ្លាប់ជាគ្រូពេទ្យយោធានោះឡើយ។ ខ្ញុំធ្លាប់ជាវេជ្ជបណ្ឌិតនៅមន្ទីរខេត្តបាត់ដំបង ព្រោះថានៅខេត្តបាត់ដំបង គ្រប់គ្នាស្គាល់ខ្ញុំថាជាវេជ្ជបណ្ឌិតពេទ្យស៊ីវិល ហើយនិងជាគ្រូពេទ្យធម្មតានៅពេទ្យយោធា។ ខ្ញុំធ្វើជាវេជ្ជបណ្ឌិតនៅពេទ្យស៊ីវិលអស់រយៈពេលយ៉ាងយូរមុនពេលដែលគេចាប់តាំងខ្ញុំឲ្យទៅធ្វើជាគ្រូពេទ្យទាហាននៅមន្ទីរពេទ្យយោធា។ ចំពោះខ្ញុំ ខ្ញុំគិតថាវាមានហេតុផលណាស់ក៏ពីរដងដែរ ដែលលោកបានបញ្ជាក់ថា លោកផ្ទេរពីមន្ទីរពេទ្យស៊ីវិលទៅមន្ទីរពេទ្យយោធា គឺផ្ទេរតួនាទីពីវេជ្ជបណ្ឌិតទៅជាគ្រូពេទ្យធម្មតា -- គ្រូពេទ្យមធ្យម"។ គឺថានៅពេលពីរដងនេះ លោកមិននិយាយថាលោកជាវេជ្ជបណ្ឌិតយោធានោះឡើយ លោកនិយាយថាជាគ្រូពេទ្យមធ្យមយោធា។ ដូច្នេះសូមលោកបញ្ជាក់ថា តើលោកជាវេជ្ជបណ្ឌិត ឬក៏ជាគ្រូពេទ្យមធ្យម?

[០៩:២១:២៨]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាឥឡូវនេះជាពេលសមស្របមុននឹងឲ្យសាក្សីនេះបំភ្លឺ គឺថាយើងមើលនៅក្នុងប្រតិចារឹកជាភាសាអង់គ្លេស យើងត្រូវតែច្បាស់លាស់ជាងហ្នឹងបន្តិច។ សូមឲ្យខាងការពារលោក អៀង សារី នេះឲ្យម៉ោង ហើយនិងពាក្យពេចន៍ ដែលប្រើ ហើយចំណុចទី២ ខ្ញុំចង់ឲ្យមានការបំភ្លឺចេញពីភាសាខ្មែរ កុំឲ្យយកយោងទៅលើភាសាអង់គ្លេស ដែលជាភាសាបកប្រែ។ សូមយោងទៅលើភាសាដើម។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ឥឡូវយើងនិយាយអំពីពេលវេលាដែលខ្ញុំដកស្រង់នេះសិន។ នៅថ្ងៃទី០៦ ខែធ្នូ គឺក្រោយម៉ោងៗ ១៤:១៦:៤៩។ គឺខ្ញុំចង់និយាយថា មុនម៉ោង ១៤:២០:២៧ ។ នៅថ្ងៃបន្ទាប់នៅថ្ងៃ០៧ ខែធ្នូ គឺនៅពេលលោកនិយាយជាលើកទី២ថាជាគ្រូពេទ្យមធ្យម ឬក៏ថាជាការបកប្រែថាគ្រូពេទ្យមធ្យមនោះ។ រយៈពេលគឺ ១១:០២:៣០ គឺម៉ោង១១ និង ២នាទី ៣០វិនាទី នៅពេលនោះ គឺលោកនិយាយថា "ជាវេជ្ជបណ្ឌិតនៅពេទ្យស៊ីវិល ហើយនិងជាគ្រូពេទ្យមធ្យមនៅក្នុងមន្ទីរពេទ្យយោធា"។

នេះហើយគឺអ្វីដែលវាមានភាពមន្ទិលសង្ស័យ។ ប្រហែលជាមានការប្រើប្រាស់ខុសគ្នារវាងពេទ្យយោធា និងពេទ្យស៊ីវិល ប៉ុន្តែខ្ញុំត្រូវពឹងផ្អែកទៅលើអ្វីដែលខ្ញុំមាន។

[០៩:២៣:៥៥]

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ខ្ញុំសូមនិយាយឲ្យច្បាស់តែម្តង គឺថាអ្វីដែលបានបកប្រែជាភាសាអង់គ្លេស ដែលលោកអាននោះ គឺជាការបកប្រែមិនត្រឹមត្រូវទេ។ ខ្ញុំបាននិយាយថា "ខ្ញុំជាវេជ្ជបណ្ឌិតនៅមន្ទីរពេទ្យស៊ីវិល ក្រោយមកខ្ញុំធ្វើជាវេជ្ជបណ្ឌិតនៅមន្ទីរពេទ្យយោធា"។ ខ្ញុំអត់ដែលនិយាយពាក្យ "គ្រូពេទ្យមធ្យម" ទេ ទី១។ ទី២ ខ្ញុំនិយាយថា នៅក្រុងបាត់ដំបង គេស្គាល់ខ្ញុំជាពេទ្យស៊ីវិល ជាងពេទ្យយោធា ពីព្រោះខ្ញុំធ្វើការយូរនៅមន្ទីរពេទ្យស៊ីវិល ចំណែកពេទ្យយោធា ខ្ញុំធ្វើការរយៈពេលខ្លី ហើយម្យ៉ាងទៀត ខ្ញុំមិនៗៗទៅពេទ្យយោធាមែន ប៉ុន្តែខ្ញុំមិនដែលពាក់ស័ក្តិផង។ អានេះ ខ្ញុំបាន -- ខ្ញុំគ្រាន់ចង់បន្ថែមអ៊ីចឹង។ គេស្គាល់ខ្ញុំ ជាគ្រូពេទ្យស៊ីវិលជាងគ្រូពេទ្យយោធា។ ចំពោះពាក្យដែលគេនិយាយថា ពាក្យ "គ្រូពេទ្យមធ្យម" ខ្ញុំមិនដែលនិយាយទេ គឺជាការបកប្រែខុសទេ។ បាទសូមបញ្ចប់ប៉ុណ្ណឹងទៅបាទ។

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណ។

[០៩:២៥:២៥]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៦:៤៦]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ម៉ែខល កាណាវាស តើមានសំណួរអ្វីដែលពាក់ព័ន្ធទៅនឹងប្រតិចារឹកដែលជាតិ

ដែរឬទេ? ហើយបើពាក់ព័ន្ធ សូមលោកពឹងផ្អែកលើប្រតិចារឹកជាភាសាខ្មែរជាមូលដ្ឋានដើម្បីរៀបចំក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីដើម្បីបញ្ជាក់បញ្ហាដែលលោកមានបំណងចង់ដឹងនេះ។ វាមិនទំនងទេដោយសារយើងពឹងផ្អែកលើប្រតិចារឹកជាភាសាអង់គ្លេស ហើយយកទៅសួរដេញដោលសាក្សីដែលផ្តល់សក្ខីកម្មជាភាសាខ្មែរ។ នោះវាមានបញ្ហា ហើយប្រសិនបើបញ្ហានេះអាច រួចហើយ មិនមានទំនងជាសំណួរអីទៀតទេ គឺអាចទៅមុខបាន។ ហើយប្រសិនបើនៅមានទេ គប្បីរៀបចំជាប្រតិចារឹកជាភាសាខ្មែរជាមុន ហើយសូមបន្តសំណួរថ្មីជាបន្តបន្ទាប់ទៀតដែលលោកមានបំណងចង់សួរសាក្សីរូបនេះ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ គឺថាពីមុនពេលនេះបន្តិចគឺថា មុនពេលដែលលោកធ្វើការប្រជុំពិភាក្សាសម្រេចនេះដើម្បីនិយាយបញ្ជាក់គឺខ្ញុំឮ ខ្ញុំមិនដឹងថាខ្មែរនិយាយថាម៉េចទេ ប៉ុន្តែខ្ញុំឮការបកប្រែពីអ្នកបកប្រែដែលធ្វើការនៅទីនេះអស់រយៈពេលយូរហើយយើងត្រូវតែពឹងផ្អែក គឺគាត់និយាយថា នៅពេលដែលគាត់ទៅធ្វើការនៅពេទ្យយោធា គឺគាត់ជាវេជ្ជបណ្ឌិតឬក៏ជាគ្រូពេទ្យមធ្យម ខ្ញុំស្តាប់ដោយយកចិត្តទុកដាក់បំផុតដែលអ្នកបកប្រែគាត់និយាយថាជា “*ដុកទ័រ អូហ្វ មេឌិក*” នេះគឺអ្វីដែលខ្ញុំឮ។ ប្រហែលជាគេអាចប្រើប្រាស់ពាក្យផ្លាស់ប្តូរគ្នាបាននៅក្នុងកន្លែងបកប្រែ ឬមួយក៏យ៉ាងម៉េច ប៉ុន្តែតើសាក្សីគាត់និយាយពាក្យថាជា វេជ្ជបណ្ឌិត ឬក៏គ្រូពេទ្យមធ្យមយ៉ាងម៉េចខ្ញុំមិនច្បាស់ទេ ប៉ុន្តែនេះគឺជាការបកប្រែហើយខ្ញុំពឹងផ្អែកទៅលើការបកប្រែនេះឯង។

[០៩:២៩:០២]

**ប្រធានអង្គជំនុំ៖**

មេធាវីជាតិអាចផ្ទៀងផ្ទាត់លើប្រតិចារឹកជាភាសាខ្មែរ ដែលមេធាវីអន្តរជាតិដកស្រង់សួរហ្នឹងបានដែរឬទេ? ដើម្បីជាប្រយោជន៍នៅក្នុងភាពត្រឹមត្រូវនៃការសួរដេញដោលនេះ ក៏ដូចជាយុត្តិធម៌សម្រាប់សាក្សីផងដែរនាពេលនេះ។

**លោក អាង ឧត្តម៖**

សូមទោសលោកប្រធាន យើងខ្ញុំអត់បានត្រៀមជាភាសាខ្មែរ ជាទូទៅយើងពឹងផ្អែកទៅលើ *ខេសមេណេជ្ជឺ* របស់យើងដែលអាចផ្តល់ព័ត៌មាននេះភ្លាមៗមួយរំពេច។ តែជាអកុសល គាត់នៅបន្ទប់រង់ចាំខាងក្រោមឯណោះទៅវិញ។ បើលោកប្រធានអនុញ្ញាតខ្ញុំសូមពេលវេលាបន្តិចដើម្បីចុះទៅជួបគាត់ពីព្រោះខ្ញុំក៏ទាក់ទងនឹង *សេមថាម* ក៏អត់បានដែរ គាត់អត់មានឈ្មោះនៅក្នុងកម្មវិធី *សេមថាម* សោះ។

ខ្ញុំផ្ញើសារទៅគាត់អត់កើត។ សូមអរគុណ។

**លោក ម៉ៃខល កាណាវាស៖**

នេះគឺជាអ្វីដែលយើងបានស្ដាប់ការបកប្រែ ថាជាវេជ្ជបណ្ឌិត ឬក៏គ្រូពេទ្យមធ្យម។ នេះគឺជាអ្វីដែលយើងឮ មិនដឹងថាជាបញ្ហាបកប្រែ ឬក៏អត់នោះទេ។ ប៉ុន្តែខ្ញុំឮបែបនេះ ខ្ញុំមិនចង់ឮអំពីអ្វីដែលកើតឡើងពីម្សិល ឬក៏ពីសប្ដាហ៍មុនទេ ខ្ញុំចង់និយាយពីថ្ងៃនេះ គឺខ្ញុំឮបែបនេះឯង។ ប្រហែលជាអ្នកបកប្រែគាត់ប្រើប្រាស់ពាក្យផ្លាស់ប្ដូរជាមួយគ្នាបាន គឺពាក្យដែលអាចប្ដូរគ្នាបាន ថាវេជ្ជបណ្ឌិត ឬក៏គ្រូពេទ្យមធ្យមនោះ។

[០៩:៣០:៤០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់ ដែលលោកបញ្ជាក់សាជាថ្មីម្ដងទៀតនេះ។ ប៉ុន្តែយើងឃើញថា វាមានបញ្ហានេះ ហើយអាចធ្ងន់ជាងនេះទៅទៀត។ អ៊ីចឹងហើយបានជាយើងរៀបចំនូវការរៀបចំដំណើរការនេះឲ្យប្រព្រឹត្តទៅបានល្អតាំងពីដើមទីទៅ ក្រែងលោវាល្អប្រសើរ ជាជាងលោកអះអាងដោយខ្លួនឯងតែម្នាក់ឯង។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមអនុញ្ញាតបន្ត--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា មានបញ្ហាអីទៅ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ដើម្បីកំណត់ត្រាតុលាការ គឺថាមានការពេញលេញ យើងបានឮច្បាស់ហើយថា សាក្សីបានបញ្ជាក់ហើយម្ដងទៀតៗ គឺថាពីរដង ថាគាត់ជាវេជ្ជបណ្ឌិតនៅមន្ទីរពេទ្យយោធានៅឆ្នាំ១៩៧៣ ដល់៧៥។ ហើយម្នាក់ៗ គេស្គាល់គាត់នៅក្នុងតំបន់នោះជាវេជ្ជបណ្ឌិត។ ហើយគាត់បានធ្វើសក្ខីកម្មពីសប្ដាហ៍មុនបែបនេះនៅក្នុងរបបខ្មែរក្រហម គាត់មិនអាចលាក់អត្តសញ្ញាណរបស់គាត់បានទេ ពីព្រោះគាត់ធ្វើការនៅទីនោះ គេស្គាល់គាត់ច្រើន។

ឥឡូវនេះ ខ្ញុំគិតថាអកុសល គឺថាមេធាវីមិនបានរៀបចំប្រតិចារឹក រៀបចំឲ្យបានត្រឹមត្រូវទេ។

ហើយឥឡូវនេះ យើងមានសាក្សីនៅទីនេះ យើងអាចសួរគាត់បញ្ជាក់ បើថាបើរកប្រតិចារឹកមិនឃើញទេ។ ដូច្នេះហើយ យើងអាចសួរគាត់ឲ្យគាត់បញ្ជាក់ម្តងទៀត ដើម្បីសន្សំពេល។

**លោក ម៉ែខល កាណាវាស៖**

ខ្ញុំនឹងទៅមុខ ហើយយើងចង់ឲ្យច្បាស់ ថាតើថ្ងៃនេះគាត់និយាយថា គាត់វេជ្ជបណ្ឌិត ឬក៏ជាគ្រូពេទ្យមធ្យម តើលោកបាននិយាយអ៊ីចឹងដែរឬទេ។ ហើយបើសិនជាគាត់និយាយបែបនោះ គឺថាសុំតុលាការបង្គាប់ឲ្យក្រុមអ្នកបកប្រែ កុំឲ្យឆ្លើយជំនួសសាក្សី ថាហេតុអីថាគាត់និយាយថា គាត់ជាដុកទ័រ ម៉េចក៏យើងទៅនិយាយថាជាគ្រូពេទ្យមធ្យម ឬក៏វេជ្ជបណ្ឌិតបាទ។

[០៩:៣៣:០០]

*(មានបញ្ហាបច្ចេកទេស)*

[០៩:៣៦:៤២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ ឮទេ?

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** សូមអរគុណ។ ខ្ញុំនឹងចូលទៅដល់ផ្នែកមួយទៀត ហើយនិងត្រឡប់មកបញ្ហានេះម្តងទៀត ពីព្រោះថាយើងមិនទាន់បានបញ្ចប់នៅឡើយ។ ឥឡូវនេះលោកសាក្សីនៅថ្ងៃសុក្រ លោកបានឆ្លើយថា លោកបានសរសេរសៀវភៅនេះទាំងស្រុងផ្អែកលើការចងចាំរបស់លោក តើលោកប្រកាន់សម្តីនេះដែរឬទេ?

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ខ្ញុំប្រកាន់សម្តីដែលខ្ញុំបាននិយាយពីថ្ងៃមុនបាទ គឺខ្ញុំសរសេរនៅ ផ្អែកនៅលើការចងចាំរបស់ខ្ញុំ។

**ស៖** នោះមានន័យថា នៅក្នុងរយៈពេលច្រើនឆ្នាំមកនោះ លោកមិនបានអាន លោកមិនបានពឹងផ្អែកលើឯកសារអ្វីផ្សេងទៀតទេ ពីសៀវភៅដែលលោកបានអានផ្សេងៗនោះ ដើម្បីរៀបចំពីហេតុ-ការណ៍ផ្សេងៗមកសរសេរសៀវភៅរបស់លោក តើហ្នឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ជាការពិតសៀវភៅខ្ញុំ គឺជាសៀវភៅខ្ញុំ ពុំបានចម្លង -- ពុំបានចម្លងពីសៀវភៅនរណាទេបាទ។

**សៈ** តើលោកបានធ្វើការសិក្សាស្រាវជ្រាវ តើលោកបានទៅមជ្ឈមណ្ឌលឯកសារ លោកបានទៅមើលបណ្ណសារអ្វីផ្សេងៗដែរឬទេ ដើម្បីជាមូលដ្ឋាននៃការសរសេរនោះ?

**ឆៈ** ខ្ញុំមិនដែលបានទៅមជ្ឈមណ្ឌលេកសារកម្ពុជាហៅថា ឌី.ស៊ី.ខេម ទេ ប៉ុន្តែនៅពេលដែលខ្ញុំសរសេររួច ខ្ញុំបានយកសៀវភៅខ្ញុំពីរក្បាលទៅប្រគល់ឲ្យមជ្ឈមណ្ឌលឯកសារ ឌី.ស៊ី.ខេម ហ្នឹងប្រាំក្បាលនៅបណ្ណាល័យជាតិ។

[០៩:៣៨:៤៩]

**សៈ** បាទ ឥឡូវនេះតាមដែលខ្ញុំអានសៀវភៅរបស់លោក ខ្ញុំមើលឃើញថាលោកបានអានប្រហែលថា យល់ឲ្យច្បាស់គឺថាលោកអាចចេះភាសាបារាំងផង អង់គ្លេសផង តើអ៊ីចឹងដែរឬទេលោកសាក្សី?

**ឆៈ** បាទ ខ្ញុំចេះភាសាបារាំង ហើយអង់គ្លេសខ្លះបាទ។

**សៈ** ហើយនៅពេលនោះ គឺក្នុងសម័យឆ្នាំ១៩៧៥ ដល់៧៩ លោកក៏បានយល់ លោកអាចអានភាសាអង់គ្លេសយល់បាន តើអ៊ីចឹងដែរឬទេ?

**ឆៈ** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**សៈ** សូមលោកឆ្លើយម្ដងទៀត ហើយយើងស្ដាប់មិនឮដោយសារមីក្រូហ្វូនមិនទាន់បើកបាទ។

**ឆៈ** បាទ ខ្ញុំអាចយល់ អាចអានភាសាបារាំង និងអាចយល់ភាសាអង់គ្លេស។

[០៩:៤០:០២]

**សៈ** លោកបានពិភាក្សាថា លោកពេលមួយនោះ លោកមានសៀវភៅភាសាអង់គ្លេសពីរនៅក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ សៀវភៅមួយនោះគឺជាសៀវភៅរបស់ ថម សយយ័រ ជាអ្នកនិពន្ធ ម៉ាក ថ្វេន របស់អាមេរិកាំង ហើយសៀវភៅមួយទៀតនិយាយថា "ពិភពបន្ទាប់ពីជីវិតទៅ" គឺថាជាអ្នកកាសែតអាមេរិកាំងជាអ្នកសរសេរ ថាតើសៀវភៅទាំងពីរនេះ លោកអានជាភាសាខ្មែរ-អង់គ្លេសឬក៏ជាភាសាបារាំងដែលលោកថាមាននោះ?

**ឆៈ** តាមពិតមិនមែនសៀវភៅពីរទេ ដែលខ្ញុំអានជំនាន់ខ្ញុំធ្វើការនៅ -- ដែលខ្ញុំអាន លួចអានហៅថាលួចអាន អានដោយស្ងាត់ៗនៅចន្លោះ៧៥ និង៧៩ គឺសៀវភៅចំនួនបី។ សៀវភៅមួយជាភាសាបារាំង ឈ្មោះថា "*លីស្ទ័រ ដឺ ឡា រុស្ស៊ី*" គឺប្រវត្តិនៃប្រទេសរុស្ស៊ី។ សៀវភៅទី២ គឺឈ្មោះអង់គ្លេសថា "*ដឺវើល អូហ្វ ឌី អាហ្វទ័រឡៃហ្វ៍*" បានជាពាក្យខ្មែរថា "បរិលោក"។ ចំពោះសៀវភៅ ថម សយយ័រ ចុង

ក្រោយ -- ខ្ញុំអានចុងក្រោយគេទេបាទ ពេលខ្ញុំមក ពេលផ្លាស់មកធ្វើការនៅមន្ទីរ ពេទ្យស៊ីវិល។

**ស៖** បាទ ខ្ញុំចង់ឲ្យប្រាកដថាលោកអាចអាន ហើយនិងយល់បានភាសាបារាំង និងអង់គ្លេសនោះ។ ឥឡូវនេះ លោកបានឆ្លើយនៅថ្ងៃសុក្រថា "បន្ទាប់ពីឆ្នាំ១៩៧៩ រហូតមកដល់ពេលមួយដែលលោកបានសរសេរសៀវភៅរបស់លោក គឺអាចឆ្នាំ២០០៤ ឬក៏ក្រោយឆ្នាំ២០០៤ ហ្នឹង។ លោកបានអានសៀវភៅជាច្រើនអំពីរបបកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហម ហើយតាមពិតលោកបានប្រាប់យើងផងដែរនៅក្នុងតុលាការនេះ។ តើលោកនៅចាំទេថាលោកបានឆ្លើយបែបនេះ?

**ឆ៖** ខ្ញុំបាន ខ្ញុំនៅចាំប៉ុន្តែខ្ញុំបាន -- មិនបាននិយាយថាខ្ញុំអានសៀវភៅច្រើនទេ ខ្ញុំអានសៀវភៅខ្លះដែលទាក់ទងនឹងៗសៀវភៅដែលទាក់ទងនឹងខ្មែរក្រហម ដូចជាសៀវភៅ ម៉ាដាម ឡូរ៉ង់ ពិច ឈ្មោះ "ថ្ងៃហួសជើងមេឃ"។ ហើយសៀវភៅមួយទៀត សៀវភៅសម្តេច សីហនុ ដែលលោកសរសេរថា "អ្នកទោសខ្មែរក្រហម" "*ព្រីសោនញេ ដឺ ខ្មែរ រូស្ស*" បាទ។ ខ្ញុំបានសរសេរ -- ខ្ញុំបាននិយាយដូច្នេះ។

[០៩:៤៣:០៣]

**ស៖** សៀវភៅមួយទៀតនោះ គឺថាជាសៀវភៅដែលសរសេរឡើងដោយៗសម្តេច នរោត្តម សីហនុ តើអ៊ីចឹងមែនឬទេ?

**ឆ៖** បាន សៀវភៅសរសេរដោយសម្តេចព្រះ នរោត្តម សីហនុ លោកសរសេរជាភាសាបារាំងឈ្មោះ *"ព្រីសោនញេ ដឺ ខ្មែរ រូស្ស"* គឺ "អ្នកទោសខ្មែរក្រហម"។

**ស៖** ឥឡូវនេះ បើយើងត្រូវយល់សក្ខីកម្មរបស់លោក អ្វីដែលលោកឆ្លើយនោះ គឺថាក្នុងសម័យកាលនោះ ឆ្នាំ១៩៧៥ -- ឆ្នាំ១៩៧៩ ដល់ឆ្នាំ២០០០ ហើយៗអ្វីដែលលោកបានអានជាសរុប ជាសៀវភៅរបស់បញ្ញវន្តនោះ ក្នុងសម័យកាលហ្នឹង តាំងពីឆ្នាំ៧៥ ដល់ ៧៩ តើសៀវភៅតែពីរហ្នឹងទេ ឬក៏មានសៀវភៅអ្វីផ្សេងទៀត?

[០៩:៤៤:០៣]

**ឆ៖** ជំនាន់ខ្មែរក្រហម ខ្ញុំអានតែសៀវភៅបីនោះទេ ដែលខ្ញុំបានរើស--

**ស៖** ខ្ញុំសូមកាត់ ហើយខ្ញុំសួរលោកក្រោយពីសម័យនុ៎ងទេ ហើយលោកបាននិយាយច្រើនដងថា ហើយលោកក៏ជាបញ្ញវន្តដែរ។ ឥឡូវនេះ ខ្ញុំចង់រកឲ្យដឹងច្បាស់ថា តើលោកអានសៀវភៅប៉ុន្មាន ចាប់ពីឆ្នាំ១៩៧៩ រហូតមកដល់ឆ្នាំ២០០៤? លោកអះអាងថាលោកបានអានតែពីរ។ តើលោកប្រកាន់ចម្លើយនេះដែរទេ លោកបានអានសៀវភៅតែពីរដែលលោកឆ្លើយអម្បាញ់មិញនេះ? តើពីរប៉ុណ្ណឹង ឬក៏ប៉ុន្មាន?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន មេធាវីបានអាងពីចំណុចមួយដែលថាសាក្សីមិនបានបញ្ជាក់ប្រាកដថា គាត់អានសៀវភៅតែពីរ ចាប់ពីឆ្នាំ១៩៧៥មកទេ ហើយទាក់ទងនឹងសំណួរដោយមេធាវីការពារក្តីលោក នួន ជា នោះ គាត់ឆ្លើយថា គាត់បានអានសៀវភៅពីរហ្នឹង ក្រោយឆ្នាំ១៩៧៩។ ដូច្នេះហើយៗ សូមឲ្យបង្ហាញសក្ខីរបស់គាត់ជូនគាត់ដើម្បីឲ្យបានត្រឹមត្រូវ។

**លោក ម៉ៃខល កាណាវាស៖**

សូមលោកប្រធាន យើងឃើញច្បាស់ហើយជាក់ស្តែងគឺថាគាត់ឆ្លើយថា គាត់អានសៀវភៅពីរនៅក្នុងសម័យហ្នឹងគឺមិនមែនសៀវភៅទាំងអស់នោះទេ ហើយគាត់បានឆ្លើយថា គាត់មិនបានទទួលឥទ្ធិពលអ្វីពេលដែលគាត់អាននោះទេ។ ហើយខ្ញុំចង់ចុចសាក្សីថាតើ លោកឆ្លើយឲ្យប្រាកដថាមានសៀវភៅប៉ុន្មានដែលគាត់អានអំពីសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង លោកបានអានសៀវភៅប៉ុន្មាន។

[០៩:៤៥:៤៩]

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គឺនៅពេលខ្ញុំធ្វើការនៅមន្ទីរពេទ្យយោធា ព-២ ខ្ញុំបានជម្រាបហើយថាខ្ញុំបានអានសៀវភៅពីរ ដែលមិនទាក់ទងនឹងរឿងខ្មែរក្រហមទេ។ ហើយពេលខ្ញុំមកធ្វើការនៅមន្ទីរពេទ្យ ព-១ ខ្ញុំលួចអានសៀវភៅមួយទៀត ឈ្មោះ សៀវភៅមួយទៀតបាទ របស់ ថម សយយ័រ បី នេះជំនាន់ខ្មែរក្រហមបាទ។ ដែលក្រោយមកទៀត ខ្ញុំអានសៀវភៅ ម៉ាដាម ឡូវ៉ង់ ពិច មួយ ហើយសៀវភៅសម្តេច សីហនុ មួយ ហើយសៀវភៅក្រោយមកទៀតសៀវភៅ ក្រោយមកទៀតខ្ញុំក៏អានដែរប៉ុន្តែខ្ញុំអានមិនបានច្រើនទេ ហើយខ្ញុំក៏មិនចាំទាំងអស់ដែរបាទ។ ព្រោះខ្ញុំមិនបានអានច្រើនដូចពេលខ្ញុំនៅជំនាន់ ប៉ុល ពត ខ្ញុំអានគ្រប់ទំព័របាទ។ គ្រាន់តែឃើញខ្ញុំអានបន្តិចៗនោះ ហើយអានមិនច្រើនទេបាទ។ គឺថាអ្វីដែលខ្ញុំអាន សៀវភៅដែលខ្ញុំអាន គ្មានឥទ្ធិពលអ្វីមកលើខ្ញុំទេ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** សូមអរគុណ។ ឥឡូវនេះយើងនិយាយអំពីសម័យឆ្នាំ១៩៧៥ដល់៧៩ លោកប្រាប់ថា លោកបាននិយាយថាមានវិទ្យុមួយគឺលោកសរសេរ បានសរសេរថា ជាវិទ្យុសូនី តើលោកនៅចាំទេពីរឿងហ្នឹង?

[០៩:៤៧:៣២]

**ឆ៖** ខ្ញុំបាទមានវិទ្យុ កូនវិទ្យុស្ងួនីមួយ ខ្ញុំលួចស្ដាប់ពេលយប់ ដោយខ្ញុំមានប្រដាប់ស្ដាប់ត្រចៀក ពេលយប់។

**ស៖** តើលោកអាចប្រាប់ខ្ញុំបានទេ តើវិទ្យុនោះទំហំប៉ុនណានៅក្នុងឆ្នាំ១៩៧៥នោះ ដែលលោកថាមានវិទ្យុហ្នឹងទំហំវាប៉ុនណា?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

ចាំៗក្បាលមីក្រូប្រតិបត្តិការសិនលោកសាក្សី!

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** វិទ្យុនោះគឺទទឹងប្រហែល១០សង់ទីម៉ែត្រ បណ្ដោយប្រហែល ២០ សង់ទីម៉ែត្រ ចំណែកប្រដាប់ស្ដាប់ ខ្ញុំដាក់នៅក្នុងហោប៉ៅខ្ញុំជានិច្ចបាទ ខ្ញុំមិនដាក់ក្រៅទេ។

**ស៖** បាទ នៅពេលដែលលោករៀបរាប់អំពីទំហំវិទ្យុ ខ្ញុំឃើញថាគឺអំពីការផ្លាស់ប្ដូរដាក់កន្លែងណាមួយនៅក្នុងសៀវភៅ ដូចថាអាចជាប្រអប់តូចមួយតើវាតូចប៉ុណ្ណឹង ឬក៏សូមលោករៀបរាប់អំពីទំហំនៃវិទ្យុហ្នឹងថាតើទំហំប៉ុនណា? បើសិនជាទំហំដូចថាវាធំជាងដូចដែលខ្ញុំរៀបប្រអប់ដាក់អ្វីតូចមួយហ្នឹង តើលោកអាចបន្ថែមបានទេ?

**ឆ៖** ទំហំមិនធំទេ គឺថាខ្ញុំដាក់នៅក្រោមស្បោងមួយ ហើយស្បោងនោះគឺធ្វើជាខ្នើយ ពេលខ្ញុំដេកខ្ញុំធ្វើជាខ្នើយ។

[០៩:៤៩:៤៦]

**ស៖** ឥឡូវនេះលោកបានប្រាប់ខ្ញុំថា លោកមានសៀវភៅបី ហើយលោកបានរៀបរាប់ក្នុងសៀវភៅថា លោកបានមាននាឡិការ៉ូឡិច មួយជានាឡិកាដ៏ថ្លៃ ហើយលោករក្សាទុករហូតដល់ឆ្នាំ១៩៧៩។ តើត្រឹមត្រូវអ៊ីចឹងដែរឬទេ?

**ឆ៖** ត្រូវ រ៉ូឡិច ខ្ញុំពាក់នេះបាទ រ៉ូឡិច។

**ស៖** ហើយលោកក៏បាននិយាយផងដែរ អំពីការមាន ការរក្សាទុកមាស គឺជាមាសនោះហើយដែលលោកបានប្រើដើម្បីទិញថ្មសម្រាប់ប្រើវិទ្យុ ដែលលោកអះអាងថា ដើម្បីលោកប្រើរហូតមកដល់ឆ្នាំ១៩៧៩ ខែកក្កដា ហើយលោកបានទុកមាសជាមួយខ្លួនគាត់រហូតផងដែរ លោកកាន់មាសមួយចំនួន

ផងដែរ តើអ៊ីចឹងដែរឬទេ?

**ឆ៖** មាសនោះគឺថា ពុំមែនខ្ញុំទុកខ្លួនខ្ញុំទេ គឺម្ដាយខ្ញុំគាត់ជាអ្នកទុកដាក់។

**ស៖** តើអ្នកណាជាអ្នកសម្រេចទុក ម្ដាយលោក ឬក៏លោកជាអ្នកកាន់វា នៅពេលដែលលោកត្រូវការប្ដូរទិញថ្នអី លោកទៅម្ដាយលោកដើម្បីសុំមាសយកមកប្ដូរ ឬក៏ធ្វើដូចម្ដេច?

**ឆ៖** ម្ដាយខ្ញុំបាទ ជាអ្នកទុក ទុកមាសហ្នឹងបាទ។

**ស៖** រីឯថ្នដែលលោកបានទិញសម្រាប់ប្រើវិទ្យុស្ទូនីនោះ តើលោកទិញនៅកន្លែងណា ទិញពីអ្នកណា នៅកន្លែងណា ដែលអាចទិញថ្នពិល ថ្នវិទ្យុហ្នឹងបាននោះ?

**ឆ៖** ខ្ញុំសូមជម្រាបលោកថា នៅជំនាន់ ប៉ុល ពត យើងៗ -- មាសជាទូទៅ គឺថាអ្នកជម្លៀស គឺថាយកមាស យកទៅទិញដោយស្ងាត់ៗ នូវស្ករ នូវអង្ករ ថ្នពិលអីជាដើម ចំពោះខ្ញុំបាទ គឺទិញដោយស្ងាត់ៗ គឺមានការជួញដូរស្ងាត់ៗជំនាន់ ប៉ុល ពត មិនអត់ទេបាទ។

**ស៖** បាទ ហើយសូមលោកឆ្លើយសំណួរខ្ញុំ។ ខ្ញុំសួរលោកថា តើលោកយកមាសទៅប្ដូរថ្នពិលហ្នឹងប្ដូរជាមួយអ្នកណា? តើពួកហ្នឹងជាកម្មាភិបាលខ្មែរក្រហម ឬក៏ជាអ្នកមានហាងពីមុន ហើយមុនពេលដែលភៀសខ្លួនទៅ បានទុកថ្នពិលតាមខ្លួន ឬក៏យ៉ាងម៉េច ដើម្បីប្ដូរបាននោះ?

[០៩:៥២:៤២]

**ឆ៖** គឺប្ដូរ គេយកមាសទៅទិញអ្នកជម្លៀសដូចគ្នា ជាអ្នកក្រុងទេ ជម្លៀសដូចគ្នា គេដូរពួកហ្នឹងបាទ។

**ស៖** ហើយរហូតមកដល់ខែកក្កដា ឬខែមិថុនា ឆ្នាំ១៩៧៧ អ្នកជម្លៀសនៅរក្សាទុកនៅរបស់មួយចំនួនដូចជាថ្នពិលហ្នឹងដែរឬទេ ឬក៏តាមអ្វីដែលលោកឆ្លើយនោះ? ហើយនៅក្នុងនោះ គឺថាក្នុងលោកផ្ទាល់គឺថាមានគេឆែកឆេរផង តើអាចទៅរួចទេបែបនេះនោះ?

**ឆ៖** បាទ ការឆែកឆេរនៅតែឆែកឆេរអ៊ីចឹង ប៉ុន្តែការដោះដូរ នៅតែមានអ៊ីចឹងការដោះដូរ។ ការលួចទិញស្ករជាមាស ការលួចទិញថ្នពិល ការលួចទិញរបស់របរ គឺថាមានបាទ មិនអត់ទេ។

**ស៖** ឥឡូវលោកអះអាងថា លោកមានកូនសៀវភៅមួយដើម្បីកត់ត្រា ហើយលោកកម្ទេចចោល ប៉ុន្តែដោយមានគេឆែកឆេរតាមដាន លោកមានការភ័យខ្លាច។ តើលោកមានបញ្ហាអ្វីទេ ក្នុងការមានវិទ្យុមួយគឺថាដែលទំហំប៉ុនប្រអប់តូចមួយនោះ ដែលថាចោទជាបញ្ហាទេ លាក់យ៉ាងម៉េចអីយ៉ាងម៉េច?

[០៩:៥៩:១៨]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំសូមកត់សម្គាល់មួយ តើលោក កាណាវាស អាចថាំបន្តិចបានទេ ព្រោះអ្នកបកប្រែ បកបាត់ក្បាលឃ្លារហូតពេលដែលចាប់ផ្តើមហ្នឹង គាត់ប្រញាប់សួរពេក។ អ៊ីចឹងសូមឲ្យគាត់បន្ថយល្បឿនបន្តិចចាំឲ្យគេបកប្រែចប់សិន។

**លោក ម៉ែខល កាណាវាស៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតបទៅនឹងសំណួរ ប្រសិនបើលោកនៅចងចាំសំណួរដែលសួរចុងក្រោយអម្បាញ់មិញនេះ ដោយមេធាវីការពារក្តី។

[០៩:៥៥:០៤]

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ ខ្ញុំដូចជាភ្លេចសំណួរអំមិញ។ សូមលោក កាណាវាស សូមលើកសំណួរម្តងទៀតបាទ ខ្ញុំភ្លេច។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** បាទ ខ្ញុំនឹងមួយជំហានម្តង សួរមួយជំហានម្តង ហើយខ្ញុំសួរថាជាមួយនឹងវិទ្យុ ប្រសិនបើអ្នកណាឃើញលោកមានវិទ្យុដែលលោករក្សាទុកនោះ តើនាំឲ្យលោកមានបញ្ហាអ្វីទេ នាសម័យកាលនោះ?

**ឆ៖** បាទ ជាការគិតពិត ជាការប្រថុយជីវិតក្នុងការមានវិទ្យុ និងលួចអានវិទ្យុបាទ និងការអានសៀវភៅ។ ប៉ុន្តែខ្ញុំស្រេកឃ្លានព័ត៌មាន ខ្ញុំស្រេកឃ្លានការអាន។ ដូច្នេះបានជាខ្ញុំប្រថុយជីវិត។

[០៩:៥៦:១០]

**ស៖** បាទ ដូច្នេះតាមអ្វីដែលលោកឆ្លើយនោះសៀវភៅនោះ សៀវភៅទាំងនោះជាភាសាបារាំង អង់គ្លេសផងដែរ ក៏មាននិយាយអំពី -- ដែលអាចធ្វើឱ្យលោកមានបញ្ហាដែរ បើគេដឹងថាលោកមានសៀវភៅបែបនេះនោះ?

**ឆ៖** បាទ សូមជម្រាបលោកថា ខ្ញុំធ្វើ ប្រើល្បិចដូចតទៅនេះ៖ នៅមន្ទីរពេទ្យ ខ្ញុំអានសៀវភៅ--

**ស៖** លោកសាក្សី ខ្ញុំមានពេលតិចណាស់។ ខ្ញុំចង់បានចម្លើយសូមលោកកុំយល់ថា ខ្ញុំដូចជាបំពានលើលោក ថាហេតុអីបានជា -- ហេតុអីលោកបានរក្សាទុក លោកបាននិយាយថា លោកបានកម្ទេចចោល។ ឥឡូវនេះ ហើយថាដោយសៀវភៅផ្សេងទៀតដែលអាចធ្វើឱ្យលោកមានបញ្ហាទេ ពេលនោះ លោកអាចឆ្លើយថា បាទ ឬទេ?

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយតប!

[០៩:៥៧:១៦]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥៧:៤៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ឡើងធ្វើអន្តរាគមន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ខ្ញុំសូមធ្វើការកត់សម្គាល់ចំនួនបី ការកត់សម្គាល់ទី១ សាក្សីបានឆ្លើយទៅនឹងសំណួរដែលលោក កាណាវាស ធ្លាប់បានចោទសួររួចមកហើយ។ អ៊ីចឹងសំណួរនេះច្រំដែល។ ការកត់សម្គាល់ទី២ នោះគឺថា លោក កាណាវាស និយាយសំឡេងនេះនិយាយនោះមិនគួរសមទាល់តែសោះ។ ហើយការកត់សម្គាល់ទី៣ នៅពេលដែលលោក កាណាវាស និយាយថា គាត់មិនចង់ច្រឡើបើសទេ អ៊ីចឹងខ្ញុំគិតថា គួរតែផ្លាស់ប្តូរឥរិយាបថហ្នឹងទៅ បើនិយាយដូច្នេះហើយ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** គឺថា ការប្រើមាស គឺថាតើនាំឱ្យលោកមានបញ្ហាដែរឬទេ បើគេដឹងថាលោកមានមាស ហើយប្រើមាសដើម្បីទិញថ្នាំវិទ្យុអ្វីជាដើមនោះ?

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ខ្ញុំយល់ថា អ្នកជម្លៀសមួយចំនួនមិនមែនមានតែខ្ញុំទេ គឺតែងតែមានមាសដែលជាប់នឹងខ្លួន ហើយគេប្រើមាសនោះដោះស្រាយជីភាពនៅពេលដែលគេទាល់ច្រក និងការលំបាក។

**ស៖** ឥឡូវនេះ សូមលោកមេត្តាឆ្លើយសំណួរខ្ញុំ។ ហើយខ្ញុំមិនគិតថា ជាសំណួរច្រំដែលដើម្បីសួរលោកឲ្យលោកឆ្លើយថា តើបើគេរកឃើញថាលោកមានមាស តើលោកនឹងមានបញ្ហាដែរឬទេ? គឺជាសំណួរសាមញ្ញទេ សូមលោកសាក្សីឆ្លើយបាទ។

[០៩:៥៩:៤៧]

**ឆ៖** បើគេដឹងថា យើងមានមាស គេយកមាសៗជារបស់យើង។

**ស៖** ចុះចំពោះនាឡិការ៉ូឡិច តើលោកពាក់នាឡិការ៉ូឡិចនេះដោយចំហ ឬក៏លោកលាក់ជាមួយវិទ្យុ ឬក៏លាក់របៀបម៉េចជាមួយសៀវភៅ ឬក៏យ៉ាងដូចម្តេច?

**ឆ៖** ខ្ញុំបានសរសេរក្នុងសៀវភៅដែរ ចំពោះនាឡិការ៉ូឡិចនេះ គឺខ្ញុំបានដាក់ក្នុងថង់ប្លាស្ទិកជាច្រើនជាន់រុំក្រណាត់ជាច្រើនជាន់ ហើយកប់នៅក្នុងដី។ ដល់ ៧៩ បានគាស់វាយកមកវិញ។

**ស៖** ប៉ុន្តែលោកបានឆ្លើយប្រាប់តុលាការថា លោកបានរៀបចំកំណត់ហេតុ លោកសរសេរជាកំណត់ហេតុ ប៉ុន្តែលោកកម្ទេចវាចោល ដោយហេតុថា លោកមានការភ័យខ្លាចអំពីសុវត្ថិភាព។ ថាតើទៅដូចម្តេចនឹងកើតថាលោកមានវិទ្យុ ដែលថាធំជាងសៀវភៅនុ៎ងទៀត គឺថាសៀវភៅបីក្បាលផ្សេងទៀត ក៏វាមានទំហំធំ ធ្វើឲ្យគេសម្គាល់បានដែរ។ រីឯមាសដែលលោកបានមកយកមកប្រើ ទិញពីអ្នកផ្សេងនូវថ្នា ហើយៗនាឡិការ៉ូឡិចកប់ទុក។ ឥឡូវនេះ អ្វីដែលលោកអះអាងថា លោកបានកត់ត្រា ប៉ុន្តែកម្ទេចសៀវភៅនោះចោល។ ប៉ុន្តែលោកបែរជារក្សាទុករបស់ផ្សេងៗធំៗជាងហ្នឹងបាន ដែលថាមើលទៅទំហំធំ។ ប៉ុន្តែសូមលោកចងចាំថា លោកក៏ត្រូវធ្វើដំណើរបន្តិចបន្តួចដែរនៅពេលនោះ ពីកន្លែងមួយទៅកន្លែងមួយ។ តើលោកអាចមានចម្លើយអ្វីទៀតទេ?

[១០:០១:៤៨]

**ឆ៖** ខ្ញុំបាទសូមនិយាយដោយទូលំទូលាយបន្តិច។ ខ្ញុំមិនអាចថាលោកសួរភ្លាម ឆ្លើយភ្លាមទេ។ ចំពោះសៀវភៅៗខ្ញុំអាននៅមន្ទីរពេទ្យយោធា ហើយនៅមន្ទីរពេទ្យយោធានោះ គេឲ្យបន្ទប់ខ្ញុំមួយនៅដោយឡែក មកនៅម្នាក់ឯង។ ហើយសៀវភៅទៀត ពេលខ្ញុំបានខ្ញុំហែកចោល ខ្ញុំហែកក្របចោលៗ ហើយពេលខ្ញុំអាន ខ្ញុំអានបានប៉ុន្មានទំព័រ ហែកទំព័រចោលបាទ ហែកទំព័រចោល។ ហើយពេលនោះសូម

ជម្រាបថា ក្រដាសគេត្រូវការណាស់ ដើម្បីយកមូរបារី។ ខ្ញុំយកក្រដាសចែកឲ្យគេដើម្បី -- គ្នាឯងដើម្បីយកទៅមូរបារីជក់។ ខ្ញុំធ្វើអ៊ីចឹងៗសៀវភៅ ខ្ញុំមិនបានរក្សាទុកទេ។ ហែកក្របចោល ធ្វើឲ្យវាចាស់ អាន១បានបួនប្រាំទំព័រហែកចោលៗ។ នេះជាសៀវភៅបាទ។ ហើយចំពោះនាឡិកា ខ្ញុំកប់ ហើយចំពោះកំណត់ហេតុ គឺថាខ្ញុំពុំអាចទុកបានទេ ខ្ញុំត្រូវតែដុតចោល ពីព្រោះវាគ្រោះថ្នាក់ ព្រោះថាខ្មែរក្រហម -- កំណត់ហេតុខ្ញុំមិនមែនកត់នៅមន្ទីរពេទ្យទេ ខ្ញុំកត់ពេលខ្ញុំចេញពីមន្ទីរពេទ្យហើយ គឺពេលមកខ្ញុំមកធ្វើស្រែនៅសហករណ៍។ ពេលនោះមានការឆែកឆេរច្រើនណាស់នៅសហករណ៍ ហើយខ្ញុំបានហែកសៀវភៅនេះនៅសហករណ៍បាទ។ ដូច្នេះការអានសៀវភៅ គឺនៅមន្ទីរពេទ្យខេត្ត នៅមន្ទីរពេទ្យឃោធា ពេទ្យស៊ីវិលដែលខ្ញុំធ្វើការ ហើយចំពោះការកប់នាឡិការ៉ូឡិចនោះ គឺនៅ -- និងវិទ្យុនោះ គឺនៅកប់នាឡិកាគឺនៅសហករណ៍ ហើយចំពោះវិទ្យុខ្ញុំដាក់នៅក្នុងស្រោមៗមួយដែលមានមុងផង មានៗភួយផង ហើយខ្ញុំធ្វើជាខ្នើយពេលខ្ញុំដេក។

[១០:០៤:០៧]

**ស៖** យើងជឿជាក់ថា តាមអ្វីដែលយើងខ្ញុំស្ដាប់ គឺថាបន្ទប់លោកគឺអត់ត្រូវបានគេឆែកឆេរមើលទេ បើសិនគេឆែកឆេរមើល គេប្រហែលជារកឃើញ ប្រហែលជាគេឆែកទាំងខ្នើយខិប ខ្នើយកើយរបស់លោកហើយ។ តាមអ្វីដែលលោកបានលើកឡើងនៅទំព័រ៨០ នៃសៀវភៅរបស់លោកផ្ទាល់ លោកបាននិយាយថា "ព័ត៌មានចុងក្រោយដែលលោកទទួលបានគឺនៅក្នុងខែកក្កដា ឆ្នាំ -- គឺរហូតដល់ថ្ងៃ -- រហូតដល់ខែកក្កដា ឆ្នាំ១៩៧៧"។ ទោះបីថាលោកធ្វើដំណើរទៅមកច្រើនកន្លែងក៏ដោយ។ លោកនៅតែអាចលាក់ទុកបាននូវវត្ថុដែលមានទំហំធំ ប៉ុន្តែក្នុងពេលជាមួយហ្នឹង លោកបែរជាមិនអាចលាក់នូវសៀវភៅកំណត់ត្រារបស់លោកបានទៅវិញ។ តើយ៉ាងដូចម្ដេចដែរ ចំពោះបញ្ហានេះ?

**ឆ៖** សូមជម្រាបលោក វាចែកជាពីរផ្នែក រឿងចែកជាពីរផ្នែក ដូចខ្ញុំបានជម្រាបលោកអ៊ីចឹង។ នៅមន្ទីរពេទ្យខេត្ត នៅមន្ទីរពេទ្យឃោធា គេឲ្យ គឺថាមិនមែនជាបន្ទប់ ជាផ្ទះ ផ្ទះ ដោយសារផ្ទះនៅជុំវិញមន្ទីរពេទ្យមានច្រើន ខ្ញុំគេឲ្យផ្ទះមួយនៅដោយឡែក។ ដូច្នេះ ខ្ញុំឆ្លៀតលួចអានសៀវភៅ ប៉ុន្តែមិនមែនថាយើងប៉ានចំហទេ គឺថាដូចខ្ញុំនិយាយអ៊ីចឹង ហែកក្របវាចោល ហើយអានហែកៗ អានហែកក្រដាសចោលបាទ។ ហើយចំពោះវ៉ាឌ្យូវិញគឺថា ទាំងនៅមន្ទីរពេទ្យ ទាំងពេលខ្ញុំចេញពីមន្ទីរពេទ្យ មកធ្វើជាអ្នកឃ្វាលគោ ធ្វើជាអ្នកធ្វើស្រែ គឺខ្ញុំដាក់នៅក្នុងថង់ខ្ញុំដែលមានមុងខ្នើយ ខ្ញុំធ្វើជា១ ដែលមានមុង ហើយខ្ញុំធ្វើជាខ្នើយសម្រាប់ដេក។ ហើយខ្ញុំនៅខ្ទមមួយដោយឡែក។

**ស៖** សូមរអរគុណលោកសាក្សី សូមអរគុណច្រើន។ ខ្ញុំសូមបន្តទៅមុខទៀត។ ពីឆ្នាំ១៩៧៩ រហូតដល់ ២០០៤ គឺលោកមិនបានព្យាយាមរៀបរាប់ ឬក៏សរសេរឡើងវិញនូវកំណត់ត្រាដែលលោកបានសរសេរកាលពីសម័យមុននោះទេ គឺថាក្នុងរយៈពេលប្រហែលជា ២៥ឆ្នាំ គឺលោកមិនបានចាប់ផ្ដើមរៀបចំនូវកំណត់ត្រាឡើងវិញទេ ប៉ុន្តែលោកអាចសរសេរសៀវភៅទាំងមូល ទាំងស្រុងនេះបានដោយផ្អែកទៅលើការចងចាំរបស់លោក តើលោកមានមតិអ្វីដែរ?

**ឆ៖** បាទ ការឆ្លងកាត់បទពិសោធន៍នៅក្នុងជំនាន់ ប៉ុលពត មិនអាចធ្វើឲ្យខ្ញុំភ្លេចបានទេ។ ខ្ញុំចាំជានិច្ច ហើយខ្ញុំមានបំណងសរសេរសៀវភៅជានិច្ចបាទ។

[១០:០៧:២២]

**ស៖** បាទ ឥឡូវនេះយើងពិនិត្យមើលទៅលើឧទាហរណ៍ទំព័រទី១១ នៃសៀវភៅរបស់លោក គឺទំព័រទី១១ ជាភាសាអង់គ្លេស ខ្មែរមានលេខ 00678956 ដល់ 57 គឺលេខ 00678956 (ស៊ីក) ដល់ 57 ខ្ញុំសូមអភ័យទោសដែលមិនមានជា ភាសាបារាំងគឺបាននិយាយថា នៅកថាខណ្ឌទីពីរ គឺថា “នៅម៉ោងប្រាំបួនយប់ ឧទ្ធម្ភាគចក្របានចុះនៅកន្លែងក្មេងលេងនៅមាត់នៃស្ទឹងសង្កែ” ខ្ញុំសូមផ្អាកត្រឹមចំណុចនេះ។ តើលោកបានឃើញឧទ្ធម្ភាគចក្រៗចុះនៅទីនោះដែរឬទេ? តើលោកបានឃើញដោយផ្ទាល់ដែរឬទេ?

**ឆ៖** ថ្ងៃ១៧ មេសា គឺនៅថ្ងៃ១៧ មេសា ១៩៧៥ ពេលម៉ោង ប្រាំបួនព្រឹក មានអេលីកុមួយបានមកចុះនៅសួនកុមារ ហើយបងប្អូនគេដែលនៅផ្លូវលេខ២ គេនាំគ្នា -- ពីរបីនាក់គេនាំគ្នា ដើរកាត់ផ្លូវស្ពានដែក ហើយឡើងអេលីកូ ហើយឡើងទៅលើបាត់ទៅ។ ហ្នឹងខ្ញុំឃើញផ្ទាល់។

[១០:០៨:៤៦]

**ស៖** តើលោកបានឃើញដោយផ្ទាល់ ឬក៏លោកឮគេប្រាប់លោកទេ គឺថាអ្វីដែលកើតឡើងនៅម៉ោងប្រាំបួនព្រឹកដែលខ្ញុំនិយាយអំមិញនោះ?

**ឆ៖** និយាយប្រាប់លោកហើយថា ខ្ញុំបានឃើញផ្ទាល់។

**ស៖** ដូច្នេះគឺខ្ញុំសូមអភ័យទោស ដោយសារតែគេមិនបានបកប្រែឲ្យខ្ញុំស្ដាប់។ នៅត្រង់ចំណុចនោះ នៅត្រង់សៀវភៅផ្នែកនោះដដែលគេនិយាយ -- លោកនិយាយថា លោកមិនបានឃើញទេ ប៉ុន្តែអ្នកដទៃប្រាប់លោក តើត្រឹមត្រូវដែរឬទេ?

**ឆ៖** សូមទោសផ្នែកត្រង់ណាដែលលោកមានប្រសាសន៍ ផ្នែកត្រង់ណា?

**ស៖** ឥឡូវនេះខ្ញុំសូមសួរលោកបន្តិចដោយសារថាលោកមានការចងចាំល្អ។ ថាតើលោកអាច

ប្រាប់បានដែរឬទេ ថានៅថ្ងៃព្រហស្បតិ៍ ឬក៏ថ្ងៃសុក្រ លោកបានប្រាប់យើងដោយលោកបានស្បថរួចទៅហើយ លោកបានប្រាប់យើងថា លោកបានឮនូវព្រឹត្តិការណ៍ដោយមិនមែនឃើញដោយផ្ទាល់នោះទេ នេះគឺជាសំណួរដែលលើកឡើងដោយព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ហើយខ្ញុំគិតថាខាងមេធាវីក៏បានសួរដែរ។ តើលោកចាំថាលោកបាននិយាយ ថាលោកបានឮគេដែរឬទេ អំពីបញ្ហាមួយចំនួននោះ?

**ឆ៖** ខ្ញុំចង់សួរលោក ថាតើលោកចង់និយាយពីអ្វី? ព្រោះខ្ញុំមិនយល់ពីអ្វីដែលលោកនិយាយ។

**ស៖** ឥឡូវនេះ យើងមើលទៅទំព័រទី៦នៃសៀវភៅរបស់លោក។ លោកបាននិយាយនៅទីព័រទី៦ គឺភាសាខ្មែរមានលេខ 00369675 គឺកថាខណ្ឌទី៣ នៅបុព្វកថា "ខ្ញុំសរសេរពីអ្វីដែលខ្ញុំឮ ខ្ញុំឃើញ"។ នៅពេលដែលលោកនិយាយថា "អ្វីដែលលោកឮ" តើលោកចង់និយាយអំពីអ្វីដែលលោកឮពីអ្នកដទៃ ឬមួយក៏យើងគិតថា អ្វីៗដែលលោកបានសរសេរនៅក្នុងសៀវភៅទាំងអស់ហ្នឹង គឺជាអ្វីដែលលោកបានឃើញដោយផ្ទាល់ មិនមែនជាអ្វីដែលលោកបានឮគេនិយាយនោះទេ តើអ្វីៗទាំងអស់ គឺជាអ្វីដែលលោកបានដឹង បានឃើញដោយផ្ទាល់ឬ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១០:១១:៣៤]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំគិតថា ប្រហែលជាមេធាវីការពារក្តីនិយាយមិនឲ្យបានច្បាស់លាស់។ ព្រោះថាកាលពីសប្តាហ៍មុនលោកវេជ្ជបណ្ឌិតបានបញ្ជាក់យ៉ាងច្បាស់ បានផ្តល់សក្ខីកម្មយ៉ាងច្បាស់ថាព្រឹត្តិការណ៍ខ្លះ គាត់ឃើញដោយខ្លួនឯង ព្រឹត្តិការណ៍ខ្លះគាត់ស្តាប់ឮពីគេ។ ដូច្នេះហើយខ្ញុំគិតថា ប្រសិនបើគាត់ -- មេធាវីការពារក្តីលើកឡើងថា អ្វីៗទាំងអស់ដែលសាក្សីគាត់ឃើញ បានសរសេរហ្នឹង គឺជាអ្វីដែលគាត់ឃើញហ្នឹង គឺជាមិន គឺជាការមិនត្រឹមត្រូវនោះឡើយ។ ដូច្នេះ យើងមិនគួរធ្វើការលើកឡើងនូវបញ្ហា ឬក៏ចំណុចបែបនេះយកមកនិយាយនោះឡើយ។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំស្របជាមួយនឹងអ្វីដែលព្រះរាជអាជ្ញាបានលើកឡើង។ ប៉ុន្តែ ក្នុងចំណុចមួយ

គឺថាសាក្សីគាត់អាចនឹងមិនមានការចងចាំល្អ ព្រោះថាកាលពីសប្តាហ៍មុនគាត់មិនចាំច្បាស់ផង តើអ្វីដែលកើតឡើងប៉ុន្មានសិបឆ្នាំមុន តើយើងដូចម្តេចដែរ? ២៥, ២៦ឆ្នាំ យ៉ាងដូចម្តេចដែរ?

ដូច្នេះយើងដឹងថា តើសាក្សីគាត់ធ្វើការផ្លាស់ប្តូរនូវសក្ខីកម្ម ឬក៏អត់។ ដូច្នេះហើយ ទើបយើងចង់ផ្តល់ឱកាសសល់សាក្សី ដើម្បីឲ្យគាត់ធ្វើការផ្លាស់ប្តូរប្រសិនបើគាត់ចង់។ ប៉ុន្តែប្រសិនបើព្រះរាជអាជ្ញាគាត់ជឿទុកចិត្ត យើងអាចទទួលយកនូវការតំណាងរបស់ ការលើកឡើងរបស់ព្រះរាជអាជ្ញា ដែលថាអ្វីដែលសាក្សីសរសេរនោះមិនមែនត្រឹមជាអ្វីដែលគាត់ឃើញដោយផ្ទាល់ទេ វាអាចជាការស្តាប់ឮតពីគេ ឬក៏ឮតៗពីពីរបីបួននាក់ ប្រាំនាក់មកបន្ថែមទៀតនោះ តើ -- ដែលនេះជាអ្វីដែលខ្ញុំចង់បញ្ជាក់។

[១០:១៣:១៤]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! មានបញ្ហាអីទៀតលោកតំណាងសហព្រះរាជអាជ្ញា?

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមអភ័យទោស ដែលខ្ញុំត្រូវចំណាយពេលវេលាច្រើន។ ខ្ញុំងើបឈរឡើងដោយសារតែមេធាវីការពារក្តីបានធ្វើឲ្យយើងនូវ -- ចាំបាច់ត្រូវលើកឡើងនូវបញ្ហាមួយចំនួន។ មធ្យោបាយសំខាន់ដែលយើងត្រូវធ្វើ គឺយើងត្រូវសាកសួរថា សាក្សីគាត់ដឹងដោយផ្ទាល់ភ្នែក ឬក៏គាត់ដឹងតាមវិធីណាផ្សេងឲ្យបានច្បាស់លាស់នោះឯង។ ដូច្នេះ យើងត្រូវតែធ្វើការសាកសួរបែបនេះផ្អែកទៅលើហេតុការណ៍ដែលគាត់ដឹង ហេតុការណ៍ដែលគាត់ឃើញដោយផ្ទាល់ និងឮ។ យើងត្រូវបញ្ជាក់ឲ្យបានច្បាស់ ថាតើព្រឹត្តិការណ៍ណាខ្លះដែលគាត់ដឹងឮ គាត់ដឹងដោយផ្ទាល់នូវព្រឹត្តិការណ៍ណាខ្លះ ដែលគាត់ឃើញ ឬក៏គាត់ឮពីគេ។ ដូច្នេះគឺយើងគួរតែសាកសួរសាក្សីដោយរបៀបនេះ។ ខ្ញុំសូមអរគុណ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមសួរសំណួរបន្ទាប់របស់ខ្ញុំ។

**ស៖** លោកសាក្សី កាលពីសប្តាហ៍មុន លោកបានប្រាប់យើងថា "លោកមិនមានសេរីភាពក្នុងការធ្វើដំណើរដោយសេរីនោះឡើយ"។ តើលោកនៅគាំទ្រអ្វីដែលលោកបញ្ជាក់ថា លោកគ្មានសិទ្ធិដើរហើរដោយសេរីនោះដែរឬទេ?

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ ជាការពិត មិនមែនតែជាខ្ញុំ គឺថាទាំងអស់គ្នា គឺគ្មានសិទ្ធិដើរហើរទេ។

[១០:១៤:៣៧]

**ស៖** ហើយនៅក្នុងអារម្ភកថារបស់លោក ត្រង់ទំព័រដដែល ដែលខ្ញុំបាននិយាយ បុព្វយោគរបស់លោកដដែលនោះ គឺលោកនិយាយថា "សៀវភៅរបស់លោកគ្របដណ្តប់តែក្រុងបាត់ដំបង និងស្រុកពីរក្នុងខេត្តបាត់ដំបង"។ តើដោយសារតែលោកស្ថិតតែក្នុងក្រុងបាត់ដំបង និងស្រុកពីរក្នុងខេត្តបាត់ដំបងនៅក្នុងពេលរបបខ្មែរក្រហមហ្នឹងឬ ទើបលោកធ្វើការសរសេរសៀវភៅគ្របដណ្តប់តែពីរស្រុកហ្នឹងក្រុងបាត់ដំបងនោះ?

**ឆ៖** ពីព្រោះថា ខ្ញុំជំនាន់របបខ្មែរក្រហមខ្ញុំធ្វើការនៅក្នុងក្រុង នៅមន្ទីរពេទ្យពីរក្នុងក្រុង និងធ្វើការនៅមន្ទីរពេទ្យស្រុកមួយ គេហៅថា ស្រុកដូនទាវ ឥឡូវនេះឈ្មោះស្រុកឯកភ្នំបាទ។ ហើយនិងស្រុកមួយទៀតដែលខ្ញុំធ្លាប់ទៅ ស្រុកមោងឫស្សី ប៉ុណ្ណឹង។ ខ្ញុំស្គាល់តែប៉ុណ្ណឹង។ គេឲ្យដើរតែប៉ុណ្ណឹងបាទ។

**ស៖** ប៉ុន្តែនៅក្នុងសៀវភៅរបស់លោកមិនមានកន្លែងណាមួយដែលបញ្ជាក់ ហើយសក្ខីកម្មរបស់លោកក៏មិនបាននិយាយដែរថា តើលោកធ្លាប់ចូលរួមក្នុងការប្រជុំ ឬមួយក៏ការប្រជុំថ្នាក់ខ្ពស់ដែលធ្វើការពិភាក្សាអំពីបញ្ហានយោបាយនោះ? តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវឬទេ ដែលលោកមិនដែលចូលរួមការប្រជុំ ឬក៏ការប្រជុំថ្នាក់លើដែលធ្វើការសម្រេចទៅលើនយោបាយនានានោះ?

[១០:១៦:២៩]

**ឆ៖** ខ្ញុំគ្រាន់តែជាគ្រូពេទ្យម្នាក់ដែលគេហៅទៅធ្វើការនៅមន្ទីរពេទ្យស្រុក បន្ទាប់មកនៅមន្ទីរពេទ្យថ្នាក់តំបន់យោធា ព-២ ហើយនិងមន្ទីរពេទ្យស៊ីវិល ព-១។ ខ្ញុំទៅធ្វើការនោះពុំមានជាគ្រូពេទ្យស្រុក -- ខ្ញុំបាទអនុញ្ញាត បកប្រែអាចច្រឡំ។ ខ្ញុំចង់និយាយថា ខ្ញុំធ្វើការមិនមែនជាគ្រូពេទ្យថ្នាក់ខ្ពស់ទេ។ ខ្ញុំគ្រាន់តែអាច ខ្ញុំអាចគ្រាន់តែថាជាទៅធ្វើការក្នុង -- ខ្ញុំដឹងខ្លួនថា ខ្ញុំគ្រាន់តែជាអ្នកទោសនយោបាយមួយប៉ុណ្ណោះ ឬមួយជាថ្នាក់បុគ្គលិកថ្នាក់ទាបបំផុតនៅក្នុងចំណោមបុគ្គលិកពេទ្យខ្មែរក្រហម។ មិនមែនខ្ញុំជាអ្នកធំទេ។ ដូច្នេះ ខ្ញុំគ្មានតួនាទីនយោបាយអ្វីទាំងអស់ អ្វីទេ។

**ស៖** តាមអ្វីដែលខ្ញុំស្តាប់ឮនៅថ្ងៃនេះ ហើយប្រហែលជាលោកបានសរសេរផងដែរ នៅក្នុងសៀវភៅរបស់លោក គឺពីឆ្នាំ៧៥ ដល់៧៩ លោកមិនបានបំពេញតួនាទី ដូចអ្វីដែលលោកបានធ្វើពីមុននោះឡើយ។ បានន័យថា នៅក្នុងរបបខ្មែរក្រហមលោកមិនត្រូវបានគេចាត់ទុកថាជាវេជ្ជបណ្ឌិតនោះឡើយគ្រាន់តែជាអ្នកជំនួយ ឬក៏ជាអ្នកព្យាបាលតែប៉ុណ្ណោះ។ តើខ្ញុំយល់អ៊ីចឹងវាត្រឹមត្រូវដែរឬទេ?

[១០:១៨:១២]

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយ!

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ លោកនិយាយអ៊ីចឹងត្រឹមត្រូវហើយ។ គ្រាន់តែខ្ញុំបន្ថែមថា ខ្ញុំៗជា គេហៅទៅធ្វើការជាជំនួយ ហើយខ្ញុំជាអ្នកទោស ដូចជាអ្នកទោសមួយដែរ ហើយក៏ជាបុគ្គលិកថ្នាក់ក្រោមមួយដែរ ដែលមិនដឹងថាអ្វីនឹងកើតឡើងចំពោះមុខ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** បាទ អរគុណ។ តាមខ្ញុំយល់អ្វីដែលលោកនិយាយថ្ងៃនេះ និងអ្វីដែលលោកទើបតែបានឆ្លើយនុំងគឺ គេមិនដែលអញ្ជើញលោកចូលរួមក្នុងការប្រជុំដែលពិភាក្សាអំពីបញ្ហាសំខាន់ៗ ឬក៏ពិភាក្សាអំពីនយោបាយនានាទេ។ តើត្រឹមត្រូវដែរឬទេ?

[១០:១៩:០៨]

**ឆ៖** បាទ ជាការត្រឹមត្រូវហើយ ពីព្រោះខ្ញុំគ្រាន់ -- ដូចខ្ញុំបានជម្រាបលោកអ៊ីចឹង គ្រាន់តែគេហៅទៅធ្វើការជាជំនួយ ជាអាចជាអ្នកទោស ឬមួយជាបុគ្គលិកទាបបំផុត ប៉ុណ្ណឹង។

**ស៖** អរគុណ។ ប៉ុន្តែថ្ងៃនេះ លោកបានផ្តល់សក្ខីកម្មថា លោកមិនមានតួនាទីក្នុងការប្រាប់មកយើងថាតើគោលនយោបាយអ្វីដែលត្រូវបានអនុវត្ត អ្វីដែលបានធ្វើនៅក្នុងរបបខ្មែរក្រហមនោះទេ លោកអាចប្រាប់ត្រឹមតែអ្វីដែលលោកចាំ លោកឃើញ បានដឹង គឺលោកមិនមានតួនាទីណាមួយដើម្បីប្រាប់យើងអំពីគោលនយោបាយទេ។

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមបន្តទៅដល់ឆ្នាំ៧៩ នៅក្នុងទំព័រចុងក្រោយបំផុតនៃសៀវភៅរបស់លោក ទំព័រ១៤៥ ភាសាអង់គ្លេស ហើយភាសាខ្មែរមាន 66678941 (ស៊ីក) ដល់ 42 លោកបាននិយាយដូចតទៅនេះ "ខ្ញុំធ្វើជាប្រធានមន្ទីរខេត្តបាត់ដំបងពីឆ្នាំ៧៩ ដល់១៩៨៦ និងជាប្រធានសុខាភិបាលខេត្តបាត់ដំបងចាប់ពីឆ្នាំ១៩៨៦ ដល់ឆ្នាំ១៩៩២"។ ខ្ញុំគិតថាលោកនឹងនៅរក្សាចម្លើយរបស់លោកដដែល គឺអ្វីដែលលោកបានសរសេរនៅក្នុងសៀវភៅនេះ។

[១០:២១:០៧]

**ឆ៖** បាទជាការពិត។ នៅឆ្នាំក្រោយការរំលំរបបខ្មែរក្រហម ខ្ញុំមកធ្វើការនៅមន្ទីរខេត្តបាត់ដំបង

វិញ ខ្ញុំធ្វើជាប្រធានមន្ទីរពេទ្យខេត្តបាត់ដំបងរហូតដល់ឆ្នាំ១៩៨៦។ បន្ទាប់មក ខ្ញុំបានត្រូវតែងតាំងជាប្រធានសុខាភិបាលខេត្តបាត់ដំបងរហូតដល់ឆ្នាំ១៩៩២។ បន្ទាប់មក ខ្ញុំត្រូវផ្លាស់មកធ្វើការនៅក្រសួងសុខាភិបាល។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំមើលទៅឃើញថា គេតែងតាំងលោកទៅកាន់តួនាទីទាំងនោះដោយរបបថ្មី ឬក៏ដោយពួកវៀតណាមដែលដឹកនាំប្រទេសនៅពេលនោះ ប៉ុន្តែលោកមិនបញ្ជាក់ឲ្យច្បាស់នៅត្រង់ចំណុចនេះក្នុងសៀវភៅរបស់លោក។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** គឺរដ្ឋអំណាចកម្ពុជា គឺរដ្ឋាភិបាលកម្ពុជាតែងតាំងខ្ញុំ។ ពុំមែនវៀតណាមទេបាទ។

**ស៖** អរគុណ។ ប៉ុន្តែក្នុងសៀវភៅរបស់លោក លោកក៏បានរៀបរាប់ផងដែរ អំពីការដែលវៀតណាមគ្រប់គ្រងស្ថានភាពនៅក្នុងប្រទេសកម្ពុជា។ តើអ៊ីចឹងមែនឬទេ?

**ឆ៖** នេះជាការធម្មតា គឺថាមានជំនាញការវៀតណាមនៅតាមមន្ទីរនានាបាទ។

**ស៖** សូមអរគុណ។ ថាតើដោយសារតែតួនាទីរបស់លោក ឬក៏វៀតណាម ឬក៏រដ្ឋាភិបាលកម្ពុជាដែលធ្វើឲ្យលោកសរសេរនៅក្នុងសៀវភៅរបស់លោកថា នៅក្នុងឆ្នាំ១៩៨៦ ប៉ុន្មានឆ្នាំក្រោយការដួលរលំរបស់របបខ្មែរក្រហមទៅឲ្យវៀតណាម គេបញ្ជូនលោកទៅប្រទេសវៀតណាមដើម្បីធ្វើការរៀនសូត្រនយោបាយដុសលាងខួរក្បាល។ តើអ្នកណាបញ្ជូនលោកទៅ រដ្ឋាភិបាលកម្ពុជា ឬក៏វៀតណាម?

[១០:២៣:៤២]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថាវីក៖**

លោកប្រធាន យើងមិនជំទាស់នៅពេលដំបូងដោយសារតែយើងចង់ឲ្យមេធាវីការពារក្តីបញ្ជាក់អំពីការទាក់ទង ប៉ុន្តែខ្ញុំគិតថា វាហាក់ដូចជាមិនសមស្របទាល់តែសោះ ដែលយើងលើកយកបញ្ហានេះមកនិយាយទាក់ទងនឹងវៀតណាម ដោយសារតែវានៅក្រៅវិសាលភាពនៃសវនាការរបស់យើង។

ដូច្នេះ នេះខ្ញុំដោយសារមូលហេតុដែលក្រៅវិសាលភាព ខ្ញុំទើបធ្វើការជំទាស់។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំរីករាយទៅលើបញ្ហាទាំងអស់នេះ។ ប៉ុន្តែខ្ញុំគិតថាវាពាក់ព័ន្ធ ព្រោះគាត់បានបង្ហាញខ្លួនគាត់ផ្ទាល់ ថាគាត់មិនមានកំណត់ត្រានោះឡើយ គាត់សរសេរសៀវភៅ២៥ឆ្នាំក្រោយមក ហើយគាត់បញ្ជាក់

ផងដែរថានៅពេលនោះ គឺគេតែងតាំងគាត់ដោយមានតួនាទីខ្ពស់ គឺរដ្ឋាភិបាលដែលមានវៀតណាមជាអ្នកណែនាំ ហើយក្រោយមក គេបញ្ជូនគាត់ទៅរៀនសូត្រនយោបាយដុសលាងខួរក្បាលនៅវៀតណាម។ ហើយដូច្នេះហើយ យើងដឹងហើយថាអ្នកណាដែលត្រូវបានគេដុសលាងខួរក្បាល គឺគ្មានតួនាទី ឬក៏គ្មានលទ្ធភាពអ្វីដែលអាចមកនិយាយអំពីបញ្ហានានានោះឡើយ។ ហេតុដូច្នេះហើយ ទើបយើងចង់បញ្ជាក់ថាអ្វីដែលគាត់ចងចាំនៅរយៈពេល២៥ឆ្នាំក្រោយមកនោះ គឺវាប្រាកដជាប្រឡាក់ប្រឡូស ប្រឡាក់ប្រឡូកដោយសារតែអ្វីដែលគាត់រៀន អ្វីដែលគាត់ទទួល បន្ទាប់ពីមានហេតុការណ៍ខ្មែរក្រហមកើតឡើងនោះហើយ។ ហេតុដូច្នេះហើយទើបយើងសួរសំណួរបែបនេះ។ ប្រសិនបើមិនអនុញ្ញាតឲ្យខ្ញុំសាកសួរពីបញ្ហានេះទេ ខ្ញុំនឹងបន្តទៅមុខទៀត។ ប៉ុន្តែខ្ញុំចង់ឲ្យមានសេចក្ដីសម្រេចពីអង្គជំនុំជម្រះសាលាដំបូង។

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់ និងរបស់តំណាងសហព្រះរាជអាជ្ញាសមស្រប។ បញ្ហានេះអង្គជំនុំជម្រះបានសម្រេចរួចហើយកាលពីថ្ងៃសុក្រមុន។

[១០:២៥:៤០]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ គោលជំហរបស់ខ្ញុំប្រហែលជាប្លែកបន្តិច ប៉ុន្តែខ្ញុំទទួលយកនូវការសម្រេចនេះ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ទាក់ទងទៅនឹងបញ្ហាវៀតណាម ខ្ញុំគិតថាវាពាក់ព័ន្ធ ហើយវាគ្របដណ្ដប់។ ប្រសិនបើយើងមើលទំព័រ ១៤៤ -- ១១៤, ខ្មែរ គឺមានលេខ 00676820 (ស៊ីក) លោកបាននិយាយដូចតទៅនេះ –ខ្ញុំចង់និយាយក្នុងថ្ងៃ ០៦ មករា ១៩៧៩ គឺនៅរយៈពេលភ្លាមៗបន្ទាប់ពីនោះ– គឺថាលោកបានបញ្ជាក់ថា៖ “នៅថ្ងៃបន្ទាប់វិទ្យុកម្ពុជាបានប្រកាសឈ្មោះប្រទេសថ្មី គឺសាធារណរដ្ឋប្រជាមានិតកម្ពុជា ដោយមានកិច្ចព្រមព្រៀងរយៈពេល ២៥ឆ្នាំ ជាមួយនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម។ នៅក្នុងបញ្ហានេះវាធ្វើឲ្យមានការប៉ះពាល់ដល់អារម្មណ៍របស់ខ្ញុំ គោលនយោបាយរបស់ប្រទេសកម្ពុជា ប្រជាជនកម្ពុជាត្រូវបានធ្លាក់ចូលទៅក្នុងអន្លង់នៃស្ថានភាពប្រហាក់ប្រហែលគ្នា គឺវាមិនខុសពីអ្វីដែលយើងថា ចុះទឹកក្រពើ ឡើងលើខ្លានោះឡើយ។ គឺថារបបត្រូវបានដឹកនាំដោយក្រុមពួកកុម្មុយនីស្ត ហើយប្រើប្រាស់របបកុម្មុនិស្តដដែល ដែលគេប្រើប្រាស់ឡើងដើម្បីលេបទឹកដីកម្ពុជា គឺរបបនេះមកជំនួសរបបកុម្មុយនីស្ត

ខ្មែរក្រហម។ តាមពិតទៅស្ថានភាពកម្ពុជានៅក្នុងរបបខ្មែរក្រហមគឺវាហាក់បីដូចជាធ្ងន់ធ្ងរពេកសម្រាប់វៀតណាម។ ប្រសិនបើមិនមានរណសិរ្សរួបរួមជាតិកម្ពុជា វៀតណាមក៏មិនបង្កើតរណសិរ្សសង្គ្រោះជាតិកម្ពុជា ហើយវៀតណាមក៏មិនមានលេសដើម្បីចូលមកឈ្លានពានប្រទេសកម្ពុជាដើម្បីបង្កើតរបបថ្មីបង្កើតជាសាធារណរដ្ឋប្រជាមានិតកម្ពុជា ដើម្បីគ្រប់គ្រងដោយវៀតណាមនោះទេ។ វាហាក់ដូចជាមានការប្លែកគ្នាបន្តិច ប៉ុន្តែអ្វីៗគឺដូចគ្នា។ តើការស្រមើស្រមៃដ៏យូរលង់របស់ ហូជីមិញ អាចក្លាយជាការពិតដែរឬទេ តើកម្ពុជាឈានទៅរកអ្វី? កូនចៅយើងនឹងមានអនាគតភ្លឺថ្លាឬទេ? ហើយសន្ធិសញ្ញា ២៥ឆ្នាំមានន័យយ៉ាងដូចម្តេច? បើវាធ្វើឡើងរវាងអ្នកជួយ និងអ្នកសុំគេជួយដូច្នេះ?” តើលោកចាំថាលោកបានសរសេរនូវឃ្លាទាំងអស់នេះដែរឬទេ?

[១០:២៨:៤៥]

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ ខ្ញុំបានសរសេរឃ្លាទាំងអស់នេះ។

**ស៖** បាទ ឥឡូវនេះយើងពិនិត្យមើលបញ្ហានេះក្នុងរយៈពេលខ្លី ពីព្រោះថា ខ្ញុំមិនចង់ឲ្យលោកពិភាក្សាអ្វីដែលបានកើតឡើងបន្ទាប់ពីអ្វីដែលបានកើតឡើងបន្ទាប់ពីឆ្នាំ១៩៧៥ ដូចជានៅក្នុង ក៥ ប៉ុន្តែខ្ញុំចង់ឲ្យលោកបញ្ជាក់អំពីអ្វីដែលលោកបានសរសេរ ពីព្រោះខ្ញុំមើលឃើញថា នៅទីនេះលោកបាន សួរអំពីបញ្ហាទស្សនវិស័យវែងរបស់ ហូជីមិញ អំពីកម្ពុជា។ លោកនិយាយថា “វៀតណាមលេបត្របាក់ ផ្នែកខ្លះនៃប្រទេសកម្ពុជា”។ តើសុំពន្យល់តុលាការ ថាតើលោកមានអារម្មណ៍ហ្នឹងនៅក្នុងខួរក្បាលរបស់លោកដែលថាលោកទទួលបានការរំដោះ ហើយហេតុអ្វីបានជាចិត្តលោកមានទស្សនៈបែបនេះ?

**ឆ៖** នេះយល់ថាជាការធម្មតាទេ ប្រទេសមួយដែលមានបរទេសចូលមករំលំរបបមួយទៀតគឺដោយសារគេមានមូលហេតុច្បាស់លាស់។ ហើយដូចខ្ញុំក្នុង សរសេរក្នុងសៀវភៅនោះដែរថា “ខ្មែរក្រហម គឺមានទំនាស់ជាមួយវៀតណាម។ ប៉ុន្តែខ្មែរក្រហម ពេលដែលមានទំនាស់ជាមួយវៀតណាមសម្លាប់ប្រជារាស្ត្រឯង”។ ខ្ញុំសរសេរដែរថា “នរណាដែលមិនស្រឡាញ់ប្រទេសកម្ពុជា ប៉ុន្តែនរណាដែលមិនបន់ស្រន់ឲ្យខ្មែរក្រហមរលំរលាយ”។ នេះខ្ញុំបានសរសេរអ៊ីចឹងបាទ។

**ស៖** សូមអរគុណ។ សូមលោកផ្តោតអារម្មណ៍--

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោកមេធាវី តើលោកមានត្រូវការចំណាយពេលប្រហែលប៉ុន្មានទៀតក្នុងការ

 សួរសាក្សីរូបនេះ?

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំអាចនឹងប្រើពេលប្រហែលជា ៧ទៅ ១០មីនុតទៀត ប្រសិនបើខ្ញុំអាចបញ្ចប់នូវសំណួរមួយចំនួនជាមួយលោកសាក្សី ហើយខ្ញុំគិតថា ខ្ញុំអាចថា អាចបញ្ចប់បាន។ ប៉ុន្តែខ្ញុំត្រូវសួរសំណួរបីបួនទៀតទាក់ទងទៅនឹងបញ្ហាដែលខ្ញុំលើកអម្បាញ់មិញនេះបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

[១០:៣១:៣៦]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ឥឡូវនេះខ្ញុំសូមត្រឡប់ទៅក្រោយបន្តិច លោកសាក្សី ខ្ញុំប្រើពាក្យរបស់លោកផ្ទាល់ លោកបាននិយាយពាក្យថា លោកនិយាយថា “ដឹកនាំដោយក្រុមកុម្មុយនីស្តដដែល ហើយគាំទ្រដោយកុម្មុយនីស្ត ដែលបានប្រើ ដែលបានធ្លាប់លេបត្របាក់ទឹកដីកម្ពុជា”។ តើអ្វីជាជំនឿរបស់លោកនៅកាលណោះនៅឆ្នាំ១៩៧៩ ខែមករា ដែលថាវៀតណាមបានលេបត្របាក់ប្រទេសកម្ពុជា ទឹកដីមួយចំនួននៅក្នុងអតីតកាលនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមជំទាស់សំណួរនេះ ដោយសារថាវាមានភាពមិនពាក់ព័ន្ធអ្វីដែលសាក្សីមានអំពីប្រវត្តិកម្ពុជាប្រវត្តិសាស្ត្រវៀតណាមហ្នឹង ក្រោយពីឆ្នាំ១៩៧៩ គឺមិនពាក់ព័ន្ធក្នុងរឿងក្តីនេះទេ ហើយមិនមានគោលបំណងអ្វីសមស្របក្នុងការសាកសួរសាក្សី។ ដូច្នេះយើងខ្ញុំសូមជំទាស់។ ដូច្នេះមេធាវីគប្បីសួរសំណួរផ្សេងទៀតដែលពាក់ព័ន្ធ។ អ៊ីចឹងគឺថាសំណួរនេះមិនមានការពាក់ព័ន្ធក្នុងរឿងក្តី មិនអាចឲ្យសាក្សីបញ្ជាក់ពីភស្តុតាងអ្វីដែលមិនពាក់ព័ន្ធទេ។

[១០:៣២:៤៩]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមអនុញ្ញាតផ្អាកបន្តិច ដើម្បីឲ្យបារាំងគេបកប្រែកើត។ នៅពេលដែលខ្ញុំបញ្ជាក់ថា វាមានការពាក់ព័ន្ធ។ សហព្រះរាជអាជ្ញា ប្រហែលជានៅក្នុងអង្គការសហប្រជាជាតិ ចង់ឲ្យយើងជឿថាមានអ្វីជាវេទមន្តកើតឡើងនៅក្នុងឆ្នាំ១៩៧៥ ខែមករា ហើយនិងខែមករា ឆ្នាំ១៩៧៩ ហើយយើងមិនចង់ដឹងពីអ្វីកើតមុន ឬក្រោយទេ។ ខ្ញុំមិនចាប់អារម្មណ៍ពីអ្វីកើតឡើងក្រោយពីនោះទេ ប៉ុន្តែខ្ញុំចង់ដឹងអ្វីដែលពាក់ព័ន្ធទៅនឹងប្រវត្តិសាស្ត្រ។ ប៉ុន្តែអំពីអំណាចដែលពាក់ព័ន្ធទៅនឹងការបង្កើតរបបនោះ ខ្ញុំក៏មិនពាក់ព័ន្ធដែរ។ ប៉ុន្តែបញ្ហាដែលខ្ញុំចង់ដឹងហ្នឹងគឺថា ដែលអាចនឹងកើតឡើងនៅក្នុងសវនាការនេះ ដែលយើងចង់ដឹង គឺថាគឺវាមានការភ័យខ្លាចពីវៀតណាម អំពីទស្សនៈដំបូង តាំងពីឆ្នាំ១៩៧៥ របស់ខ្មែរក្រហម ឬក៏មុននឹងមកផងដែរ។ គឺមានការភ័យខ្លាចថា វៀតណាមមានការប៉ុនប៉ង និងធ្វើអ្វីនោះ។

[១០:៣៣:៥៥]

សាក្សីរូបនេះ គាត់មិនមែនជាកម្មាភិបាលខ្មែរក្រហមទេ គាត់ប្រាប់តុលាការថា ថាគាត់ៗបានទៅរៀននយោបាយ ហើយគាត់បាននិយាយពីផែនការយូរអង្វែងរបស់ ហូជីមិញ គាត់សរសេរសៀវភៅ ហើយគាត់និយាយអំពីថា អតីតកាលវៀតណាមបានលេបត្របាក់កម្ពុជា។ នៅពេលដែលយើងនិយាយអំពីបញ្ហានេះ ដែលយើងសួរដែលថា ការពាក់ព័ន្ធរបស់វៀតណាម ឬក៏ការភ័យខ្លាចរបស់ខ្មែរក្រហមអំពីវៀតណាម ហើយនិងអង្គហេតុដែលកើតឡើងនោះ យើងត្រូវពិនិត្យមើលនៅក្នុងបរិបទប្រវត្តិសាស្ត្រ។ ដូច្នេះ វិចារបុគ្គលគឺទទួលស្គាល់ថា នេះគឺជាការភ័យខ្លាចបែបប្រវត្តិសាស្ត្រមួយរបស់ខ្មែរ ហើយបើយើងយល់ថា មិនពាក់ព័ន្ធ មិនឲ្យយើងលើកឡើងហ្នឹង តើហេតុអ្វីបានជារបបខ្មែរក្រហមក្នុងកម្រិតណាមួយដែលអាចនឹងអះអាង ជារឿងដែលថា វៀតណាម ចង់បានទឹកដី ចង់លេបទឹកដីខ្មែរ ចង់មានមហិច្ឆតានយោបាយ ឬក៏ទឹកដីនៅកម្ពុជា? ហេតុអ្វីបានជាខ្មែរក្រហមនិយាយអ៊ីចឹង?

ខ្ញុំយល់ថា វាមានការពាក់ព័ន្ធ។ ដូច្នេះហើយ ខ្ញុំចង់បានការអនុញ្ញាត ដើម្បីឲ្យសួរ ដើម្បីឲ្យដឹងថាយើងដឹងថា ហេតុអ្វីបានជារឿងក្តីនេះស្ថិតនៅក្នុងពិភពមួយវាបិទ ហើយក៏វាមានតក្កភាព វាមានសមហេតុផលរបស់វាផងដែរ។

[១០:៣៥:១២]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣៥:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា សមស្រប។ សំណួរនេះមិនពាក់ព័ន្ធទេ។ សូមមេធាវីតាំងសំណួរថ្មីបន្ត។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ មុននឹងខ្ញុំចូលទៅចំណុចមួយទៀត នឹងអង្គុយចុះ ខ្ញុំសូមឲ្យមានការបំភ្លឺអំពីអង្គជំនុំជម្រះសាលាដំបូងថា តើនេះជាសេចក្តីសម្រេចថា សហព្រះរាជអាជ្ញាអាចនិយាយអំពីភស្តុតាងទាក់ទងទឹងវៀតណាម ប៉ុន្តែមេធាវីការពារក្តី គឺមិនត្រូវបានអនុញ្ញាតឲ្យនិយាយទេ។ ក្នុងការ -- ប្រសិនបើការសម្រេចបែបនោះ គឺថាក្រៅពីការប្រើស្តង់ដារពីរនៅទីនេះ គឺបានបង្ហាញឲ្យយើងឃើញថា មេធាវីការពារក្តីមិនត្រូវបានអនុញ្ញាតឲ្យកត់ត្រាត្រឹមត្រូវរបស់តុលាការ ហើយមិនអាចអះអាងអំពីអង្គហេតុ ឬក៏ភស្តុតាងទាក់ទងទៅនឹងបរិបទនយោបាយទេ -- ប្រវត្តិសាស្ត្រទេ។ អ៊ីចឹងខ្ញុំចង់បានការបំភ្លឺ តើទាក់ទងទៅសាក្សីរូបនេះ ឬក៏ថាការសម្រេចនេះ គឺជាការហាមប្រាមចាប់ពីនេះរហូតទៅ គឺថាមេធាវីការពារក្តីមិនអាចនិយាយពីអ្វីទាក់ទងទៅនឹងវៀតណាម? អំពីអាកប្បកិរិយា មុន ក្រោយ ក្នុងពេលដែលប្រព្រឹត្តឡើងក្នុងការសម្លាប់ ដែលយើងសង្ស័យ ដែលថាប្រជាជនសាមញ្ញដឹងអំពីវៀតណាមនោះ ដែលអាចនឹងឆ្លុះបញ្ចាំងអំពីការសង្ស័យរបស់ខ្មែរក្រហម ហើយខ្ញុំចង់ដឹងការសម្រេចរបស់អង្គជំនុំជម្រះនៅពេលនេះ។ បន្ទាប់ពីនោះមកខ្ញុំនឹងសូមអនុញ្ញាតអង្គុយចុះ។

[១០:៣៧:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣៧:៥៥]

**ប្រធានអង្គជំនុំ៖**

យើងសម្រេចរួចហើយ។ ហើយយើងសម្រេចនេះទៅតាមករណីជាក់លាក់នៃសំណួរនីមួយៗដែលសួរ។ ហើយដែលមានការជំទាស់យ៉ាងជាក់លាក់ ហើយអង្គជំនុំជម្រះក៏យល់ផងដែរថា សាក្សីរូបនេះ គឺសាក្សីមិនមែនអ្នកជំនាញប្រវត្តិសាស្ត្រទេ។ កាលពីអង្គជំនុំជម្រះកំណត់យកសាក្សីនេះមកធ្វើសវនាការក្នុងគោលបំណងស្តាប់សក្ខីកម្មដែលគាត់បានដឹង បានឮ បានឃើញដោយផ្ទាល់នូវអង្គហេតុនៃការអនុវត្តគោលនយោបាយជម្លៀស ហើយនិងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មូលដ្ឋាន។ ហើយប្រហែលជា

ពិនិត្យមើលលើអ្វីដែលយើងបានកំណត់ក្នុងណែនាំដំបូងៗនៃកិច្ចពិភាក្សាដេញដោល គឺយើងបានជម្រាបទៅភាគីរួចអំពីបញ្ហានេះ។ ដូច្នេះ អង្គជំនុំជម្រះមិនសម្រេចបញ្ហានេះទៀតទេ ហើយមិនមែនស្រេចតែលោកយល់ទេ។ ប៉ុន្តែយើងសម្រេចទៅតាមសំណួរដែលសួរ ហើយមានការជំទាស់យ៉ាងជាក់ច្បាស់ទៅតាមសំណួរនីមួយៗ។ យើងដោះស្រាយទៅតាមករណីនៃសំណួរនីមួយៗដែលកើតមានចំពោះមុខយើងនេះ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ មុននឹងខ្ញុំអង្គុយចុះ ខ្ញុំសូមជម្រាបថា សហព្រះរាជអាជ្ញាបានសួរសំណួរដែលចូលទៅផ្នែកមួយទៀត ដែលចាត់ទុក គាត់ថាជាសាក្សីនោះ។

**ប្រធានអង្គជំនុំ៖**

អស់ពេលហើយណ៎ះ!

បាទ ឥឡូវនេះដល់ពេលវេលាសម្រាកដែរហើយ ហើយកិច្ចពិភាក្សាដេញដោលចំពោះសាក្សីរូបនេះក៏ដល់ពេលបានចប់ហើយដែរ។

អង្គជំនុំជម្រះសូមអរគុណលោក ហ៊ុន ឈុនលី ការស្ដាប់សក្ខីកម្មរបស់លោករហូតមកដល់ពេលនេះ បានចប់ហើយ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ។ លោក ហ៊ុន ឈុនលី សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោក ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ ហើយសូមលោកជួបតែសំណាងល្អ មានសេចក្ដីសុខសេចក្ដីចម្រើន ធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជានឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់ចង់ទៅវិញចុះ។ លោក ហ៊ុន ឈុនលី អាចចាកចេញពីបន្ទប់សវនាការ វិលទៅវិញបានហើយ។ ជាបន្តអង្គជំនុំជម្រះសាលាដំបូងនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-307។

ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤០នាទី ដល់ម៉ោង ១១:០០ នាទី)*

[១១:០១:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

មន្ត្រីរដ្ឋបាលសូមអញ្ជើញសាក្សីដែលមានរហស្សនាម TCW-703 និងមេធាវីប្រឹក្សារបស់គាត់ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(សាក្សីចូលមកកាន់បន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកសាក្សី តើលោកឈ្មោះអី?

លោករង់ចាំមើលក្បាលមីក្រូហ្វូនដែលមានភ្លើងសញ្ញាក្រហម មានន័យថា វាចាប់ផ្ដើមធ្វើប្រតិបត្តិការសូមលោកនិយាយ។ ឆ្លើយម្ដងទៀត!

**លោក ផាន វ៉ាន៖**

**ផ៖** ខ្ញុំបាទ ឈ្មោះ ផាន វ៉ាន។

**ស៖** ក្រៅពីឈ្មោះ ផាន វ៉ាន តើលោកមានឈ្មោះអ្វីផ្សេងទៀតដែរឬទេ?

**ផ៖** ឈ្មោះដើម ឈ្មោះ ខាំ ផាន់។

**ស៖** បាទអរគុណ។ ហើយសព្វថ្ងៃនេះ តើលោកប្រើប្រាស់អីឈ្មោះអីពិតប្រាកដ?

**ផ៖** ឈ្មោះ ផាន វ៉ាន បាទ។

**ស៖** លោក ផាន វ៉ាន តើលោកមានអាយុប៉ុន្មានហើយ?

**ផ៖** ៥៣ បាទ។

**ស៖** តើសព្វថ្ងៃនេះលោកមានទីលំនៅនៅកន្លែងណា?

**ផ៖** នៅម៉ាឡៃបាទ។

**ស៖** បាទអរគុណ ហើយលោកប្រកបរបររកស៊ីធ្វើអី?

**ឆ៖** ធ្វើចម្ការបាទ។

**ស៖** ឪពុកបង្កើតរបស់លោក គាត់ឈ្មោះអី?

[១១:០៤:០៥]

**ឆ៖** ឈ្មោះ ឡាំង។

**ស៖** លោកស្គាល់នាមត្រកូលទេ តើគាត់ប្រើត្រកូលអី?

**ឆ៖** អត់ស្គាល់ត្រកូលទេបាទ។

**ស៖** ចុះម្ដាយបង្កើតរបស់លោកគាត់ធ្វើអី?

**ឆ៖** ម៉ែឈ្មោះ ខាំ កន។

**ស៖** ចុះប្រពន្ធរបស់លោកគាត់ឈ្មោះអី?

**ឆ៖** ហ៊ុន ឆវី។

**ស៖** លោកមានកូនប៉ុន្មាននាក់?

**ឆ៖** មានកូនបីនាក់។

**ស៖** លោក អ៊ីចឹងគឺយើងប្រើឈ្មោះជាផ្លូវការរបស់លោកដែលលោកប្រើសព្វថ្ងៃគឺឈ្មោះ ផាន វ៉ាន អ៊ីចឹងណេះ?

**ឆ៖** បាទ ឈ្មោះ ផាន វ៉ាន។

**ស៖** លោក ផាន វ៉ាន តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញនេះថា តាមសមត្ថភាពដែលលោកអាចដឹងលោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីនេះទេ ហើយក៏មិនជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទដែរ តើពិតមែនដែរឬទេ?

**ឆ៖** ពិតបាទ។

**ស៖** ហើយរបាយការណ៍ដដែលថា លោកបានស្បថរួចហើយមុននឹងចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ តើពិតមែនដែរឬទេ?

**ឆ៖** ពិតបាទ។

[១១:០៥:៥៦]

**ស៖** លោក ផាន វ៉ាន ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះលោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬក៏ការធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនឆ្លើយសក្ខីកម្ម -- មិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មានន័យថាដោយសារចម្លើយ ឬក៏អំណះអំណាងរបស់លោក នាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។ អំពីករណីក្នុងនាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកត្រូវតែឆ្លើយទៅនឹងសំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ហើយលោកជាសាក្សីត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលខ្លួនលោកបានឃើញ បានដឹង បានឮ បានចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬការធ្វើសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ តើលោកយល់ទេ?

**ផ៖** យល់បាទ។

**ស៖** លោក ផាន វ៉ាន តើលោកចេះអក្សរទេ?

**ផ៖** ចេះអានបាន សរសេរបានខ្លះ។

[១១:០៧:៥០]

**ស៖** អក្សរខ្មែរ?

**ផ៖** អានបាន សរសេរបានបាទ។

**ស៖** បាទ អរគុណ។ លោក ផាន វ៉ាន តើលោកធ្លាប់ផ្តល់នូវកិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេក្នុងអំឡុងពេលប៉ុន្មានឆ្នាំមុននេះ?

**ផ៖** ធ្លាប់បាទ។

**ស៖** លោកផ្តល់បទសម្ភាសន៍ប៉ុន្មានដងដែរ? ហើយធ្វើនៅទីកន្លែងណា? នៅពេលវេលាណាលោកចងចាំទេ?

**ផ៖** បីដង នៅម៉ាឡៃ។

**ស៖** លោកចាំថានៅខែឆ្នាំណាដែរឬទេ លើកទី១ លើកទី២ និងលើកទី៣?

**ផ៖** មើលឯកសារ--

**ស៖** លោកចាំថាលោកចាំ បើលោកមិនចាំ មិនចងចាំទេ លោកថាមិនចងចាំក៏បានដែរ។

[១១:០៩:០០]

**ឆ៖** អត់ចាំថ្ងៃបាទ។

**ស៖** បាទ អរគុណ។ ហើយមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើលោកបាន ពិនិត្យមើល ឬក៏បានអាន ឬក៏ស្តាប់ការអានរបស់អ្នកណាម្នាក់នូវកំណត់ហេតុស្តាប់ចម្លើយរបស់លោក ដែលបានធ្វើជាមួយអ្នកស៊ើបអង្កេត ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** អត់បានអានឡើងវិញទេបាទ។

**ស៖** ចុះមានអ្នកណាអានឲ្យលោកស្តាប់ដែរឬទេ?

**ឆ៖** មានលោកមេធាវីបាទ។

**ស៖** តាមសមត្ថភាពដែលលោកអាចដឹង តើលោកអាចបញ្ជាក់បានដែរឬទេថា កំណត់ហេតុស្តាប់ចម្លើយរបស់លោក ដែលលោកបានស្តាប់ការអានឲ្យស្តាប់ដោយមេធាវីប្រឹក្សាសាក្សី ដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹមត្រូវ ឬក៏ស៊ីសង្វាក់គ្នា ឬក៏ស្របគ្នាទៅនឹងចម្លើយរបស់លោក ដែលលោកបានផ្តល់កិច្ចសម្ភាសន៍បីដងលើកមុនដែរឬទេ?

**ឆ៖** សមស្របគ្នាបាទ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណ។

អង្គជំនុំជម្រះសូមជម្រាបតំណាងសហព្រះរាជអាជ្ញាថា ក្នុងកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលស្តាប់សក្ខីកម្មរូបនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។ ហើយក៏សូមរំឭកផងដែរថា ទាំងសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានពេលពេលវេលាមួយថ្ងៃក្នុងការសួរដេញដោលដល់សាក្សីរូបនេះ។

[១១:១១:០៦]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំឈ្មោះ វាំងសង់ ខ្ញុំតំណាងឱ្យការិយាល័យសហព្រះរាជអាជ្ញា ខ្ញុំនឹងសួរសំណួរនៅថ្ងៃនេះរហូតដល់ចប់ពេលថ្ងៃត្រង់ ហើយស្អែកព្រឹកខ្ញុំនឹងសួរបន្តទៅទៀត។ ហើយបន្ទាប់មកទៀត មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងសួរបន្តពីខ្ញុំប្រហែលជា១ម៉ោង។

ក្នុងមួយព្រឹកនេះ ខ្ញុំសូមឱ្យលោកឆ្លើយដោយបានច្បាស់ៗ ខ្លីៗ ទៅនឹងសំណួរដែលខ្ញុំចោទសួរ ហើយប្រសិនបើលោកមិនយល់សំណួរ សូមលោកបញ្ជាក់ថាលោកមិនយល់។ ដើម្បីជួយលោកនោះ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំនឹងសួរទៅកាន់លំដាប់កាលប្បវត្តិ ទៅតាមហេតុការណ៍ដែលលោកបានឃើញ លោកបានឆ្លងកាត់ ឬក៏ហេតុការណ៍ដែលលោកបានស្តាប់ឮ គឺមុនពេលឆ្នាំ៧០ រហូតទៅដល់ពេលបញ្ចប់របបខ្មែរក្រហម។ ជាបឋម ខ្ញុំនឹងសួរសំណួរមួយចំនួនពាក់ព័ន្ធនឹងរយៈពេលមុនឆ្នាំ១៩៧០។ តើលោកអាចបញ្ជាក់បានទេ មុនឆ្នាំ៧០នេះ តើលោករស់នៅខេត្តណាដែរ?

**លោក ផាន វ៉ាន៖**

**ផ៖** មុន៧០ ខ្ញុំនៅខេត្តមណ្ឌលគីរី។

**ស៖** តើលោករៀនសរសេរ និងរៀនអាននៅទីណានៅក្នុងភូមិ ឬក៏នៅក្នុងព្រៃ ឬក៏នៅកន្លែងផ្សេងទៀត?

**ផ៖** រៀននៅក្នុងព្រៃបាទ។

[១១:១៣:១៤]

**ស៖** ហេតុអ្វីបានជានៅពេលនោះ លោកទៅរៀននៅក្នុងព្រៃ ហើយលោកនៅក្នុងព្រៃនោះនៅជាមួយអ្នកណាដែរ?

**ផ៖** នៅជាមួយឪពុកម្តាយ។

**ស៖** តើលោកអាចជម្រាបយើងបានទេថា ហេតុអ្វីបានជានៅមុនឆ្នាំ៧០ ឪពុកម្តាយរបស់លោកនៅក្នុងព្រៃនោះ តើពួកគាត់ធ្វើអ្វីដែរ?

**ផ៖** គាត់រត់ចូលព្រៃ។

**ស៖** សូមអរគុណ។ ខ្ញុំសូមឱ្យលោកផ្តល់ព័ត៌មានលម្អិតបន្ថែមទៅនឹងសំណួរដែលខ្ញុំចោទសួរនេះ។ ខ្ញុំចង់ដឹងថា ហេតុអ្វីបានជាឪពុកម្តាយរបស់លោករត់ទៅនៅក្នុងព្រៃ?

**ឆ៖** ខ្ញុំនៅក្មេង អត់ដឹងរឿងអីដែរ គ្រាន់តែតែថា ដឹងថារត់ចូលព្រៃអីអ៊ីចឹង។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្វាឯល៖**

លោកប្រធាន ខ្ញុំសូមអានសម្រង់នៃចម្លើយរបស់សាក្សីដែលបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺឯកសារលេខ E3/58 គឺនៅទំព័រទី២ នៃភាសាខ្មែរ អង់គ្លេស និងបារាំង។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីផ្តល់កំណត់ហេតុទាំងបីជូនសាក្សី ដើម្បីឲ្យគាត់មានជាឯកសារយោងសម្រាប់ពេលដែលខ្ញុំ -- ធ្វើការយោង ហើយក្រឡាបញ្ជីអាចបញ្ជាក់ជូនគាត់បានថា នៅកន្លែងណាថាខ្ញុំចង់សួរនោះ។ ហើយម្យ៉ាងទៀត ខ្ញុំសូមការអនុញ្ញាតពីលោកប្រធានផងដែរក្នុងការបង្ហាញឯកសារខ្មែរជាភាសាខ្មែរទំព័រ២ នៅលើអេក្រង់គឺ ឯកសារ E3/58។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

[១១:១៥:៥១]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្វាឯល៖**

**ស៖** ឯកសារនេះ គឺជាកំណត់ហេតុស្តាប់ចម្លើយរបស់លោកដែលចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨ នៅទំព័រ២ លោកបានឆ្លើយថា ខ្ញុំសូមដកស្រង់ "មុនឆ្នាំ១៩៧០ ខ្ញុំបានរៀនអក្សរនៅក្នុងព្រៃ ត្រង់ម្តុំអូរតាង អូរលាវ ក្នុងខេត្តរតនគិរីជិតព្រំដែនវៀតណាម។ នៅពេលនោះ ខ្ញុំនៅក្មេងដែលទៅរស់នៅតាមឪពុកម្តាយនៅក្នុងព្រៃ។ អ្នកដឹកនាំនៅក្នុងព្រៃនោះមានឈ្មោះដូចជា តាយ៉ា, តាវ៉ង់ ហៅ វី, តាថងស៊ី ស្លាប់ក្រោយវៀតណាមចូលឆ្នាំ៧៩, តាឡាំង (ឪពុករបស់ខ្ញុំ)" សូមបញ្ចប់ការដកស្រង់។ តើលោកមាននៅចងចាំទេ អំពីចម្លើយរបស់លោកនេះ ហើយលោកអាចជម្រាបបានទេថាតើ តាឡាំង, តាយ៉ា, តាវ៉ង់ ហៅ វី, តាថងស៊ី នោះ គាត់ស្ថិតក្នុងចលនាតស៊ូនយោបាយ?

[១១:១៧:០៣]

**លោក ផាន វ៉ាន៖**

**ឆ៖** នៅចងចាំ។ គាត់ជាកម្មាភិបាលអ្នកតស៊ូកាលជំនាន់ហ្នឹង ខ្ញុំដឹងតែប៉ុណ្ណឹង។ រួមទាំងឪពុកខ្ញុំ។

**ស៖** សូមអរគុណ។ តើលោកដឹងទេថា នៅក្នុងចលនាតស៊ូមុនឆ្នាំ១៩៧០នោះ ឪពុកលោកមានតួនាទីអ្វីដែរ?

**ឆ៖** កាលជំនាន់ហ្នឹងខ្ញុំអត់ៗដឹងទេ ខ្ញុំនៅក្មេង។

**ស៖** ចុះនាពេលក្រោយមកនោះ ឪពុករបស់លោកមានបានប្រាប់លោកទេថា គាត់ធ្វើអ្វីនៅក្នុងចលនាតស៊ូហ្នឹង?

**ឆ៖** ក្រោយមកដឹងថា គាត់នៅលេខាតំបន់ដូចខ្ញុំបានជម្រាបតាមឯកសារហ្នឹង។

[១១:១៨:២៤]

**ស៖** បាទ សូមអរគុណ។ ខ្ញុំនិយាយនៅមុនឆ្នាំ១៩៧០ នៅពេលដែលលោកនៅក្មេងនៅក្នុងព្រៃក្នុងខេត្តរតនគិរី តើលោកមានធ្លាប់ជួប ប៉ុល ពត, អៀង សារី, ខៀវ សំផន ឬ មេដឹកនាំផ្សេងទៀតនៃចលនាតស៊ូនៅក្នុងខេត្តរតនគិរីដែរឬទេ គឺខ្ញុំសំដៅដល់មុនឆ្នាំ១៩៧០?

**ឆ៖** ដូចអត់ទេ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចូលទៅដល់រយៈពេលពាក់កណ្ដាលឆ្នាំ៧០ រហូតទៅដល់ចុងឆ្នាំ១៩៧៣ ឬក៏ដើមឆ្នាំ១៩៧៤។ លោកបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា "លោកធ្វើការ និងរស់នៅប-២០"។ តើលោកអាចបញ្ជាក់ជូនបានទេថា នៅចន្លោះឆ្នាំ៧០ និង៧៣ នោះ ប-២០ មានទីតាំងនៅឯណាដែរ?

[១១:១៩:៤៧]

**ឆ៖** ខ្ញុំចាំអត់ច្បាស់ទេ។ ដូចខ្ញុំបានជម្រាបខាងដើមហើយ តាមរយៈសហព្រះរាជអាជ្ញាដែលសួរខ្ញុំហ្នឹង។ ដឹងថា ជិតម្ដុំគីឡូ១០ ជិតគីឡូ១០ គីឡូអីហ្នឹង។

**ស៖** បាទសូមអរគុណ។ គោលបំណងនៃសវនាការនេះ គឺថាធ្វើយ៉ាងណាឲ្យលោកឆ្លើយអ្វីដែលលោកបានដឹង អំពីហេតុការណ៍ដែលបានកើតឡើងនៅសម័យនោះ។ នៅពេលដែលលោកនិយាយថានៅជិតបង្គោលគីឡូម៉ែត្រលេខ១០នោះ តើថាជិតខេត្តណា ជិតក្រុងណាដែរ មន្ទីរប-២០នុំង?

**ឆ៖** ខ្ញុំចាំអត់ច្បាស់ដែរ។

**ស៖** សូមអរគុណ។ ខ្ញុំនឹងអាននូវសម្រង់នៃកំណត់ហេតុស្ដាប់ចម្លើយរបស់លោក គឺលេខ E3/58 ដើម្បីរំឭកការចងចាំរបស់លោក គឺសំណួរទី១ដែលគេបានសួរនៅពេលស្ដាប់ចម្លើយលោក គឺនៅទំព័រទី២ ជាភាសាខ្មែរ ទីព័រទី២ជាភាសាបារាំង និងទំព័រទី២ ជាភាសាអង់គ្លេស ទី៣ -- ទី២ និងទី៣ ជាភាសាអង់គ្លេស។

[១១:២១:២៦]

លោកឆ្លើយនៅក្នុងឯកសារនោះថា “មន្ទីរប-២០ជិតគីឡូលេខ១០ ជិតបឹងកេត ប្រហែលជានៅក្នុងស្រុកស្ទឹងត្រង់ខេត្តកំពង់ចាម”។ តើលោកមាននឹកឃើញពាក់ព័ន្ធទៅនឹងទីតាំងប-២០ទេនៅពេលនេះ? តើពិតជានៅក្នុងស្រុងស្ទឹងត្រង់មែនទេ ឬក៏ប្រហែលជានៅក្នុងស្រុកទុំងទេ?

**ឆ៖** ប្រហែលបាទ ប្រហែលក្នុងស្រុកហ្នឹង។

**ស៖** លោកបានឆ្លើយថា លោកបានរស់នៅប-២០។ តើលោកបានរៀនទេនៅទីនោះ ហើយរៀនផងធ្វើការទេ -- ផងទេនៅពេលនោះ?

**ឆ៖** រៀនបាទ រៀនផងធ្វើការផង។

**ស៖** សូមអរគុណ។ តើនៅពេលនោះ លោកធ្វើអ្វីដែរ?

**ឆ៖** កាលហ្នឹងគេហៅរត់នីរសារ។

**ស៖** បាទសូមអរគុណ។ មុននឹងនិយាយអំពីការសិក្សារបស់លោកនោះ ខ្ញុំចង់និយាយអំពីមុខងាររបស់លោកជានីរសារ។ តើលោកយកសារទៅឲ្យអ្នកណាគេដែរ នៅពេលនោះ?

**ឆ៖** កាលហ្នឹងនៅបម្រើអ៊ំៗនៅកន្លែង នៅមន្ទីរហ្នឹង។

[១១:២៣:៤៥]

**ស៖** សូមអរគុណ។ នៅពេលដែលលោកនិយាយថា អ៊ំៗនេះ តើជាអ្នកណាខ្លះដែលធ្វើការនៅមន្ទីរប-២០នេះ? សូមលោកផ្តល់ឈ្មោះអ៊ំៗទាំងនោះ។

**ឆ៖** កាលហ្នឹងមាន អ៊ំនួន, អ៊ំ ហ៊ូ នឹម, ហ៊ូ យន់, ហើយនិង ប៉ុល ពត –អ៊ំប៉ុល ពត។

**ស៖** តើមានអ៊ំៗផ្សេងទៀតទេ ក្រៅពីអ៊ំ នួន, ប៉ុល ពត, ហ៊ូ នឹម, ហ៊ូ យន់ នេះ? តើលោកមាននឹកឃើញទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន!

**លោក អាកទួរ វែកគែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់កត់សម្គាល់ថា សហព្រះរាជអាជ្ញាគួរតែឲ្យគាត់អានកំណត់ហេតុរបស់គាត់ក្នុងអំឡុងពេលដែលគាត់ -- ក្នុងអំឡុងពេលដែលយើងរង់ចាំការបកប្រែនោះ។

**អ្នកបកប្រែ៖**

សូមទោស សូមកែប្រែ គឺថាសូមកុំឲ្យគាត់អានកំណត់ហេតុរបស់គាត់ សូមឲ្យគាត់ឆ្លើយនូវអ្វី

ដែលគាត់ចងចាំ កុំឲ្យគាត់មើលឯកសារបែបនេះ ព្រោះថាពេលដែលមើលទៅធ្វើឲ្យប៉ះពាល់ដល់ចម្លើយរបស់គាត់។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល -- មិនចាំបាច់អាននូវឯកសារចំពោះមុខលោកទេ នៅពេលអាននៅពេលណាដែលភាគីពាក់ព័ន្ធនឹងដកស្រង់ ៗនូវខ្លឹមសារនៃកំណត់ហេតុសួរទេ អាហ្នឹងអាចអានបាន។ បើមិនដូច្នោះទេ មិនបាច់អានទេ ស្តាប់នូវសំណួរដែលសួរ ហើយនិងចាំឆ្លើយតប។

[១១:២៦:០២]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** សំណួររបស់ខ្ញុំនោះ ខ្ញុំចង់ដឹងថាតើក្រៅពី ប៉ុល ពត, អ៊ំនួន, ហ៊ូ នឹម, ហ៊ូ យន់ តើមានមេដឹកនាំណាផ្សេងទៀតទេដែលរស់នៅ ឬធ្វើការនៅមន្ទីរប-២០ ហើយដែលលោកបានឃើញដោយផ្ទាល់ភ្នែកនោះ?

**លោក ផាន វ៉ាន៖**

**ឆ៖** អត់ៗមានទេបាទ។

**ស៖** សូមអរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីអាននូវសម្រង់នៃកំណត់ហេតុលេខ E3/57 ដែលចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩។ គឺសំណួរទី១ ដែលចោទសួរទៅកាន់សាក្សីរូបនេះដោយសហចៅក្រមស៊ើបអង្កេត ជាភាសាខ្មែរទំព័រ២, ៣, ERN 00287701 រហូតទៅដល់ 00287702, អង់គ្លេស -- បារាំងទំព័រ២ អង់គ្លេសទំព័រទី៣។ បាទ ដូចជារាល់ដងដែរ គឺខ្ញុំសូមការអនុញ្ញាតបង្ហាញឯកសារនេះនៅលើអេក្រង់លោកប្រធាន។

[១១:២៧:២៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** លោកសាក្សី តើលោកមានឯកសារនេះនៅហ្នឹងដៃឬទេ ប៉ុន្តែនៅមុខលោកនេះគឺមានហើយនៅលើអេក្រង់។ លោកបានឆ្លើយថា "នៅប-២០ មាន នួន ជា, ប៉ុល ពត និងបញ្ញាជនមួយចំនួនទៀត ដូចជា ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់ ចំពោះ តាម៉ុក, សុន សេន មកមន្ទីរនេះម្តងម្កាលទេ។ និយាយរួមអ្នកដឹកនាំតាមតំបន់ ភូមិភាគទាំងអស់មកប្រជុំគ្នានៅទីនេះ" សូមបញ្ចប់ការដកស្រង់។ ដូច្នេះ តើលោកមានទឹកឃើញទេថាតើក្រៅពី នួន ជា, ប៉ុល ពត, ហ៊ូ នឹម, ហ៊ូ យន់ លោកបានបញ្ជាក់ជូនសហចៅក្រមស៊ើបអង្កេតថាលោកក៏បានឃើញ ខៀវ សំផន, តាម៉ុក និង សុន សេន ផងដែរ នៅពេលដែលលោកឆ្លើយនោះ?

**លោក ផាន វ៉ាន៖**

**ឆ៖** បាទ បានឃើញមែន ពីព្រោះកន្លែងនេះជាកន្លែងមន្ទីររួម ប៉ុន្តែអត់នៅទេ គាត់អត់នៅហ្នឹងទេ។

**ស៖** សូមអរគុណ។ លោកឆ្លើយថា "លោកជានីរសារ លោកនាំសារទៅឱ្យអ៊ំៗ"។ ដូច្នេះតើលោកយកទៅឱ្យអ៊ំៗណាខ្លះ?

**ឆ៖** ឱ្យតាម -- ឱ្យអ៊ំៗពីអ៊ំមួយទៅអ៊ំមួយ ពីអ៊ំនួន ទៅអ៊ំប៉ុល ពត អ៊ីចឹងទៅ។ គាត់ប្រើពីផ្ទះមួយទៅផ្ទះមួយ។

**ស៖** នៅពេលដែលលោកធ្វើជានីរសារ តើអ៊ំៗទាំងអស់នោះនៅកន្លែងតែមួយ ឬក៏មានអ៊ំណាផ្សេង នៅកន្លែងផ្សេង រស់នៅឆ្ងាយពីប-២០?

**ឆ៖** នៅកន្លែងតែមួយ។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប សូមអញ្ជើញលោកមេធាវីការពារក្តី លោក អៀង សារី។

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជឿថា របៀបសួរសំណួរនេះគឺធ្វើឱ្យច្រឡំ ដែលថា តើអ៊ំទាំងអស់នោះអ្នកណាខ្លះ? អ្វីដែលគាត់យោងខាងដើមឱ្យគាត់ចងចាំវិញ ឬក៏ទាំងអស់ទូទៅ គឺអ៊ំទាំងអស់ទូទាំងមួយរបបនេះ ឬក៏ដូចម្តេច? ដូច្នេះដើម្បីឱ្យច្បាស់ ដើម្បីសួរឱ្យជាក់លាក់ជាងនេះ ហើយបើសួរបែបនេះអាចជាសំណួរនាំមុខដល់សាក្សី។ បាទ សូមអរគុណ។

[១១:៣០:៤២]

**លោក វ៉ាំងសង់ វ៉ាយជ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំនឹងរៀបចំសំណួរឡើងវិញ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយជ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សី លោកបានយល់ស្របថា នូវចម្លើយដែលលោកឆ្លើយចំពោះសហចៅក្រមស៊ើបអង្កេតគឺថា តាម៉ុក និង សុន សេន មកម្តងម្កាល។ ខ្ញុំនិយាយអំពីអ៊ំផ្សេងៗ នួន ជា, ប៉ុល ពត, ខៀវ សំផន, ហ៊ូ នឹម និង ហ៊ូ យន់។ តើអ៊ំទាំង៥ នេះធ្វើការនិងរស់នៅ នៅកន្លែងតែមួយនៅប-២០ ឬក៏មានអ្នកខ្លះក្នុងចំណោមអ្នកទាំង៥ នេះធ្វើការនៅកន្លែងផ្សេងម្តងម្កាលដែរ?

**លោក ផាន វ៉ាន៖**

**ផ៖** គាត់នៅហ្នឹងជុំគ្នាទាំងអស់ ហើយក្រៅពីហ្នឹងគាត់មកម្តងម្កាលទេ។

**ស៖** នៅពេលនោះ តើលោកដឹងអំពីមុខងាររបស់មេដឹកនាំទាំងប្រាំពីរនាក់ ដែលលោកបានរៀបរាប់ហ្នឹងទេ ថាពួកគាត់ធ្វើអ្វីខ្លះ?

**ផ៖** អត់ដឹងទេ។

**ស៖** ក្នុងសម្រង់ដែលខ្ញុំបានអានអម្បាញ់មិញនេះ លោកបានឆ្លើយថា ជាកន្លែងរបស់មជ្ឈិម ហើយមេដឹកនាំតាមតំបន់ភូមិភាគទាំងអស់មកប្រជុំគ្នានៅកន្លែងនោះ។ តើលោកពិតជាដឹងថាមានកិច្ចប្រជុំរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ និងកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមនៅមន្ទីរប-២០ ដែរឬទេ?

**ផ៖** ដឹង ក្រោយមកបានដឹង។

**ស៖** សូមអរគុណ។ នៅក្នុងអំឡុងពេលដែលលោកជានីរសារនេះ តើលោកមានរៀនសូត្រអ្វីផ្សេងទៀតទេ នៅមន្ទីរប-២០?

[១១:៣២:៥១]

**ផ៖** កាលនោះ ខ្ញុំរៀនបកប្រែអង្គុលីលេខ។

**ស៖** តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការបង្រៀនលោកអំពីការបកប្រែទូរលេខ?

**លោក គង់ សំអុន៖**

លោកប្រធាន!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទ អរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ សាក្សីគាត់ថា គាត់បកប្រែអង្គុលីលេខ ហើយសំណួររបស់សហព្រះរាជអាជ្ញានិយាយអំពីការបកប្រែទូរលេខ ដូច្នេះវាអត់ស៊ីគ្នាទេបាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការកត់សម្គាល់នេះ។ សូមលោកតំណាងសហព្រះរាជអាជ្ញាតាំងសំណួរឲ្យបានជាក់ច្បាស់ ដើម្បីឃើញថាវា បកប្រែអង្គុលីលេខ ឬក៏បកប្រែសារទូរលេខ ដល់ពេលឆ្លើយថា អង្គុលីលេខ ដល់ពេលក្រោយមកលោកសួរទូរលេខ វាខុសគ្នាឆ្ងាយណាស់។ ជាភាសាខ្មែរ គឺខុសគ្នាឆ្ងាយណាស់។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសួរសំណួរនេះផ្អែកទៅតាមការបកប្រែមកឲ្យខ្ញុំជាភាសាបារាំង គឺគេបកថា បកប្រែទូរលេខ ដូច្នេះខ្ញុំសួរដោយយកពាក្យនេះវិញទេ។ ហើយយើងក៏ឃើញនៅក្នុងកំណត់ហេតុនោះ កំណត់ហេតុស្តាប់ចម្លើយរបស់គាត់នោះ គឺគាត់និយាយអំពីការបកប្រែសារអង្គុលីលេខសម្ងាត់ ហើយឯកសារស្តាប់ចម្លើយមួយទៀតនោះ និយាយថាបកប្រែទូរលេខ។ ដូច្នេះ ខ្ញុំគិតថាមានបញ្ហាផងដែរនៅក្នុងការបកប្រែជាភាសាខ្មែរ។

**ស៖** ប៉ុន្តែដើម្បីត្រឡប់មកនិយាយអំពីអ្វីដែលសាក្សីបាននិយាយនោះ ខ្ញុំចង់ដឹងថាតើអ្នកណាជាអ្នកបង្រៀនសាក្សីឲ្យបកប្រែអង្គុលីលេខសម្ងាត់ ឬក៏ទូរលេខ? ដូច្នេះសូមឲ្យសាក្សីបញ្ជាក់ថា តើជាអង្គុលីលេខ ឬក៏ជាសារទូរលេខ?

**លោក ផាន វ៉ាន៖**

**ឆ៖** នេះគេហៅថា ទូរលេខ អាហ្នឹង។ អាម៉េចមិនយល់ដែរខ្ញុំ។

**ស៖** សូមអរគុណលោកសាក្សីដែលបានឆ្លើយបំភ្លឺ។ ដូច្នេះ ខ្ញុំសួរថា តើអ្នកណាជាអ្នកបង្រៀនលោកឲ្យបកប្រែទូរលេខ សូមលោកផ្តល់ឈ្មោះអ្នកដែលបង្រៀនលោក?

**ឆ៖** ឈ្មោះ មីងស៊ឹម ជំនាន់ហ្នឹង។

[១១:៣៦:០៥]

**សៈ** តើមានឈ្មោះ យស់ ដែលធ្វើការនៅខាងផ្នែកទូរលេខ នៅប-២០ដែរទេ?

**ឆៈ** ខ្ញុំអត់ចាំ អត់ស្គាល់។

**សៈ** សូមអរគុណលោកសាក្សី។ ប្រហែលជាខ្ញុំអានឈ្មោះមិនត្រឹមត្រូវ បានជាលោកឆ្លើយថា អត់ស្គាល់។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ E3/57 នៅទំព័រទី៣ ជាភាសាខ្មែរ, ទំព័រទី៣ ជាភាសាបារាំង និងទំព័រទី៣ ជាភាសាអង់គ្លេស។ លោកបានឆ្លើយថា ខ្ញុំសូមដកស្រង់ "គ្រូបង្រៀនក្មេងៗទាំងអស់នោះឈ្មោះ ស៊ឹម ភេទស្រី (ស្លាប់)។ គ្រូបង្រៀនគេឡើក្រោមខ្ញុំឈ្មោះ យស់"។ លោកសាក្សី តើលោកមាននឹកឃើញអំពីឈ្មោះ យស់ ដែលជាអ្នកបង្រៀនលោកឲ្យបកប្រែទូរលេខនេះដែរឬទេ?

**ឆៈ** មានឈ្មោះ យស់ មាន ប៉ុន្តែស្លាប់បាត់ហើយ។

**សៈ** នៅមន្ទីរប-២០ តើលោកធ្លាប់ជួបលោក នង សុផង់ ហៅ ផង់ ឬក៏ឈ្មោះ ខឹម ឬក៏ ប៉ង់ តើលោកធ្លាប់ជួបអ្នកទាំងអស់នេះដែរឬទេ?

**ឆៈ** អត់ទេ អត់បានជួបទេ។

[១១:៣៨:២៥]

**សៈ** នៅពេលដែលលោករៀនបកទូរលេខ តើលោកត្រូវសរសេរទូរលេខ ឬក៏លោករៀនកូដសម្ងាត់ផ្សេងៗដែលគេប្រើដោយកងកម្លាំងខ្មែរក្រហមនោះ?

**ឆៈ** គ្រាន់តែរៀន គ្រាន់តែរៀនលេខកូដ។

**សៈ** នៅពេលដែលលោករៀននោះ ជាទូទៅ គឺលោកបកប្រែទូរលេខដែលផ្ញើទៅឲ្យអ៊ំផ្សេងៗ នៅមន្ទីរ ប-២០ គឺបានន័យថា លោករៀនបក និងបំភ័ន្តអក្ខរៈ តើមែនទេ?

**ឆៈ** គ្រាន់តែរៀន ខ្ញុំអត់បានបកអីសម្រាប់ខាងអ៊ំៗហ្នឹងទេ។

[១១:៣៩:៤៦]

**សៈ** សូមអរគុណ។ ឥឡូវនេះខ្ញុំចូលទៅនិយាយអំពីរយៈពេលដែលលោកចេញពីអំពី ប-២០ លោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេតថា លោកបានអមដំណើរឪពុករបស់លោក គឺ តាឡាំង ទៅអូរបួនក្រោម បន្ទាប់មកទៀតទៅតំបន់១០៥ តើលោកអាចបញ្ជាក់ទេថា ពេលណាដែលលោកបានចាកចេញពីប-២០ ដើម្បីជូនដំណើរឪពុកលោកទៅអូរបួនក្រោម។ សូមអភ័យទោសផងបើសិនជាខ្ញុំអានឈ្មោះនេះមិនត្រូវ។

**ឆៈ** ចាំថ្ងៃខែមិនបាន ចាំឆ្នាំអត់បានដែរ។

**ស៖** ដើម្បី -- ជាដំបូងគឺខ្ញុំចង់ដឹងថា ទោះបីជាលោកមិនស្គាល់រយៈពេលពិតប្រាកដក៏ដោយ តើលោកអាចដឹងទេថា តើពេលណាប្រហែលដែលលោកចាកចេញពីប-២០ នេះ? ឧទាហរណ៍ថា ឆ្នាំ ឬក៏អាចចាំជារដូវក៏បាន។

**ផ៖** ឆ្នាំចាំអត់បានដូចមុន បើមិន ៧២, ៧៣។

[១១:៤១:២២]

**ស៖** សូមអរគុណ។ នៅពេលដែលលោកជូនឪពុកលោកទៅកន្លែងនោះ តើលោកធ្វើអ្វី ឲ្យឪពុកលោកនោះ?

**ផ៖** ខ្ញុំនៅបកសារជាមួយគាត់។

**ស៖** នៅពេលដែលលោកនៅអូរប្ឫសក្រោម តើលោកអាចបញ្ជាក់អំពីទីតាំងកន្លែងនោះបានទេ? តើវាស្ថិតនៅក្នុងខេត្តមណ្ឌលគិរី មែនដែរឬទេ?

**ផ៖** មែន នៅខេត្តមណ្ឌលគិរី។

**ស៖** នៅពេលដែលលោកនៅទីនោះ តើមេដឹកនាំដូចជា ប៉ុល ពត, នួន ជា, ខៀវ សំផន មាន បានមកមើល ចុះមើលកន្លែងនុ៎ងទេ?

**ផ៖** អត់មានទេ។

**ស៖** តើលោកនៅអូរប្ឫសក្រោមនេះប៉ុន្មានឆ្នាំដែរ មុននឹងលោកទៅភ្នំក្រោលនៅតំបន់១០៥នោះ?

**ផ៖** ស្តាប់អត់ច្បាស់ផង ស្តាប់សំណួរអត់បានច្បាស់។

**ស៖** នៅពេលដែលលោកចាកចេញពីប-២០ ទៅជាមួយឪពុករបស់លោកនោះ គឺថា លោក បានថា លោកបានទៅអូរប្ឫសក្រោម ហើយបន្ទាប់មកលោកទៅរស់នៅភ្នំក្រោល។ ដូច្នេះ ខ្ញុំចង់ដឹងថា តើលោកអាចបញ្ជាក់បានទេថា លោកទៅភ្នំក្រោលនោះនៅពេលណា?

**ផ៖** ភ្នំក្រោល ជិតៗរំដោះភ្នំពេញ។

**ស៖** តើមន្ទីរភ្នំក្រោលមានលេខកូដសម្ងាត់ដែរឬទេ?

**ផ៖** មន្ទីរភ្នំក្រោលគេហៅ ក-១៧។

[១១:៤៤:៣១]

**ស៖** សូមអរគុណ។ ខ្ញុំនឹងត្រឡប់មកនិយាយអំពីមុខងាររបស់លោក និងរចនាសម្ព័ន្ធរដ្ឋបាលនៃ តំបន់១០៥ នៅពេលក្រោយ ក៏ប៉ុន្តែអម្បាញ់មិញនេះ លោកនិយាយអំពីការរំដោះទីក្រុងភ្នំពេញ។ ហើយ

លោកនៅតំបន់១០៥ មុនពេលគេរំដោះ តើមានអ្នកដែលគេជម្លៀសពីភ្នំពេញ ឬក៏ពីក្រុងផ្សេងទៀត ត្រូវបានបញ្ជូនទៅខេត្តមណ្ឌលគិរីតំបន់១០៥ ដែរឬទេ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥? តើលោកមានបានឃើញអ្នកជម្លៀសទាំងអស់នោះ ទៅកន្លែងរបស់លោកទេ?

[១១:៤៥:១៥]

**ធ៖** អត់មានទេ។

**ស៖** បាទ សូមអរគុណ។ យើងនឹងនិយាយអំពីការទំនាក់ទំនងនៅក្នុងតំបន់១០៥ ជាមួយមជ្ឈិម ក៏ប៉ុន្តែមុនពេលនិយាយដល់ចំណុចនេះ ដើម្បីឲ្យយល់ថាតើព័ត៌មានត្រូវបានផ្សព្វផ្សាយយ៉ាងម៉េច? ខ្ញុំចង់សួរសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងការរៀបចំ និងរចនាសម្ព័ន្ធនៅក្នុងតំបន់១០៥។ នៅមុនពេលទៅដល់ -- (សូមទោស) នៅពេលនៅភ្នំក្រោលនោះ តើឪពុករបស់លោកមានមុខងារអ្វីដែរនៅភ្នំក្រោល នៅតំបន់១០៥?

**ធ៖** គាត់ជាលេខាតំបន់។

**ស៖** អម្បាញ់មិញនេះ លោកបានឆ្លើយថា លោកមិនចាំឈ្មោះផ្សេងៗរបស់ឪពុកលោក។ តើឪពុកលោកមានឈ្មោះបដិវត្តន៍ទេ? ហើយគាត់ផ្លាស់ប្តូរឈ្មោះបដិវត្តន៍គាត់ញឹកញាប់ដែរឬទេ?

**ធ៖** មានឈ្មោះ ឡាំង ហើយនិងឈ្មោះ ហម។

**ស៖** តើគាត់មានឈ្មោះផ្សេងទៀត ដែលគាត់ប្រើ ឧទាហរណ៍ដូចជា នៅក្នុងការទំនាក់ទំនងគ្នាតាមទូរលេខនោះ គាត់មានប្រើឈ្មោះអ្វីផ្សេងទៀតដែរឬទេ បើតាមការចងចាំរបស់លោកនោះ?

**ធ៖** តាមទូរលេខអត់មានទេ។

**ស៖** ក្នុងឋានៈជាលេខាតំបន់១០៥ តើលោកដឹងទេថា តើឪពុករបស់លោករាយការណ៍ទៅអ្នកណាដែរ ចាប់ពីខែមេសា ឆ្នាំ៧៥ មក?

**ធ៖** រាយការណ៍ទៅ៨៧០។

**ស៖** សូមអរគុណ។ តើលោកដឹងថា ឪពុកលោករាយការណ៍ជូនមន្ទីរ៨៧០ នេះដោយរបៀបណា?

**ធ៖** តាមសារទូរលេខ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកមេធាវីការពារក្តីលោក ខៀវ សំផន!

[១១:៤៨:៣២]

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ ខ្ញុំចង់ធ្វើការកត់សម្គាល់ពីការដាក់សំណួរបន្ថែមរបស់តំណាងសហព្រះរាជអាជ្ញា ព្រោះសាក្សីបានឆ្លើយថា ឪពុករបស់លោករាយការណ៍ទៅ៨៧០។ ដល់តែពេលសហព្រះរាជអាជ្ញាគាត់បន្ថែមថាជាមន្ទីរ៨៧០។ ដូច្នេះ វាមានចំណុចខ្វែងគ្នា។ សូមលោកព្រះរាជអាជ្ញាធ្វើការសាកសួរទៅតាមចម្លើយរបស់សាក្សី។ បាទ សូមអរគុណ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

គឺនេះជាបញ្ហាបកប្រែ ព្រោះខ្ញុំសួរគាត់ថា គាត់ -- ឪពុកគាត់រាយការណ៍ទៅណា? ហើយសាក្សីគាត់ឆ្លើយថា ឪពុកគាត់រាយការណ៍ជូនមន្ទីរ៨៧០។ ខ្ញុំមិនមែនជាអ្នកនិយាយទេ គឺសាក្សីគាត់ឆ្លើយគេបកប្រែមកឲ្យខ្ញុំ គឺគាត់ថា គាត់ដឹងព័ត៌មាននេះតាមរយៈទូរលេខ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** តើលោកដឹងទេថា តំបន់១០៥ ស្ថិតនៅក្រោមបង្គាប់របស់អ្នកណា ឬក៏របស់អង្គភាពណានៅក្នុងរបបខ្មែរក្រហម?

**លោក ផាន វ៉ាន៖**

**ផ៖** អត់យល់ន័យសំណួរ។

**ស៖** សំណួរគឺខ្ញុំចង់ដឹងថា តាមឋានានុក្រម តើតំបន់១០៥ ស្ថិតនៅក្រោមឱវាទរបស់ភូមិភាគ ឬក៏ស្ថិតនៅក្រោមឱវាទរបស់មជ្ឈិម?

**ផ៖** អានេះជារបស់មជ្ឈិម។

[១១:៥០:៥៣]

**ស៖** តើតំបន់១០៥ ជាតំបន់ស្វយ័តមែនដែរឬទេ នៅក្នុងក្រោមរបបខ្មែរក្រហម បើតាមចម្លើយរបស់លោកអម្បាញ់មិញនេះ? ហើយប្រសិនជា ខ្ញុំយល់ខុស សូមលោកកែតម្រូវ។

**ផ៖** តាមខ្ញុំយល់ដូចស្វយ័តបាទ។

**ស៖** តើតំបន់១០៥ មានប៉ុន្មានស្រុកដែរ? ហើយប្រសិនបើលោកចាំអំពីឈ្មោះស្រុកទាំងអស់នោះ សូមផ្តល់ឈ្មោះផង។

**ផ៖** អត់អស់ផង។

សៈ ប្រសិនបើលោកមិនចាំឈ្មោះទាំងអស់ទេ តើលោកចាំឈ្មោះស្រុកមួយចំនួន ដែលស្ថិតនៅក្នុងតំបន់១០៥ដែរឬទេ?

ធៈ មានស្រុកកោះញែក, ស្រុកកែវសីមា, ស្រុកអូររាំង, ពេជ្រចិន្តា ហើយនិងកែវសីមា។

សៈ សូមអរគុណលោកសាក្សី។ នៅក្នុងតំបន់១០៥ តើមានសហករណ៍ច្រើនដែរឬទេ?

ធៈ សហករណ៍ទូទៅ។ ទាំងអស់គ្រប់ស្រុកហ្នឹង សហករណ៍ទាំងអស់ហ្នឹង។

សៈ តើសហករណ៍នេះ ត្រូវបានបង្កើតឡើងមុនពេលឪពុកលោកទៅដល់ ឬក្រោយពេលឪពុកលោកទៅដល់?

ធៈ អត់យល់ន័យនេះ។

សៈ លោកបានឆ្លើយថា មានសហករណ៍នៅតាមស្រុកនីមួយៗ។ អ៊ីចឹង ខ្ញុំចង់ដឹងថាតើសហ-ករណ៍ទាំងនោះ ត្រូវបានបង្កើតឡើងតាំងពីមុនពេលដែលឪពុកលោកទៅដល់ភ្នំក្រោល ឆ្នាំ៧៥ ឬក៏ទើបតែបង្កើតនៅពេលដែលគាត់ទៅដល់ទេ?

[១១:៥៣:៣៥]

ធៈ មុន៧៥ បាទ។

សៈ តើលោកដឹងទេថា សហករណ៍នោះ កើតឡើងនោះនៅឆ្នាំណាដែរ?

ធៈ តាំងពីខ្ញុំទៅពី ប-២០ទៅ ទៅពីខ្ទង់ឆ្នាំ៧០ ចុង៧៣ ឬ៧៤ ប្រហែលប៉ុណ្ណឹង។

សៈ អម្បាញ់មិញនេះ លោកឆ្លើយ ៧២, ៧៣ គឺមានន័យថា ចុង៧៣ និងដើម៧៤ ដែលលោកបានចាកចេញពីមន្ទីរ ប-២០ តើអ៊ីចឹងមែនទេ?

ធៈ ចាំអត់ច្បាស់។

សៈ តើលោកមានដឹងទេថា មានចលនាដឹកនាំនោះ មានចេញសេចក្ដីណែនាំ នៅមន្ទីរប-២០ ដើម្បីបង្កើតសហករណ៍នៅតំបន់១០៥ នៅមុនឆ្នាំ៧៥ ដែរឬទេ?

ធៈ ខ្ញុំនៅក្មេងណាស់ អត់យល់ទេ ប៉ុន្តែដឹងតែថា បាយរួម មុន៧៥។

សៈ នៅពេលដែលលោកធ្វើការនៅតំបន់១០៥ គឺលោកនៅទីនោះ នៅជាមួយឪពុកលោកនៅភ្នំក្រោល។ តើតំបន់១០៥ មានកងទ័ពផ្ទាល់ខ្លួនដែរឬទេ?

ធៈ មានកងទ័ពតំបន់។

**សៈ** ប្រសិនបើខ្ញុំយល់មិនច្រឡំទេ គឺថាកងទ័ពនោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឪពុកលោក តើមែនទេ?

**ឆៈ** មែនបាទ។

[១១:៥៦:៣០]

**សៈ** ចុះអ្នកណាជាអ្នកទទួលខុសត្រូវខាងសន្តិសុខ ហើយនិងខាងឃោធានោះ នៅក្រោមឪពុកលោកនោះ តើមានកម្មាភិបាលណានៅមន្ទីរ -- នៅតំបន់១០៥ហ្នឹង ដែលដឹកនាំកងទ័ពទាំងនុំងទេ?

**ឆៈ** ឈ្មោះ សុភា។

**សៈ** សូមអរគុណ។ ក្រៅពីកងទ័ពតំបន់ តើមានកងពលរបស់កងទ័ពខ្មែរនៅតំបន់១០៥ ទេ?

**ឆៈ** អត់យល់ន័យ។ សួរមុន៧៥ ឬក៏ក្រោយ៧៥?

**សៈ** ខ្ញុំនិយាយសំដៅដល់ដើមឆ្នាំ៧៥ ហើយនិងចុងឆ្នាំ៧៧។ ខ្ញុំចង់ដឹងថាតើនៅតំបន់១០៥ នោះមានកងពលធំរបស់មជ្ឈិម ដែលមកបោះទីតាំងនៅតំបន់១០៥ របស់លោកហ្នឹងទេ?

**ឆៈ** មានក្រោយឆ្នាំ៧៥។ វាពាក់កណ្តាលឆ្នាំ៧៥ ច្រឡំ។ កងទ័ព -- កងពល៩២០។

**សៈ** ហើយអ្នកណាជាមេបញ្ជាការកងពលធំ៩២០ នៅពេលដែលកងពលនេះ មកបោះទីតាំងនៅក្នុងខេត្តមណ្ឌលគិរីនោះ?

**ឆៈ** ឈ្មោះ ឈិន។

**សៈ** សូមអរគុណ។ តើតាឈិន នេះត្រូវបានផ្លាស់ប្តូរដោយមេដឹកនាំផ្សេងទៀត ជាមេបញ្ជាការកងពល៩២០ ដែរឬទេ? ហើយបើមានតើឈ្មោះអ្វីដែរ អ្នកដែលមកជំនួស តាឈិន នេះ?

[១១:៥៨:៥៩]

**ឆៈ** ក្រោយមក អត់ស្គាល់ដែរ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមល្មមសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀល សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះ និងមេធាវីប្រឹក្សារបស់គាត់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់

សក្ខីកម្មនេះវិញ នៅវេលាម៉ោងមួយសាមសិបនាទីរសៀលនេះ។

សូមអញ្ជើញលោកមេធាវីការពារក្ដីលោក នួន ជា!

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ សូមអរគុណលោក លោកស្រីចៅក្រម។

លោក លោកស្រីចៅក្រម ខ្ញុំទទួលដំណឹងថា ព្រឹកមិញនេះ គាត់មានសម្ពាធឈាមខ្ពស់ គឺថានៅម៉ោងប្រាំ ហើយគាត់បាន -- មិនទាន់បានពិនិត្យដោយវេជ្ជបណ្ឌិត។ ហើយព្រឹកមិញនេះគឺវេជ្ជបណ្ឌិតបានពិនិត្យ គឺថាសម្ពាធឈាមរបស់គាត់ គឺស្ថិតនៅក្នុងកម្រិតធម្មតា ក៏ប៉ុន្តែគាត់មានឈឺខ្នង ហើយនិងមិនអាចផ្ដង់អារម្មណ៍បាន។ ហើយសូមអនុញ្ញាតតុលាការដើម្បីទៅតាមនៅបន្ទប់ខាងក្រោម ហើយគាត់នឹងព្យាយាមតាមដានដំណើរការនីតិវិធីពីបន្ទប់ខាងក្រោម ប៉ុន្តែយើងខ្ញុំនឹងតាមដានសុខភាពរបស់គាត់នឹងជូនដំណឹងទៅតុលាការប្រសិនបើតាមពិតនោះគាត់មិនអាចមានលទ្ធភាពតាមដានបាននៅល្ងាចនេះ។ ដូច្នេះហើយគឺខ្ញុំសូមអនុញ្ញាតដើម្បីឲ្យគាត់ទៅតាមដានសវនាការនៅបន្ទប់ខាងក្រោមនេះក្នុងរយៈពេលពេញមួយល្ងាចនេះ។ សូមអរគុណលោកប្រធាន។

[១២:០០:៥៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០២:២៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានស្ដាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្ដីរបស់គាត់ ស្នើសុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រយៈពេលធ្វើសវនាការពេញមួយថ្ងៃនេះ ដោយមានមូលហេតុសុខភាព ដែលនាំឲ្យគាត់មិនអាចអង្គុយតាមដានក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះបាន។ ហើយសំណើសុំរបស់លោក នួន ជា ធ្វើឡើងមានមូលហេតុសមស្រប អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ ដែលលោក នួន ជា លះបង់សិទ្ធិចូលរួមដោយផ្ទាល់ក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្ដី នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្ជាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយ

ផ្ទាល់ក្នុងបន្ទប់សវនាការដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់របស់ជនជាប់ចោទ នួន ជា។

[១២:០៣:២១]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយដែលស្ថិតនៅក្រោមសាលសវនាការនេះសម្រាប់រយៈធ្វើសវនាការនៅរសៀលថ្ងៃនេះ។

ហើយក៏សូមជម្រាបលោកមេធាវីផងដែរថា ការពិនិត្យនិងវាយតម្លៃលើស្ថានភាពសុខភាពរបស់ជនជាប់ចោទនោះគឺជាភារកិច្ចរបស់លោកវេជ្ជបណ្ឌិត ដែលទទួលពិនិត្យថែទាំព្យាបាលសុខភាពរបស់ជនជាប់ចោទនៅក្នុងអំឡុងពេលនៃដំណើរការនៅ អ.វ.ត.ក នេះ។ នេះជាមូលដ្ឋាននៃសំអាងរបស់អង្គជំនុំជម្រះ មិនមែនផ្អែកលើការពិនិត្យដោយផ្ទាល់របស់លោកមេធាវីនោះទេ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ នួន ជា និងលោក ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំង អ៎! ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយនៅរសៀលនេះទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

[១២:០៤:២៧]

ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញឲ្យបានមុនម៉ោងមួយនិងសាមសិបនាទីរសៀលនេះ។

បាទ សូមអញ្ជើញលោកមេធាវីមានបញ្ហាអីទៀត?

**លោក អេនគ្រូ អ៊ីន្ធូហ្វ៊ឺ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់ឲ្យបានបំភ្លឺនៅក្នុងកំណត់ត្រាតុលាការ។ ខ្ញុំមិនបានចង្អុលបង្ហាញថា យើងមិនតាមដានពិនិត្យសុខភាពរបស់គាត់ទេ ហើយយើងមិនមានសិទ្ធិអ្វីដែលខ្ញុំថា ខ្ញុំនឹងតាមដានដូចថា តាមដានមើលថាតើសុខភាពរបស់គាត់យ៉ាងដូចម្តេច ដើម្បីធានាថា ពិត -- តាមពិតនោះ គាត់អាចតាមដានដោយប្រសិទ្ធភាព ចូលរួមដោយប្រសិទ្ធភាពដែរឬទេ? ហើយខ្ញុំចង់ជម្រាបលោកប្រធានថា គឺយើងខ្ញុំនឹងឃ្លាំមើលមិនមែនថា ការពិនិត្យបែបវេជ្ជសាស្ត្រទៅលើគាត់នោះទេ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់ដែលលោកបានយល់ច្បាស់លាស់ អំពីបញ្ហានេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៥ នាទី ដល់ម៉ោង ១៣:៣២នាទី)*

[១៣:៣២:២៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅរសៀលនេះ មុននឹងផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ អង្គជំនុំជម្រះប្រកាសនូវសេចក្តីសម្រេចផ្ទាល់មាត់ទៅលើសំណើសុំផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-1 ដូចខាងក្រោមនេះ៖

នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូង បានទទួលអនុស្សរណៈមួយ ពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដែលបានបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-1 ដែលមានអាយុ៦៨ឆ្នាំ បានស្នើសុំផ្តល់សក្ខីកម្ម តាមរយៈប្រព័ន្ធសោតទស្សន៍ និងបានបញ្ជាក់ថា ១)គាត់បានសម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំង អំពីការធ្វើដំណើរមកទីក្រុងភ្នំពេញដើម្បីផ្តល់សក្ខីកម្មដោយផ្ទាល់។ ២) គាត់បន្តរងការឈឺចាប់ដោយសារការចងចាំ នូវបទពិសោធន៍យ៉ាងជូរចត់ចំពោះព្រឹត្តិ-ការណ៍នានា ដែលគាត់បានជួយប្រទះមុនពេលគាត់ចាកចេញពីប្រទេសកម្ពុជា។ ៣) គាត់បានបាត់បង់មនុស្សគ្រប់គ្នា ដែលគាត់បានស្គាល់នៅប្រទេសកម្ពុជា និង ៤) ស្វាមីរបស់គាត់មិនអាចធ្វើដំណើរជាមួយគាត់មកប្រទេសកម្ពុជា ដើម្បីជួយគាំទ្រដល់គាត់បានទេ។ ឯកសារលេខ E 236/1/1។

[១៣:៣៤:៥៥]

អង្គជំនុំជម្រះសាលាដំបូងបានទទួលយកសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដោយអនុញ្ញាតឱ្យគាត់ផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ ពីប្រទេសបារាំង និងបានកំណត់កាល

បរិច្ឆេទសម្រាប់ការផ្តល់សក្ខីកម្មរបស់គាត់ ពីថ្ងៃទី១២ ដល់ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១២។ ឯកសារលេខ E236/1/1/1។

អង្គជំនុំជម្រះបានកត់សម្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-1 នេះ មិនមែនជាអ្នកជំនាញទេ ហើយនិងទំនងមិនមានឯកសារត្រូវបង្ហាញច្រើនទេពាក់ព័ន្ធចំពោះគាត់។ ហេតុដូច្នេះ គាត់អាចផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍បាន។ អង្គជំនុំជម្រះក៏បានកត់សម្គាល់បន្ថែមទៀតថា ដោយសារដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមានភាពទន់ខ្សោយផ្នែកផ្លូវចិត្ត និងផ្លូវកាយនោះ ទើបតម្រូវឲ្យមានការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ដូចនេះ។ នាពេលនោះ ភាគីមិនបានទទួលដំណឹងពីសំណើសុំ របស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទេ ហើយភាគីក៏មិនបានប្តឹងជំទាស់អ្វីដែរ។ ពេលនេះមេធាវីការពារក្តី អៀង សារី បានស្នើសុំដល់អង្គជំនុំជម្រះឲ្យបង្ហាញភស្តុតាងបន្ថែមទៀត ដើម្បីគាំទ្រសេចក្តីសម្រេចរបស់ខ្លួន ដោយសារអង្គជំនុំជម្រះសាលាដំបូងមិនបានបង្ហាញថា សំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 គឺមានហេតុផលសមស្របអាចទទួលយកបាន។

[១៣:៣៦:៣១]

មេធាវីការពារក្តី អៀង សារី បានស្នើសុំបន្ថែមទៀតថា ដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 ត្រូវមកផ្តល់សក្ខីកម្មដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ឯកសារ E236/1/1/2។ សំណើសុំកថាខណ្ឌ១៧។

អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា អង្គជំនុំជម្រះឆន្ទានុសិទ្ធិក្នុងការអនុញ្ញាតឲ្យផ្តល់ភស្តុតាងតាមរយៈប្រព័ន្ធសោតទស្សន៍បាន ប្រសិនបើចាំបាច់ត្រូវធ្វើដូច្នេះ។ ដរាបណាវិធានការទាំងនោះមិនប៉ះពាល់ធ្ងន់ធ្ងរ ឬរំលោភលើសិទ្ធិការពារខ្លួនរបស់ជនជាប់ចោទ។ សូមមើលសេចក្តីសម្រេចរបស់តុលាការ អាយ.ស៊ី.ស៊ី នៅក្នុងរឿងក្តីរដ្ឋអាជ្ញាតទល់នឹង បំបា ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ៥។ សូមមើលផងដែរវិធាន២៦(១) នៃវិធានផ្ទៃក្នុង អ.វ.ត.ក។

មេធាវីការពារក្តីបានលើកឡើងថា ការអនុញ្ញាតឲ្យផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 តាមរយៈប្រព័ន្ធសោតទស្សន៍នឹងប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ ពីព្រោះថាវាមានហេតុផលសមស្របក្នុងការសន្និដ្ឋានថា សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 នេះគឺជាសក្ខីកម្មដាក់បន្ទុកក្នុងអំឡុងពេលជំនុំជម្រះជនជាប់ចោទ អៀង សារី នៅក្នុងឆ្នាំ១៩៧៩។ សំណើសុំកថាខណ្ឌ១៥។

[១៣:៣៨:២២]

មេធាវីការពារក្តីបានជំទាស់ដោយលើកឡើងថា ការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍

មិនមែនជាការចាំបាច់ ដើម្បីបង្ហាញពីពិរុទ្ធភាពរបស់ជនជាប់ចោទទេ។ សំណើសុំកថាខណ្ឌ១៣។ ទោះបីជនជាប់ចោទរក្សាសិទ្ធិជំទាស់នឹងសក្ខីកម្មសាក្សី ដែលបានផ្តល់ដោយគ្មានវត្តមានរបស់គាត់នៅពេលដែលការផ្តល់សក្ខីកម្មនោះប៉ះពាល់ដោយផ្ទាល់ក្តី ដោយមិនផ្ទាល់ក្តី ឬការប្រព្រឹត្តិ ឬឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ដល់ជនជាប់ចោទនៅក្នុងដីកាដំណោះស្រាយក៏ដោយ ក៏ជនជាប់ចោទ អៀង សារី ធ្លាប់បានលះបង់សិទ្ធិក្នុងការចូលរួមស្តាប់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការរបស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 រួចហើយ ឯកសារ E237។ ជាពិសេសនៅពេលដែល អៀង សារី និងមេធាវីរបស់គាត់បានពិនិត្យមើលឯកសារនានា ដែលបានពិពណ៌នាច្បាស់លាស់ ពីបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ រួមទាំងការបាត់បង់ស្វាមីកូនស្រី និងសាច់ញាតិដទៃទៀតរបស់គាត់ជាច្រើននាក់ផងដែរ ឯកសារ D22/36, D22/36.2, D199/15។

បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ជនជាប់ចោទ អៀង សារី មានសម្បទាគ្រប់គ្រាន់ ដើម្បីចូលរួមសវនាការនោះ លិខិតលះបង់សិទ្ធិក៏ត្រូវបានដកចេញដែរ។ ឯកសារ E237/2។ ហើយនាពេលនេះ មេធាវីការពារក្តី អៀង សារី បានលើកឡើងថា ការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍មិនបានអនុញ្ញាតឲ្យលោក អៀង សារី ឬមេធាវីរបស់គាត់វាយតម្លៃយ៉ាងពេញលេញចំពោះការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានទេ។ សំណើសុំកថាខណ្ឌ១៦។

ដូចដែលការិយាល័យសហព្រះរាជអាជ្ញា បានកត់សម្គាល់រួចមកហើយ គឺថាអំណះអំណាងនេះផ្ទុយពីវិធានដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិដោយតុលាការ អាយ.ស៊ី.ធី.វ៉ាយ ដែលបានសម្រេចថា "សិទ្ធិរបស់ជនជាប់ចោទ មិនប៉ះពាល់ដោយសារតែអវត្តមានរបស់សាក្សី នៅពេលការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ត្រូវបានអនុញ្ញាតនោះឡើយ"។

[១៣:៤១:០៦]

មេធាវីការពារក្តីក៏បានលើកឡើងបន្ថែមទៀតថា "មិនមានភស្តុតាងគាំទ្រដល់ភាពទន់ខ្សោយផ្នែកផ្លូវកាយ និងផ្លូវចិត្តរបស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 ទេ"។ សំណើសុំកថាខណ្ឌ១១។ អង្គជំនុំជម្រះកត់សម្គាល់ថា ការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ ត្រូវបានធ្វើយុត្តកម្មយ៉ាងពេញលេញ ដើម្បីការពារសុខមាលភាពផ្លូវចិត្ត និងសេចក្តីថ្លៃថ្នូររបស់សាក្សី ដែលស្ថិតក្រោមបញ្ញត្តិ ជាសារវន្តនៃការជំនុំជម្រះប្រកបដោយយុត្តិធម៌។ សូមមើលសេចក្តីសម្រេចរបស់តុលាការ អាយ.ស៊ី.ស៊ី នៅក្នុងរឿងក្តី លូបាងហ្គា ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០, កថាខណ្ឌ១៥ ដល់កថាខណ្ឌ១៦។

បន្ថែមទៅលើការប្រាស្រ័យទាក់ទងរវាងដើមបណ្ដឹងរដ្ឋប្បវេណី TCCP-1 និងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ TCCP-1 បានបញ្ជាក់ច្បាស់លាស់ហើយថា គាត់បានទទួលរងព្យសនកម្មផ្លូវកាយ សម្ភារៈ និងផ្លូវចិត្តដោយផ្អែកយ៉ាងហោចណាស់លើឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មនានា ដែលបានចោទប្រកាន់ក្នុងសំណុំរឿង០០២/០១ នេះដែរ។ វិធាន២៣ស្ទួន នៃវិធានផ្ទៃក្នុង។ ការពិតការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលមេធាវីការពារក្ដី អៀង សារី មិនបានប្ដឹងឧទ្ធរណ៍នេះ ក៏បានគាំទ្រដល់ការលើកឡើងខាងលើនេះដែរ។

លើសពីនេះទៀត អង្គជំនុំជម្រះទើបបានទទួលលិខិតពេទ្យមួយច្បាប់ដែលបានបញ្ជាក់ថា ដើមបណ្ដឹងរដ្ឋប្បវេណីខាងលើនេះ មិនអាចធ្វើដំណើរមកប្រទេសកម្ពុជាបានទេ ដោយសារលក្ខខណ្ឌសុខភាពរបស់គាត់មិនអនុញ្ញាតឲ្យគាត់ធ្វើដំណើរមកបាន។

[១៣:៤៣:១០]

តាមសំអាងហេតុខាងលើនេះ អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើសុំរបស់មេធាវីការពារក្ដី អៀង សារី ដែលសុំកោះហៅដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-1 មកផ្ដល់សក្ខីកម្មនៅប្រទេសកម្ពុជា។

បាទ ជាបន្ត អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមកុំអាលទាន់។ សូមអញ្ជើញលោក ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាសៈ**

ខ្ញុំសូមជម្រាបថា យើងយល់ច្បាស់ តាមកំណត់ត្រា គឺថាជំហររបស់យើងគឺ ច្បាស់ដែរ គឺនៅដប់មួយសាមសិបនាទី គឺថាយើងបានវិញ្ញាបនបត្រពេទ្យគឺថា បើអង្គជំនុំជម្រះសាលាដំបូង ផ្ដល់វិញ្ញាបនបត្រពេទ្យ គឺថាបើយើងដឹងអំពីថា គ្រាន់តែជាការអះអាងពីមុននោះ គឺថាយើងអាចនឹងប្រកាន់ជំហរផ្សេង។ ដូច្នេះ ជំហររបស់ខ្ញុំនោះ គឺថាបើសិនជាអង្គជំនុំជម្រះសម្រេចថាធ្វើវីដេអូលីង គឺថាយើងសុំឲ្យគោរពទៅតាមនីតិវិធី ហើយយើងចង់បានព័ត៌មានឲ្យបានគ្រប់គ្រាន់។ បើយើងមិនបានព័ត៌មានទេ សូមអញ្ជើញឲ្យគាត់មកជាបុគ្គលដោយផ្ទាល់ ហើយយើងខ្ញុំចង់សុំឲ្យមានវិញ្ញាបនបត្រពេទ្យ។ ដូច្នេះគឺសូមអភ័យទោសដែលយើងធ្វើឲ្យមានការលំបាក។ បើសិនយើងបានព័ត៌មាននេះមុន គឺថាយើងមិនអាចមិន

បានធ្វើការជំទាស់នោះទេបាទ។

**ប្រធានអង្គជំនុំ៖**

បាន១។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១៣:៤៥:០១]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រី។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី មុននឹងត្រឡប់មកនិយាយអំពីអ្វីដែលយើងបាននិយាយមុនពេលសម្រាកថ្ងៃត្រង់នេះ និយាយអំពីកងពល៩២០ ខ្ញុំមានសំណួរមួយចំនួនសួរទៅលោកទាក់ទងទៅនឹង។ បាទ អម្បាញ់មិញនេះ លោកបាននិយាយថា ពុំមានជម្លៀសមនុស្សទៅមណ្ឌលគិរីនោះទេ។ យ៉ាងណាក្តីលោកមិនបានឃើញទេ។ អ៊ីចឹងខ្ញុំចង់ដឹងថា នៅក្នុងតំបន់១០៥នោះ តើមានការជម្លៀសអ្នកភូមិ ឬក៏អ្នកឃុំដែលតាមបញ្ជារបស់តំបន់១០៥ នៅក្នុងចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៧ ដែរឬទេ?

**លោក ផាន វ៉ាន៖**

**ឆ៖** អត់យល់ អត់យល់ពីសំណួរទេ លោកប្រធាន បាទ។

**ស៖** បាទ ខ្ញុំសូមសម្រួលសំណួរ។ អម្បាញ់មិញលោកនិយាយថា មិនឃើញមានគេជម្លៀសមនុស្សចេញពីភ្នំពេញ ទៅមណ្ឌលគិរីនោះទេ។ អ៊ីចឹងសំណួរខ្ញុំ ចង់ដឹងថា នៅក្នុងតំបន់១៥នោះ នៅក្នុងខេត្តមណ្ឌលគិរី តើមានការជម្លៀសប្រជាជនដែលត្រូវបានរៀបចំដោយតំបន់១០៥ ដែរឬទេ? តើនៅក្នុងតំបន់១០៥នេះ មានការជម្លៀសមនុស្សពីកន្លែងមួយទៅកន្លែងមួយនៅចន្លោះឆ្នាំ១៩៧៥ ទៅដល់១៩៧៩ ដែរឬទេ? ការជម្លៀសដែលរៀបចំដោយតំបន់១០៥ នោះ?

[១៣:៤៦:៤៤]

**ឆ៖** មាន មានជម្លៀសពីតំបន់ភ្នំ មកធ្វើស្រែនៅស្រុកកោះញែក ហើយនិងស្រុកច្បារ។

**ស៖** តើលោកដឹងថា ហេតុអ្វីបានមានការជម្លៀសមនុស្ស ហើយតើលោកដឹងថា បញ្ជាចេញមកពីណាដែរឬទេ បញ្ជាជម្លៀសប្រជាជនចេញ?

**ឆ៖** អត់មានបានដឹងថា បញ្ជាមកពីណាទេ វាគ្រាន់តែមានការជម្លៀសពីភូមិ តាមព្រៃភ្នំនោះមកនៅតាមដងស្ទឹងច្បារ។ មកទួលអូរច្បារ គេហៅ អូរច្បារ។

**ស៖** បាទ សូមអរគុណ។ តើប្រជាជនយល់ព្រមជម្លៀសខ្លួនពីតំបន់ភ្នំមក តំបន់ដាំដុះបាននោះដែរឬទេ ឬក៏ជាបញ្ហាដែលគាត់សុខចិត្តទទួលយកទាំងទើសទាល់?

**ឆ៖** អាហ្នឹងអត់យល់ដែរ មិនដឹងថាគាត់ជំទាស់ មិនដឹងជំទាស់ទេ។ ជំនាន់ហ្នឹងគេមកទាំងអស់ មកធ្វើស្រែនៅច្បារហ្នឹង។ បើនៅភ្នំ វាអត់មានអីហូប។

[១៣:៤៨:៣៦]

**ស៖** បាទ សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមត្រឡប់មកចោទសំណួរទាក់ទងនឹងកងពល៩២០ ខ្ញុំគ្រាន់តែចង់ដឹងថា តើមន្ទីរបញ្ជាការកងពល៩២០ នេះនៅត្រង់ណា? ហើយនិងចង់ដឹងថា តើមន្ទីរនេះនៅជិត ឬក៏ឆ្ងាយពីមន្ទីរក-១៧?

**ឆ៖** ពីបញ្ជាការកងពល៩២០ នៅប្រហែលជាប្រាំពីរ ប្រាំបីគីឡូ ពីក-១៧។ តាមផ្លូវភ្នំក្រោលដូចគ្នា។

**ស៖** សូមអរគុណ។ តើមន្ទីរហ្នឹង ទីបញ្ជាការហ្នឹងនៅក្នុងឃុំណាដែរ មន្ទីរបញ្ជាការប្រាំបួនរយ -- កងពល៩២០ នោះតើនៅភ្នំក្រោល ឬក៏នៅកន្លែងផ្សេង?

**ឆ៖** អាហ្នឹងគេហៅ ភ្នំក្រោល ដែរ។

[១៣:៤៩:៥៥]

**ស៖** សូមអរគុណ។ តើមុខងារ និងតួនាទីមន្ទីរ១៧ នៅក្នុងតំបន់១០៥ នោះមានអ្វីខ្លះ?

**ឆ៖** នៅមន្ទីរ១០៥ ហ្នឹងមានអង្គភាពជាង ជាងរបស់តំបន់ ជាងឡាន កងដឹកជញ្ជូន ហើយនិងក្រុមធ្វើស្រែ ជំនាន់ហ្នឹងគេហៅក្រុមធ្វើស្រែ ក្រុមកងចល័តរបស់តំបន់។

**ស៖** បាទ លោកនិយាយអំពីមន្ទីរ១០៥ ហើយអំមិញនេះខ្ញុំនិយាយអំពីក-១៧។ ខ្ញុំចង់និយាយអំពីមន្ទីរដែលឪពុករបស់លោកជាអ្នកគ្រប់គ្រង គឺថាឪពុកលោកនុំងជាលេខាតំបន់១០៥ ហើយមន្ទីរ ក-១៧ នេះ ខ្ញុំចង់ដឹងថា តើមន្ទីរក-១៧នេះ មានមុខងារអ្វីនៅក្នុងតំបន់១០៥នេះ?

**ឆ៖** ហ្នឹងគេហៅឈ្មោះពីរជំនាន់ហ្នឹងនោះ ក-១៧ ក៏បាន គេហៅតំបន់មកក្រៅ គេហៅ ១០៥ បើថាអ្នកនៅក្នុងស្រុកហ្នឹងគេហៅ ក-១៧។

**ស៖** បាទ អ៊ីចឹងសូមអរគុណ។ ក្រៅពីអង្គភាពរៀបចំដួសជុល ហើយនិងខាងកសិកម្មនេះ តើមានផ្នែកអីផ្សេងទៀតទេ ផ្នែករដ្ឋបាលអីជាដើមនោះនៅក្នុងមន្ទីរក-១៧នេះ ឬក៏នៅក្នុងតំបន់១០៥នេះ?

[១៣:៥២:០២]

**ឆ៖** គេមានផ្នែកៗគេ មានផ្នែកកម្មករ មានផ្នែកសន្តិសុខ វានៅក្នុងតំបន់ ក្នុងមន្ទីរ១០៥ ហ្នឹង ទាំងអស់ តែវាចែកជាខណ្ឌៗតាមផ្ទះដូរៗអ៊ីចឹងទៅ។

**ស៖** តើលោកអាចជម្រាបជូនតុលាការដែរឬទេ ថាតើក-១៧ មានមុខងារទូទៅអ្វីខ្លះនៅក្នុង តំបន់១០៥ទាំងមូល?

**ឆ៖** កាលជំនាន់ហ្នឹងខ្ញុំអត់យល់ដែរ មិនដឹងមានតួនាទីស្អី គ្រាន់តែថាមន្ទីរក-១៧ ហ្នឹងគឺ ខ្មោចឪពុកខ្ញុំហ្នឹងគាត់ -- កន្លែងគាត់ហ្នឹងគេហៅ ក-១៧ រួមទាំងអស់។ ភ្នំក្រោលហ្នឹងគេហៅ១០៥ គេហៅ តែអ៊ីចឹងតែម្តង។

[១៣:៥៣:២០]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ ខ្ញុំសូមបំភ្លឺចំណុចមួយ ហើយនិងសូមដកស្រង់ផ្នែកមួយនៃចម្លើយរបស់លោក ដែលមាន លេខ E3/57 គឺថាទំព័រទី៣ ជាភាសាខ្មែរ គឺ 00287702, ជាភាសាបារាំង គឺទំព័រទី៣ ហើយនិង ជាភាសាអង់គ្លេសក៏ទំព័រទី៣ ដែរ។

បាទ លោកប្រធាន ខ្ញុំសូមអនុញ្ញាតបញ្ចាំងនៅលើអេក្រង់ជូនសាក្សី។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ លោកបាននិយាយដូចតទៅនេះ "ក-១៧ ទទួលបន្ទុកទូទៅនៅតំបន់១០៥ គឺជាកន្លែង ធ្វើសន្និបាតបូកសរុបការងារ រៀនសូត្រផ្នែកយោធា សេដ្ឋកិច្ច ដឹកជញ្ជូន និងពេទ្យ"។ តើលោកនឹក ឃើញអំពីមុខងាររបស់មន្ទីរ ក-១៧ ហើយនិងអំពីកិច្ចប្រជុំដែលបានប្រព្រឹត្តទៅ នៅក្នុងតំបន់១០៥នេះ ដែរឬទេ?

**លោក ផាន វ៉ាន៖**

**ឆ៖** ពិតត្រឹមត្រូវហើយ និយាយពីការគ្រប់គ្រងរួម តែការប្រជុំអីខ្ញុំអត់ដឹងទេ។ ខ្ញុំនៅក្មេង គ្រាន់ ដឹងថា មន្ទីររួមគឺនៅក-១៧ ហ្នឹង ឪពុកខ្ញុំគាត់នៅ គាត់ជាប្រធាន។ នៅក្នុងនុ៎ងគេហៅ១០៥ ហ្នឹងគឺរួម ទាំងអស់មួយភ្នំក្រោលហ្នឹងយ៉ាង តំបន់ខេត្តមណ្ឌលគិរីហ្នឹង គេហៅ ១០៥ ដឹងតែប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ បន្តិចទៀតនេះ ខ្ញុំសូមត្រឡប់មកនិយាយអំពីកិច្ចប្រជុំ ដែលកើតមាន នៅទីនេះ។ លោកនិយាយថា បើឪពុករបស់លោកជាលេខាតំបន់១០៥ តើលោកអាចបញ្ជាក់បានដែរ ឬទេថាតើអ្នកណាខ្លះជាកម្មាភិបាលសំខាន់ៗនៅតំបន់ហ្នឹង? ឧទាហរណ៍ដូចជា គណៈកម្មការ សមាជិក

គណៈកម្មការនៅតំបន់នុ៎ង ឬក៏គណៈកម្មការផ្នែកផ្សេងៗ តើលោកស្គាល់ឈ្មោះ ហើយនិងមុខងាររបស់ពួកគាត់ដែរឬទេ តើមុខងារគាត់នៅក្នុងតំបន់១០៥ នេះ?

[១៣:៥៥:៥២]

**ឆ៖** អ្នកទាំងអស់ហ្នឹងស្លាប់អស់ហើយ ដូចជា ពូសុភា, ពូ អន ស៊ី ,អ៊ំលប អីអីចឹងស្លាប់អស់ហើយ អត់មានអ្នកណានៅរស់ទេ។ នៅរស់តែ បងសារុន មួយទេ ក្នុងគណៈកម្មការតំបន់១០៥ពីមុន។

**ស៖** ហើយក្នុងចំណោមអ្នកដែលស្លាប់ទៅហើយនោះ តើអ្នកអាចឲ្យឈ្មោះអនុប្រធានឪពុកលោក ឬក៏សហការីរបស់ឪពុកលោកដែរឬទេ?

**ឆ៖** អនុប្រធានមានខ្មោច ពូសុភា ហើយខ្មោចលោក ខាំភួន ហើយខ្មោច ពូម៉ី, ពូចាំ នេះនៅចាំឈ្មោះប៉ុណ្ណឹង។ នេះសុទ្ធតែអ្នកស្លាប់អស់ហើយ។

**ស៖** បាទសូមអរគុណ។ ដើម្បីជួយ -- ឲ្យលោកជួយកំណត់អំពីមុខងាររបស់ពួកគាត់ទាំងអស់គ្នា ខ្ញុំសូមអានចម្លើយរបស់លោក គឺឯកសារ E3/57។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកនោះគឺថា ទំព័រ៥ ទំព័រ៦ គឺថា ERN 00287705 ដល់ 06 ។ ទំព័រទី៦ ជាភាសាអង់គ្លេស និងទំព័រ៥ ជាភាសាអង់គ្លេស -- អ៎! ៦ ជាភាសាបារាំង ហើយ ៥ ជាភាសាអង់គ្លេស។ ឥឡូវ ខ្ញុំសូមដកស្រង់លោក “នៅក្រោមឪពុកខ្ញុំ គឺមានតាខាំភួន អនុប្រធានទទួលបន្ទុកផ្នែកនយោបាយ, តាសារុន អនុប្រធាន, ម៉ី អនុប្រធាន ទទួលបន្ទុកខាងអប់រំ, ចាំ អនុប្រធាន, រ៉ា អនុប្រធាន ទទួលបន្ទុកទូទៅ, អន ស៊ី អនុប្រធានជាគណៈស្រុកកែវសីមា, ជួន អនុប្រធាន កាន់ខាងពាណិជ្ជកម្មខេត្ត, សុភា ទទួលខាងយោធាតំបន់, ហៀង (រង សុភា), ឡា (រងយោធា), ម៉ាំង (រងយោធា) និងបុាំង (រងយោធា)” តើអ្វីដែលខ្ញុំទើបនឹងដកស្រង់នេះ ធ្វើឲ្យនឹកឃើញឈ្មោះ ហើយនិងមុខងាររបស់អ្នកដែលខ្ញុំលើកឡើងនេះទេ? លោកចាំទេ?

**ឆ៖** ចាំបាទ ត្រឹមត្រូវហើយ។ ហើយអ្នកទាំងអស់ហ្នឹងស្លាប់អស់ហើយ នៅសល់តែពីរនាក់ទេ នៅសល់តែ បងម៉ាំង ហើយនិង អ៊ំសារុន។ តែពីរនាក់ហ្នឹងទេ ដែលនៅរស់។

[១៣:៥៩:៣៤]

**ស៖** បាទ ត្រង់ចំណុចនេះ ទាក់ទងនឹង តាសារុន នោះ លោកនិយាយថា គាត់ជាអនុប្រធាន។ តើគាត់មានធ្លាប់កាន់តំណែងជាគណៈស្រុកទេ នៅចន្លោះឆ្នាំ១៩៧៥ ដល់៧៧ នៅក្នុងតំបន់១០៥ហ្នឹង?

**ឆ៖** គាត់ធ្លាប់កាន់ធ្វើជាគណៈស្រុកដែរ តែអត់ចាំមិនដឹងស្រុកណា។ បើមិនស្រុកអូររាំង ឬក៏

ស្រុកពេជ្រចិន្តា បាទ។

**ស៖** តើ តាសារុន នោះមកមន្ទីរក-១៧ ញឹកញាប់ដែរឬទេ ដើម្បីចូលប្រជុំជាមួយកម្មាភិបាលផ្សេងទៀត និងជាមួយឪពុកលោកនោះនៅពេលដែលគាត់ធ្វើការនៅស្រុក?

**ឆ៖** គាត់មកញឹកញាប់ដែរ។

**ស៖** នៅក្នុងសម្រង់អម្បាញ់មិញនេះ លោកបានលើកឡើងដែរពីឈ្មោះ អាន ស៊ី ឈ្មោះ អន ស៊ី ដែលជាអនុប្រធាន និងជាគណៈស្រុកកែវសីមានេះ ជាសមាជិកក្រុមគ្រួសារលោកដែរឬទេ?

**ឆ៖** ជាឪពុកមា។

[១៤:០១:២១]

**ស៖** តើ អន ស៊ី នេះស្លាប់ហើយ ឬក៏គាត់រស់រានមានជីវិត ដូចអ្នកទាំងពីរនាក់អម្បាញ់មិញលោកបានលើកឡើងអ្នកដែលរួចផុតរស់រានមានជីវិត រួចផុតពីរបបខ្មែរក្រហម?

**ឆ៖** គាត់ស្លាប់ក្រោយ។

**ស៖** តើនៅក្នុងតំបន់១០៥ មានមន្ទីរមួយឈ្មោះមន្ទីរក-១១ ដែរឬទេ?

**ឆ៖** អត់មានទេ ក-១១។

**ស៖** តើលោកធ្លាប់ឮគេនិយាយអំពីមន្ទីរក-១៦ ដែរឬទេ?

**ឆ៖** ដូចអត់ចាំ។ កាលជំនាន់ខ្ញុំនៅ អត់មានទេ។

**ស៖** តើអ្នកណាដែលជំនួសឪពុករបស់លោក ធ្វើជាប្រធានតំបន់១០៥ បន្ទាប់ពីឪពុកលោកបានចូលមរណភាពទៅនោះ?

**ឆ៖** តាសារុន បាទ។

**ស៖** អម្បាញ់មិញនេះលោកបាននិយាយថា "លោកមិនដឹងថាអ្នក -- ថាគាត់ជាមេស្រុកណានោះទេ តាសារុន នេះ" ប៉ុន្តែខ្ញុំសូមរំឭកប្រាប់លោកថានៅក្នុងចម្លើយរបស់លោក គឺថាឯកសារ E3/57 នៅទំព័រទី៦ ជាភាសាខ្មែរ ERN គឺ 00287705, ទំព័រទី៦ ជាភាសាអង់គ្លេស ហើយនិងទំព័រទី៧ ជាភាសាបារាំង។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយនេះលោកនិយាយថា "គឺតាសារុន ឡើងជំនួសឪពុកខ្ញុំរហូតដល់យួនចូល។ កាលណោះ តាសារុន ជាគណៈស្រុកអូររាំង។ ពេល តាសារុន ឡើងជាគណៈតំបន់១០៥ អ៊ំឡោក ត្រូវបានឡើងជាអនុប្រធានរបស់គាត់រហូតដល់យួនចូល"។ តើសម្រង់នេះលោកអាចៗធ្វើឲ្យលោកនឹកឃើញ គាត់ពិតជាគណៈស្រុកអូររាំងដែរឬទេ?

**ឆ៖** មិនច្បាស់ អាហ្នឹងមិនច្បាស់គណៈស្រុកអូររាំង។ តែគាត់គណៈស្រុក បើមិនអូររាំង ឬពេជ្រចិន្តាដូចខ្ញុំបញ្ជាក់អម្បាញ់មិញ ភ្លេចវាយូរពេក។

**ស៖** បាទ សូមអរគុណ។ លោកបានលើកឡើងអំពីអត្ថភាពពីមន្ទីរ១សន្តិសុខមួយនៅតំបន់១០៥ នៅភ្នំក្រោល។ តើអ្នកណាជាអ្នកគ្រប់គ្រងមន្ទីរភ្នំក្រោលនេះ នៅចន្លោះឆ្នាំ១៩៧៥ និង ១៩៧៧?

[១៤:០៥:០០]

**ឆ៖** ហ្នឹងឈ្មោះ ឡេង។

**ស៖** បាទ ដើម្បីឲ្យច្បាស់លាស់ ដើម្បីជាប្រតិចារឹកនោះ តើលោកអាចអាននូវឈ្មោះ ឡេង ហ្នឹងម្តង ទៀតបានទេ? ឡេង ហ្នឹងជាឪពុករបស់លោក ឬក៏ជាមនុស្សមួយផ្សេងទៀតទេ?

**ឆ៖** នេះផ្សេងបាទ ឡេង។

**ស៖** អម្បាញ់មិញនេះលោកនិយាយថា សុភា ហ្នឹងជាអ្នកទទួលខាងសន្តិសុខ ហើយអ៊ីចឹងសួរថាតើទំនាក់ទំនងរវាង ឡេង និង សុភា នេះយ៉ាងម៉េចដែរ?

**ឆ៖** អត់យល់ពីអត្ថន័យសួរបាទ។

**ស៖** អម្បាញ់មិញលោកនិយាយថា សុភា ជាអ្នកទទួលសន្តិសុខនៅក្នុងតំបន់១០៥ ហើយលោកបានបញ្ជាក់នូវចម្លើយរបស់លោក នៅមុខចៅក្រមស៊ើបអង្កេតថា សុភា ហ្នឹងជាអ្នកទទួលខុសត្រូវនៅតំបន់ហ្នឹងខាងសន្តិសុខ ហើយ ឡេង ដែលជាអ្នកទទួលខុសត្រូវក្នុងមន្ទីរសន្តិសុខហ្នឹង ដែលធ្វើការយ៉ាងស្អិតល្មួតជាមួយ សុភា ហើយ សុភា នេះជាមេបញ្ជាការកងទ័ពនៅតំបន់១០៥ហ្នឹង។ តើទំនាក់ទំនងគាត់ហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** ពូសុភា គាត់ជាប្រធានយោធារួម ទទួលសន្តិសុខ។ ហើយ ឡេង ហ្នឹងគាត់អ្នកអនុវត្តផ្ទាល់ ទទួលនាទីសន្តិសុខផ្ទាល់តែម្តង។

[១៤:០៧:១៥]

**ស៖** តើមានមន្ទីរនៅក្នុងតំបន់១០៥ ដែលមិននៅមណ្ឌលគិរីទេ ប៉ុន្តែនៅភ្នំពេញ តើមានមន្ទីរបែបហ្នឹងទេ ដែលមិននៅមណ្ឌលគិរី តែនៅភ្នំពេញ តើមានទេ? បើមានមុខងារមន្ទីរហ្នឹងអ្វីដែរ?

**ឆ៖** ចង់១សួរម្តងទៀតមើល៍ មន្ទីររបៀបម៉េច? មន្ទីរសន្តិសុខ ឬក៏មន្ទីរស្អីបាទ?

**ស៖** អម្បាញ់មិញខ្ញុំចង់ដឹងថា តើតំបន់១០៥ មានសាខា ឬក៏មន្ទីរដែលមាននៅទីក្រុងភ្នំពេញដែរឬទេ ដែលនៅក្រោមឱវាទ ឬក៏តំណាងឲ្យតំបន់១០៥នោះ ខ្ញុំសួរចង់ដឹងថាតើមន្ទីរបែបហ្នឹងមានដែរ

ឬទេនៅភ្នំពេញ?

**ឆ៖** មាន។

**ស៖** តើសាខា ឬក៏មន្ទីរហ្នឹងមានឈ្មោះកូដ ដែរឬទេ? ហើយមន្ទីរនេះមានមុខងារអ្វីដែរ?

**ឆ៖** មន្ទីរនៅភ្នំពេញមុខងារ គឺចាំទទួលសម្ភារៈ ហើយនិងកម្លាំងមករៀនសូត្រមកស្នាក់នៅកន្លែងមន្ទីររបស់១០៥ នៅមាត់ទន្លេ។

**ស៖** តើគេហៅមន្ទីរហ្នឹងថាជាមន្ទីរពាណិជ្ជកម្ម ឬក៏មន្ទីរហ្នឹងមានឈ្មោះផ្សេងពីនេះ?

**ឆ៖** គេហៅមន្ទីរហ្នឹងជាមន្ទីរពាណិជ្ជកម្ម១០៥ អ៊ីចឹង។

[១៤:០៩:៣១]

**ស៖** នៅពេលដែលកម្មាភិបាលតំបន់១០៥ មកទីក្រុងភ្នំពេញ តើពួកគាត់ស្នាក់នៅហ្នឹងមន្ទីរពាណិជ្ជកម្មតំបន់១០៥ នៅភ្នំពេញហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទមកស្នាក់នៅមន្ទីរពាណិជ្ជកម្ម១០៥។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមត្រឡប់មកនិយាយអំពីកិច្ចប្រជុំដែលលោកមិនសូវដឹងប៉ុន្មានទេ ក៏ប៉ុន្តែលោកដឹងថាមានកិច្ចប្រជុំ ឬការប្រជុំនៅក-១៧។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាកិច្ចប្រជុំ ឬក៏ការប្រមូលផ្តុំមនុស្សនេះ ទ្រង់ទ្រាយធំនៅមន្ទីរក-១៧នេះ ប្រព្រឹត្តទៅញឹកញាប់ប៉ុនណាដែរ ហើយប៉ុន្មានដែរក្នុង១ឆ្នាំ?

**ឆ៖** ញឹក ព្រោះប្រជុំរាល់តែខែ មិនដឹងជាប្រជុំស្អី ព្រោះជំនាន់នុ៎ងអ៊ីចឹងបាទ។

**ស៖** សូមអរគុណ។ នៅក្នុងកិច្ចប្រជុំប្រចាំខែនេះ តើអ្នកណាខ្លះដែលមកពីស្រុកផ្សេងៗ ហើយតើនៅក្នុងស្រុកមួយៗនេះ អ្នកដែលមកចូលរួមនេះមានឋានៈយ៉ាងណាដែរ? ហើយឬក៏មានតែចៅហ្វាយស្រុកទេ ដែលមកចូលប្រជុំនេះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីការពារក្តីលោក អៀង សារី!

[១៤:១១:២៤]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ផ្អែកតាមចម្លើយសាក្សីនេះពីខាងដើម គឺវាហាក់ដូចជាការស្មានបើ

សិនជាឲ្យសាក្សីឆ្លើយនឹងសំណួរនេះ។ គឺជាការពិត ត្រូវតែបង្ហាញមូលដ្ឋាន។ ហើយគាត់បានបញ្ជាក់ហើយថា គាត់មិនបានចូលរួមក្នុងការប្រជុំ ដូច្នេះធ្វើម៉េចគាត់ដឹងថាអ្នកណាខ្លះមានវត្តមានក្នុងពេលប្រជុំទៅ?

[១៤:១១:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១២:៣៦]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯលះ**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ ខ្ញុំគិតថា យើងអាចដឹងថាអ្នកណាចូលរួមនៅក្នុងកិច្ចប្រជុំហ្នឹង អ្នកណាដែលមកចូលប្រជុំនៅ ក-១៧ ហ្នឹងនៅក្នុងតំបន់១០៥។ យើងមិនចាំបាច់ដែលថា គាត់ចូលមកប្រជុំហ្នឹង បានគាត់ដឹងនោះទេ។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់ និងសំអាងហេតុលើសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក អៀង សារី មិនសមស្រប។ សេចក្ដីជំទាស់គ្មានប្រសិទ្ធភាព។ អង្គជំនុំជម្រះត្រូវការស្ដាប់នូវចម្លើយតបរបស់សាក្សីទៅនឹងសំណួរដែលសួរដោយតំណាងសហព្រះរាជអាជ្ញា។ សំណួរចុងក្រោយអម្បាញ់មិញនេះ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯលះ**

**ស៖** បាទ ខ្ញុំសូមសួរឡើងវិញ ព្រោះក្រែង ប្រហែលជាគាត់ភ្លេច។ ដើម្បីឲ្យច្បាស់ថា តើអ្នកណាអ្នកចូលរួមនៅសន្និបាត ឬក៏ប្រជុំប្រចាំខែនៅមន្ទីរក-១៧ តើអ្នកណាដែលមកពីស្រុកនានា ឬក៏មកពីឃុំនានាហ្នឹងមកចូលប្រជុំនៅ ក-១៧ហ្នឹង?

**លោក ផាន វ៉ាន៖**

**ផ៖** មកពីស្រុកនានា។ ជួនកាលចៅហ្វាយស្រុក បើយើងឥឡូវហៅចៅហ្វាយស្រុកទៅ តែពីមុនគេហៅ លេខាស្រុក។ មានប្រជុំលេខាស្រុក មានប្រជុំអនុលេខាស្រុកអីអ៊ីចឹងទៅ។ ដឹងតែប៉ុណ្ណឹង។ ថាប្រជុំរឿងអី ខ្ញុំអត់ដឹងដែរបាទ។

[១៤:១៤:៣២]

**ស៖** នៅពេលដែលលោកនិយាយពីការប្រជុំប្រចាំខែនេះ តើជាការប្រជុំបើកទូលាយជាមួយអ្នកតំណាងឲ្យស្រុកនីមួយៗនោះ ឬក៏ជាកិច្ចប្រជុំរឹតត្បិតសម្រាប់តែអ្នកធ្វើការនៅតំបន់១០៥ ទេ?

**ផ៖** អ្នកធ្វើការក្នុងតំបន់១០៥។

**ស៖** ហើយចៅហ្វាយស្រុកទាំងអស់នោះ គាត់មកប្រជុំនៅក-១៧ នោះញឹកញាប់ប៉ុនណាដែរ រយៈពេលប៉ុន្មានដងដែរ ក្នុងមួយ -- ចំនួនប៉ុន្មានដងដែរក្នុង១ឆ្នាំ?

**ផ៖** វាសឹងតែ -- ជំនាន់ហ្នឹងសឹងតែរាល់ខែ។

**ស៖** តើលេខាស្រុកទាំងអស់នុ៎ងសុទ្ធតែជាសមាជិកគណៈតំបន់១០៥?

**ផ៖** តាមមើលទម្រង់វាជាសមាជិករបស់តំបន់។

**ស៖** បាទ សូមអរគុណដែលបានបំភ្លឺ។ ក្រៅពីកិច្ចប្រជុំទៀងទាត់ទាំងអស់នេះ តើមានវគ្គអប់រំនយោបាយទូលំទូលាយដែលបានប្រព្រឹត្តទៅនៅមន្ទីរក-១៧ ដែរឬទេ?

**ផ៖** មានបាទ។

**ស៖** ហើយអ្នកណាមានសិទ្ធិចូលរួមក្នុងវគ្គអប់រំទាំងអស់នេះ? តើជាកម្មាភិបាលបក្សនៅក្នុងតំបន់១០៥ ឬក៏យ៉ាងណា?

**ផ៖** ភាគច្រើនកម្មាភិបាលបក្សក្នុងតំបន់១០៥។

[១៤:១៧:០៨]

**ស៖** តើមានសាលាអប់រំនៅក្នុងស្រុកនីមួយៗដែរឬទេ? នៅសាលាដែលគេផ្ដល់ការអប់រំនយោបាយនោះ?

**ផ៖** ស្រុកអត់មានទេ ជំនាន់នុ៎ង មានតែនៅភ្នំក្រោលហ្នឹងមួយកន្លែង។

**ស៖** បាទ សូមអរគុណ។ ឥឡូវ ខ្ញុំសូមអានសម្រង់មួយទៀតនៃចម្លើយរបស់លោក ដែលមានលេខកូដ E3/57 នៅទំព័រទី៥ ជាភាសាខ្មែរ ERN 00287704, ជាភាសាបារាំងនៅទំព័រទី៥ និងអង់គ្លេសក៏នៅទំព័រទី៥ ដែរ។ បាទ នេះជាអ្វីដែលលោកនិយាយ "នៅសម័យខ្ញុំជាលេខារបស់ឪពុកខ្ញុំ នៅតំបន់នុ៎ងមានសាលាអប់រំនៅក្នុងតំបន់ ហើយនៅក្នុងស្រុកមានសាលាក្នុងថ្នាក់ស្រុក។ ហើយតាមរយៈការអប់រំរៀនសូត្រនេះ ហើយគេធ្វើស្វ័យទិតៀន ហើយគេរកខ្មាំងតាមរយៈការរាយការណ៍អីជាដើមនេះ"។ តើលោកអាចបំភ្លឺចំណុចនេះ ពេលដែលលោកឆ្លើយទៅសហចៅក្រមស៊ើបអង្កេតនេះ លោកនិយាយថា មានសាលាអប់រំតាមតំបន់ ថ្នាក់តំបន់ ថ្នាក់ស្រុកអីជាដើមនេះ លោកអាចបញ្ជាក់ចម្លើយនេះបានទេ?

[១៤:១៨:៥៩]

**ឆ៖** អាហ្នឹងវា ចង់បញ្ជាក់អ៊ីចេះអារឿងប្រជុំទិតៀន ស្វ័យទិតៀនហ្នឹងវាជារឿងទូទៅ ដែលនៅតំបន់១០៥ហ្នឹង នៅមន្ទីរតំបន់ហ្នឹងមករៀនសូត្រហើយបានគេកងសាងស្វ័យទិតៀននៅហ្នឹង។ អាហ្នឹងជាធម្មតាទៅហើយជំនាន់ហ្នឹង។ ឯតាមស្រុកនុំងវាមិនមែនជាសាលាទេ គ្រាន់តែអប់រំ ប្រជុំទិតៀនស្វ័យទិតៀនវាជាធម្មតាដែរ។ វាជាទម្លាប់អ៊ីចឹងទៅហើយ របៀបរបបធ្វើការងារគេនោះវាអ៊ីចឹង។ គឺដាច់មិនបានទេអារឿងប្រជុំទិតៀន ស្វ័យទិតៀន។ ហ្នឹងសូមបញ្ជាក់បណ្ណឹងបាទ។

**ស៖** តើលោកផ្ទាល់នេះ លោកធ្លាប់ចូលរួមវគ្គអប់រំបន្ថែមពីលើវគ្គស្វ័យទិតៀន នៅមន្ទីរក-១៧ ដែរឬទេ?

**ឆ៖** អានោះ ធ្វើតាមៗមុខងាររបស់ខ្លួនហ្នឹងធ្លាប់ធ្វើដែរ ប៉ុន្តែមិនបានចូលក្នុងសមាជិកធំអីហ្នឹងគេទេ គឺថា អ្នកទូទៅក៏ស្វ័យទិតៀនដូចតែគ្នា វាអ៊ីចឹង។ ចង់បញ្ជាក់ តាំងពីពួកៗក្រុមឡើងទៅហ្នឹងគេស្វ័យទិតៀនទាំងអស់។ ហ្នឹង ដែលសូមបញ្ជាក់ជូនប៉ុណ្ណឹងបាទ។

[១៤:២០:៤០]

**ស៖** នៅក្នុងសម្រង់អំមិញនេះ លោកនិយាយថា តាមរយៈការអប់រំរៀនសូត្រ និងធ្វើស្វ័យទិតៀន ហ្នឹងគេរកខ្មាំងឃើញ។ តើហេតុអ្វីបានជាមានសារៈសំខាន់ក្នុងការកំណត់រកខ្មាំងនោះនៅក្នុងតំបន់១០៥?

**ឆ៖** ខ្ញុំអត់យល់ដែរអាបញ្ហាហ្នឹង ព្រោះកាលជំនាន់ហ្នឹងវាអ៊ីចឹង វាទម្លាប់ទូទៅអ៊ីចឹងតែម្តង។ ឲ្យតែចោទប្រជុំទិតៀន ស្វ័យទិតៀនគ្នាអី អាណាអត់ឯកភាព អាហ្នឹងគេចោទថាខ្មាំងអ៊ីចឹងតែម្តង មិនដឹងធ្វើយ៉ាងម៉េច។

**ស៖** តើមានការបញ្ជាក់ដែរឬទេ ក្រៅពីកិច្ចប្រជុំស្វ័យទិតៀននោះ? ក្រៅពីអ្នកដែលថា ជំទាស់ពេលធ្វើស្វ័យទិតៀននេះ តើមានអ្នកណាខ្លះដែលជាខ្មាំងរបស់បក្ស?

**ឆ៖** កាលជំនាន់ហ្នឹងខ្ញុំអត់ដឹងដែរ មិនដឹងអ្នកណាគេកំណត់ថាជាខ្មាំងរបស់បក្សទេ ប៉ុន្តែឃើញបាត់ខ្លួនអ្នកដឹកនាំក្នុងតំបន់អ៊ីចឹង មកក្រោមអ៊ីចឹងបាត់ទៅ គេប្រកាសថាក្បត់អីអ៊ីចឹងទៅ ឮតែអ៊ីចឹង។

[១៤:២២:៤៤]

**ស៖** បាទ លោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេតថា តាមពិតមានក្រមសីលធម៌ ដែលមាន១២ប្រការ ហើយគេដាក់ក្នុងហោប៉ៅ គ្រាន់ទុកសម្រាប់អាន។ ជាបឋម តើមុននឹងដឹងថា អ្នកដែលមិនគោរពសីលធម៌ទាំង១២ប្រការនោះ តើអ្នកណាខ្លះដែលគេចាត់ទុកថា ជាខ្មាំង?

**ផ៖** កាលជំនាន់ហ្នឹង គេមិនកំណត់ខ្នាំងហ្នឹងទាំងអស់ទេ អាហ្នឹងវា -- ឧបមាទេ ឧបមាថា យើងអត់គោរពវិន័យអីអ៊ីចឹង អាហ្នឹងគេថាខ្នាំងសតិអារម្មណ៍ មិនដឹងគេដកទៅណាទីណាទេ វាអ៊ីចឹង។

**សៈ** បាទ សូមអរគុណ។ លោកទើបនិយាយអំពីខ្នាំងច្រើនប្រភេទ។ អ៊ីចឹងក្រៅពីខ្នាំងសតិអារម្មណ៍នោះ តើមានខ្នាំងប្រភេទអីផ្សេងទៀតទេ លោកអាចឲ្យជាឧទាហរណ៍បានទេ?

**ផ៖** ឧទាហរណ៍ដូច ខ្ញុំគ្រាន់ជម្រាបព្រះរាជអាជ្ញាអំមិញអ៊ីចឹងគឺថា ខ្នាំងសតិអារម្មណ៍នោះ ទស្សនៈ ខ្នាំងទស្សនៈរបស់យើងខុសពីទិសដៅរបស់គេ អាហ្នឹងគេថាខ្នាំងដែរ។ ហ្នឹងវាអ៊ីចឹង មិនដឹងគេឧបមាម៉េច ព្រោះខ្ញុំអត់យល់ដែរអារឿងពាក្យថា "ខ្នាំង" ហ្នឹង។ ខ្នាំងៗ ថាតាមខ្នាំងវាទៅ ជំនាន់ហ្នឹង។

[១៤:២៤:៤៥]

**សៈ** បាទ សូមអរគុណ។ តើលោកអាចពន្យល់ឲ្យបានលើសពីនេះ អំពីសីលធម៌ទាំង១២ប្រការនេះដែរឬទេ? តើលោកក្នុងចំណោមប្រការទាំង១២នេះ លោកដឹងថា ប្រការណាមួយដែលយើងមិនត្រូវរំលោភបំពានទាល់តែសោះ បានដែរឬទេ?

**ផ៖** ប្រការទាំង១២ ខ្ញុំចាំអត់អស់ទេ ឥឡូវវាយូរហើយ។ សំខាន់សីលធម៌ការរស់នៅ ជំនាន់វាដំបូងល្អណាស់សីលធម៌១២ប្រការហ្នឹង អ្នកអនុវត្តល្អគឺប្រជាជនគាំទ្រ តែក្រោយមកក្រឡែ ក្រោយពីនេះមកវាៗដូចខ្ញុំថាអ៊ីចឹង ស្អីក៏ខ្នាំងៗ។ ដល់អ៊ីចឹងអាសីលធម៌ទាំង១២ប្រការហ្នឹង លែងៗអនុវត្តទៅក្រោយ។ បើថាអនុវត្តតាមសីលធម៌១២ប្រការ ឧបមាដូច មិនចេះលួច មិនចេះប្លន់ មិនចេះមានស្នេហាយអ៊ីចឹងទៅ គ្មានស្រី គ្មានញី ប្រពន្ធមួយអ៊ីចឹងទៅ។ ឃើញព្រះសង្ឃចេះគោរព ចេះអ៊ីចឹងទៅ វាអាហ្នឹងវាល្អ។ ហើយក្រោយមក វាមិនទៅអ៊ីចឹងឯណា។ ដល់អ៊ីចឹងក្រោយមក មិនគោរពតាមសីលធម៌១២ប្រការទេ ដល់អ៊ីចឹងវាបែកឆ្វេងអស់ទៅ។ សូមបញ្ជាក់ប៉ុណ្ណឹងទេបាទ។

[១៤:២៦:០៤]

**សៈ** បាទ សូមអរគុណ។ តើគេមានសុំឲ្យកម្មាភិបាលសរសេរប្រវត្តិរូបរបស់ខ្លួនជាទៀងទាត់ដែរឬទេ?

**ផ៖** មានបាទ។

**សៈ** តើលោកដឹងថាពាក្យថា "ប្រវត្តិរូបស្អាតស្អំ" នៅក្នុងអំឡុងរបបខ្មែរក្រហមនេះ មានន័យយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំអត់យល់ដែរជំនាន់ហ្នឹងបាទ។ ឮថាស្អាត ហើយរស់នៅឲ្យសមរម្យ គេនិយាយតែប៉ុណ្ណឹង ហើយអត់មានកម្មសិទ្ធិអីៗ កម្មសិទ្ធិសមរម្យ មានតែស្បោងមួយតូច គេឧទាហរណ៍តែប៉ុណ្ណឹង។ ខោអាវមានតែពីរកំប្លេអ៊ីចឹងទៅ មានប៉ុណ្ណឹងទេបាទ។

**ស៖** បាទ សូមអរគុណ។ មុននឹងចោទសំណួរលើការងាររបស់លោកដោយផ្ទាល់ ហើយនិងការងារផ្នែកទំនាក់ទំនងតាមទូរលេខ ខ្ញុំចង់ចោទសួរសំណួរទៅលោកទាក់ទងបងប្អូនរបស់លោក។ តើលោកអាចប្រាប់ឈ្មោះបងប្អូនរបស់លោកដែរឬទេ ដោយឲ្យឈ្មោះបដិវត្តន៍ជាដើម គឺថាលោកអាចចាប់ផ្ដើមរៀបរាប់ពីបងប្អូនដែលអាយុតិចជាង ទៅដល់អាយុច្រើនជាងគេ ឬក៏បញ្ច្រាស់មកវិញ?

**ឆ៖** បងប្អូនៗបង្កើតអ៊ីចឹងមែនទេ ខ្ញុំចង់សួរបញ្ជាក់។ មានប្អូនៗពៅមួយនៅ -- ឈ្មោះ ធាតុ ឈ្មោះតាំងពីកើតមករហូតដល់រាល់ថ្ងៃហ្នឹង។ ហើយ ធី, ហើយបាន ឡា, ហើយបាន បងធិ, បងហាន និងរូបខ្ញុំផ្ទាល់ ហើយ វ៉ាន់នី មួយទៀត ប្រុស។ នេះបងប្អូនទាំងអស់ប្រុសបួន ស្រីបី។ សរុបទាំងអស់ប្រាំពីរនាក់។

[១៤:២៩:០១]

**ស៖** ខ្ញុំគិតថាប្រហែលជា -- លោកៗមានបងស្រី១ ឈ្មោះ ផាន សុវណ្ណ ហាន ដែរឬទេ?

**ឆ៖** មានបាទ ឈ្មោះ ហាន អំមិញ។

**ស៖** តើឈ្មោះរហស្សនាមរបស់គាត់ហ្នឹង ឈ្មោះហៅក្រៅរបស់គាត់ហ្នឹង ហៅ បុប្ផា មែនទេ?

**ឆ៖** អត់ទេឈ្មោះៗ ហាន ហ្នឹងហៅរាល់ថ្ងៃ។ បើឈ្មោះដើម ឈ្មោះ បូផាន់។

**ស៖** បាទ សូមអរគុណ។ តើបងស្រីរបស់លោកហ្នឹង ធ្លាប់បានធ្វើការឲ្យឪពុកលោកនៅតំបន់១០៥ ដែរឬទេ? ហើយបើគាត់ធ្វើការនៅទីនោះៗ គាត់មានមុខងារអ្វីដែរ?

**ឆ៖** គាត់ធ្វើការឲ្យឪពុកខ្ញុំដែរ ក្រោយមកធ្វើការបានមួយរយៈខ្លីទេ។ នៅបកសារទូរលេខដែរ។

**ស៖** សូមអរគុណ។ លោកបាននិយាយអំពីបងស្រីរបស់លោកឈ្មោះ ធិ តើគឺឈ្មោះ ផាន ធិ កើតនៅក្នុងឆ្នាំ១៩៥៩ ហ្នឹងតើមែនទេ?

**ឆ៖** បាទឈ្មោះ ធិ ហ្នឹងហើយបាទ។

**ស៖** តើគាត់ធ្លាប់ធ្វើការនៅតំបន់១០៥ ជាមួយឪពុកលោកដែរឬទេ?

**ឆ៖** អត់ទេ អត់ដែលនៅស្រុកទេ។

**ស៖** អ៊ីចឹងនៅក្នុងរបបខ្មែរក្រហមនោះគាត់នៅធ្វើការនៅកន្លែងណាដែរ សូមឆ្លើយដោយសង្ខេប។

**ឆ៖** ខ្ញុំអត់ច្បាស់ដែរ កាលនោះគាត់នៅជាមួយ តាធុច។ ហើយក្រោយមកមិនជាគាត់នៅឯណា ក្រោយមក។

[១៤:៣១:៣៥]

**ស៖** បាទ សូមអរគុណ។ តើប្អូនប្រុសរបស់លោក ឈ្មោះ វ៉ាន់ នី ធ្វើការនៅឯណាដែរ?

**ឆ៖** សព្វថ្ងៃនៅស្រុក។

**ស៖** តាមពិតខ្ញុំចង់ដឹងនៅថានៅក្នុងអំឡុងរបបខ្មែរក្រហមនោះ វ៉ាន់ នី ធ្វើការនៅឯណាដែរ?

**ឆ៖** វ៉ាន់ កាលហ្នឹងនៅជាមួយតា ប៉ុល ពត ឬនៅឯណាទេ ខ្ញុំមិនច្បាស់ដែរ ប៉ុន្តែនៅមន្ទីរនៅមន្ទីរកន្លែងតា ប៉ុល ពត។

**ស៖** នៅក្នុងចម្លើយរបស់លោកដែលលោកឆ្លើយទៅសហចៅក្រមស៊ើបអង្កេត លោកនិយាយថា វ៉ាន់ នី នេះត្រូវ ប៉ុល ពត យកទៅធ្វើជាកូនចិញ្ចឹម។ តើឪពុករបស់លោក លោក ឡាំង នេះជិតស្និទ្ធនឹង ប៉ុល ពត ដែរឬទេ នៅក្នុងដំណាក់កាលតស៊ូមុននឹងដណ្ដើមបានយកអំណាចនៅក្នុងឆ្នាំ១៩៧៥?

**ឆ៖** តាមខ្ញុំដឹង អង្កាល់ជំនាន់គាត់រត់ចូលព្រៃហ្នឹង គាត់រត់ទៅមណ្ឌលហ្នឹង គាត់ឆ្លងកាត់ឪពុកខ្ញុំក៏ស្គាល់ ស្គាល់គាត់ មិនដឹងស្និទ្ធប៉ុនណា ខ្ញុំអត់យល់ច្បាស់ដែរទេ គ្រាន់តែថាស្គាល់ ព្រោះគាត់តំណាងនៅមណ្ឌលគិរីហ្នឹង។

[១៤:៣៣:៤០]

**ស៖** បាទ សូមអរគុណ។ ឥឡូវសូមត្រឡប់មកនិយាយអំពី ផាន សុវណ្ណ ហាន ហៅ បុប្ផា។ តើគាត់ធ្វើការផ្នែកទូរលេខ ឲ្យឪពុកលោកក្នុងពេលដែលលោកធ្វើការនៅទីនោះដែរ ឬក៏ក្រោយមកទេ?

**ឆ៖** ក្រោយមកទេ។

**ស៖** លោកបានឆ្លើយទៅនឹងសហចៅក្រមស៊ើបអង្កេតថាលោកជាអ្នកបកប្រែទូរលេខ ហើយលោកជានីរសារផ្ទាល់របស់ឪពុកលោក។ តើលោកជាលេខារបស់ឪពុកលោកដែរឬទេ?

**ឆ៖** ខ្ញុំអត់យល់ពាក្យ"លេខា"ទេ។ ជំនាន់ហ្នឹងមិនមែនលេខាទេ គេហៅគ្រាន់តែអ្នកបកសារ ហើយនិងបើកឡាន។

**ស៖** សូមអរគុណ។ ក្នុងឋានៈលោកជានីរសារហើយនិងអ្នកបើកឡាន ហើយលោកបាននិយាយអម្បាញ់មិញថា លោកក៏ជាអ្នកបកប្រែទូរសារដែរ ហើយក្នុងឋានៈជានីរសារនេះ លោកយកសារទៅឲ្យអ្នកណានៅក្នុងតំបន់១០៥ នៅក្នុងខណៈដែលលោកធ្វើការនៅមន្ទីរ ក-១៧នេះ?

**ឆ៖** នៅជំនាន់ហ្នឹង ន័យនីរសារមិនមែនបានន័យថា ចាំតែយកសារសំបុត្រអីទេ។ នីរសារនៅលើកងការពារ ដូចថាគេប្រើឲ្យទៅនេះ ទៅនោះ គេហៅនីរសារទាំងអស់។ អត់មានបានន័យថាទាល់តែយកក្រដាសបាននីរសារ អត់ទេ។ ចង់បញ្ជាក់ ហើយឲ្យយល់អ៊ីចឹង។

**ស៖** បាទ សូមអរគុណដែលបានបំភ្លឺនេះ ក៏ប៉ុន្តែក្នុងឋានៈលោកជានីរសារ ទោះបីជាថាលោកជាអ្នកការពារឪពុកលោកក៏ដោយ តើលោកធ្លាប់យកសារទៅឲ្យកម្មាភិបាលមួយចំនួននៅក្នុងតំបន់១០៥ដែរឬទេ?

**ឆ៖** ធ្លាប់យកឲ្យចៅហ្វាយស្រុក ចៅហ្វាយអីហ្នឹង ដូចហៅគេមកប្រជុំ យកសំបុត្រយកទៅឲ្យគេអ៊ីចឹងទៅ។ ដឹកគេមកប្រជុំ មកអីអ៊ីចឹងទៅ មកមន្ទីរតំបន់អ៊ីចឹងទៅ។

**ស៖** សូមអរគុណ។ តើលោកចង់និយាយអំពីចៅហ្វាយស្រុកណា ពេលលោកយកសារទៅឲ្យចៅហ្វាយស្រុកនោះ តើចៅហ្វាយស្រុកមួយណា? តើមានចៅហ្វាយស្រុកតែមួយទេ ឬក៏ចៅហ្វាយស្រុកទាំងប្រាំនៅតំបន់១០៥ នោះ?

**ឆ៖** ចៅហ្វាយស្រុកទាំងប្រាំហ្នឹង ស្រេចតែគាត់ប្រើទេ បើប្រើទៅស្រុកណា ទៅស្រុកហ្នឹង។ អាហ្នឹងបញ្ជាក់ អារឿងនីរសារអ៊ីចឹងបាទ។

[១៤:៣៧:៣១]

**ស៖** តើមានផ្នែកទូរលេខនៅតាមស្រុកដែរឬទេ? តើមានសារដែលគេផ្ញើចេញពីស្រុកទៅក-១៧ ដែរឬទេ? ឬក៏មានតែសារដែលសរសេរជាលាយលក្ខណ៍អក្សរទេ ដែលផ្ញើចេញពីថ្នាក់ស្រុក?

**ឆ៖** ជំនាន់ហ្នឹងតាមស្រុកនៅមណ្ឌលគិរីអត់មានទេ អត់មានទូរលេខទេ មានតែប្រើសំបុត្រ។

**ស៖** សូមអរគុណ។ តើសំបុត្រ ឬក៏សារដែលផ្ញើទៅតាមស្រុក ឬក៏ចេញពីស្រុកមកវិញ សុទ្ធតែជាសារដែលគេបំភ័ន្តអក្ខរៈដែរឬទេ?

**ឆ៖** បើពីស្រុកមក អត់មានបំភ័ន្តអក្ខរៈទេ សំបុត្រធម្មតា។ ប៉ុន្តែគេដាក់ស្រោមអ៊ីចឹងទៅ យើងអត់មានសិទ្ធិមើលទេ។

**ស៖** លោកប្រធាន ខ្ញុំសូមសួរសំណួរចុងក្រោយ។ តើឪពុកលោកទៅភ្នំពេញញឹកញាប់ដែរឬទេនៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៧?

**ឆ៖** ញឹកដែរបាទ។ ញឹកអាពេលវៀតណាមវ៉ៃខ្លាំងហ្នឹង បានមកញឹក។

[១៤:៣៩:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះដល់ពេលវេលាសមល្មមសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសមស្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤០ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:២៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងព្យាយាមទៅឲ្យបានលឿន ហើយខ្ញុំនឹងព្យាយាមធ្វើម៉េចសួរឲ្យបានច្រើនពាក់ព័ន្ធនឹងចំណុចដែលខ្ញុំចង់សួរនៅថ្ងៃនេះ ហើយនិងថ្ងៃស្អែក។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** សំណួរចុងក្រោយនោះ ខ្ញុំចង់ដឹងថា តើឪពុករបស់លោកទៅភ្នំពេញញឹកញាប់ដែរឬទេ? ហើយលោកឆ្លើយថា “ទៅ”។ អ៊ីចឹងខ្ញុំចង់ដឹងថា តើឪពុកលោកទៅតែម្នាក់ឯងទេ ទៅភ្នំពេញហ្នឹង ឬក៏មានកម្មាភិបាលផ្សេងទៀតនៃតំបន់១០៥នុ៎ង អមដំណើរទៅជាមួយគាត់ដែរ?

[១៥:០៣:២២]

**លោក ផាន វ៉ាន៖**

**ផ៖** ទៅម្នាក់ឯង ជួនកាលទៅពីរនាក់អ៊ីចឹងទៅបាទ អត់ទៀងដែរ។

**សៈ** ក្នុងឋានៈលោកជានីរសា ហើយនិងអ្នកអង្គរក្សការពារគាត់ តើលោកអមដំណើរឪពុកលោកជាញឹកញាប់ដែរឬទេ នៅពេលដែលឪពុកលោកឡើងទៅភ្នំពេញ ទៅចូលរួមក្នុងកិច្ចប្រជុំនានានោះ?

**ឆៈ** មកត្រឹមមន្ទីរពាណិជ្ជកម្មនៅភ្នំពេញ នៅចាំគាត់នៅហ្នឹងបាទ។

**សៈ** ខ្ញុំចង់ដឹងថា តើលោកទៅញឹកញាប់ដែរឬទេទៅភ្នំពេញនុ៎ង? ខ្ញុំដឹងថាលោកមិនចូលរួមប្រជុំទេ ក៏ប៉ុន្តែលោកជូនឪពុករបស់លោកទៅមន្ទីរពាណិជ្ជកម្មហ្នឹង ញឹកញាប់ដែរឬទេ?

**ឆៈ** មករាល់លើក មករាល់តែលើក តែគាត់មកគឺត្រូវតែមកអ៊ីចឹង។

[១៥:០៤:៤០]

**សៈ** តើលោកអាចបញ្ជាក់បានទេថា អ្នកណាជាអ្នកកោះហៅឪពុកលោក មកប្រជុំនៅភ្នំពេញនោះ?

**ឆៈ** ជំនាន់ហ្នឹងអត់ដឹងដែរ ដឹងថា ខាងលើៗ។

**សៈ** សូមអរគុណ។ យើងនឹងត្រឡប់មកនិយាយ អំពីបញ្ហានេះនៅពេលក្រោយ។ តើលោកចាំទេថា ឪពុកលោក និងលោកផ្ទាល់ទៅភ្នំពេញមួយខែ ក្រោយរំដោះភ្នំពេញថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ គឺមានន័យថា ខែឧសភា ឆ្នាំ៧៥ នោះ តើលោកចាំថា លោកបាននាំឪពុកលោកមកទីក្រុងភ្នំពេញទេ?

**ឆៈ** ចាំបាន មក។

[១៥:០៦:២៣]

**សៈ** តើលោកអាចប្រាប់បានទេថា ឪពុកលោកពេលនោះបានចូលរួមក្នុងមហាមីទ្ទិង ឬក៏ក្នុងកិច្ចប្រជុំប្រភេទអ្វីដែរ នៅខែឧសភា ឆ្នាំ៧៥ នោះ?

**ឆៈ** អត់ចាំដែរ មិនដឹងជាគាត់មកមហាមីទ្ទិងអី ចូលឆ្នាំក៏មកដែរកាលនោះ។

**សៈ** នៅពេលដែលឪពុកលោកទៅភ្នំពេញ នៅខែឧសភា ឆ្នាំ៧៥ តើ តាសារុន មានអមដំណើរគាត់ទេ?

**ឆៈ** អត់ចាំដែរ អង្កាល់ហ្នឹងដូចមក អ៊ំសារុន មកបាទ។ ហ្នឹងអត់ប្រាកដដែរ តាមមើលមកអត់នេះទេ។

**សៈ** តើលោកចាំទេថា មហាមីទ្ទិងនោះប្រព្រឹត្តទៅនៅទីណាដែរ កាលពីខែឧសភា ឆ្នាំ៧៥ នៅទីក្រុងភ្នំពេញនោះ?

**ឆៈ** ចាំបានកាលហ្នឹង ដូចនៅស្តាត បាទ។

[១៥:០៧:៣៦]

**ស៖** សូមអរគុណ។ ចុះចំពោះលោកផ្ទាល់នោះ ពេលនុង តើលោកទៅស្គាត់ជាមួយឪពុកលោកដែរឬទេ?

**ឆ៖** អត់បានទៅទេ ទៅពេលយប់ ជំនាន់ហ្នឹងគេដើរលេង ដើរយប់ ទៅមើលសិល្បៈមើលអីយប់។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចង់និយាយអំពីប្រភេទនៃកិច្ចប្រជុំផ្សេងទៀត។ តើជាទូទៅក្នុងចំណោមមេដឹកនាំបក្ស ឪពុកលោកតែងតែមកជួបអ្នកណាខ្លះ នៅទីក្រុងភ្នំពេញនោះ ប្រសិនបើលោកដឹង?

**ឆ៖** អត់ដឹងដែរ ជំនាន់ហ្នឹង។

[១៥:០៨:៣៥]

**ស៖** តើលោកដឹងទេថាឪពុករបស់លោកទៅកន្លែងណាដែរ ដើម្បីចូលរួមក្នុងកិច្ចប្រជុំនានានោះ?

**ឆ៖** អត់ដឹងទេបាទ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំចង់អានសម្រង់នៃកំណត់ហេតុសម្ដាប់ចម្លើយរបស់សាក្សី ដែលមានលេខ E3/57, ទំព័រ៥ ជាភាសាខ្មែរ 00287704, ជាភាសាបារាំង ទំព័រ៥ ជាភាសាអង់គ្លេស ទំព័រ៤។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** សំណួរគឺថា “តើលោកធ្លាប់ទទួលទូរលេខពីការបោសសម្អាតជនជាតិចាម វៀតណាមដែរឬទេ?” ឆ្លើយ “កាលនោះមិនមានទេ បើមានការបោសសម្អាត មានតែនៅមហាសន្និបាត នៅពេលរៀនគោលនយោបាយនៅភ្នំពេញឯណោះទេ។ ភាគច្រើន គេហៅគណៈតំបន់ និងគណៈស្រុកទៅរៀនសូត្រនៅមជ្ឈិម”។ ជាភាសាអង់គ្លេស ប្រហែលជាបកមានកំហុសបន្តិច។ “គណៈតំបន់ និងគណៈស្រុកគេផ្លាស់វេនគ្នាទៅរៀននៅក-៣”។ សូមបញ្ចប់ការដកស្រង់។ លោកសាក្សី តើខ្ញុំអាននេះធ្វើឲ្យលោកនឹកឃើញថាមានគណៈតំបន់ និងគណៈស្រុកដែលទៅរៀនសូត្រជាញឹកញាប់នៅក-៣ ដែរឬទេ?

**ឆ៖** នេះសូមៗបញ្ជាក់ថាអត់ៗច្បាស់ទេ ដែលខ្ញុំប្រាប់ហ្នឹង គ្រាន់ថា មករៀនៗសូត្រហ្នឹង មក -- ហើយតួនាទីខាងខ្ញុំមកបានត្រឹមតែកន្លែងពាណិជ្ជកម្ម១០៥។ ហើយឡានខាងនីរសារហ្នឹង គេមកយកពីហ្នឹងទៅ។ សូមបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** បាទ សូមអរគុណ។ ក្រៅពីកិច្ចប្រជុំ តើឪពុករបស់លោក តាឡាំង នោះធ្លាប់ទៅភ្នំពេញក្នុងអំឡុងបុណ្យទាន។ ឧទាហរណ៍ដូចជាថ្ងៃទី១៧ មេសា ឬក៏ថ្ងៃទី៣០ ខែកញ្ញា រៀងរាល់ឆ្នាំដែរឬទេ?

**ធ៖** ទៅបាទ។

[១៥:១១:៣២]

**ស៖** តើចំពោះលោកផ្ទាល់នោះ លោកធ្លាប់ទៅស្តាតដើម្បីមើលការសម្តែងសិល្បៈផ្សេងៗនៅក្នុងថ្ងៃទី១៧ មេសា ឬក៏ថ្ងៃទី៣០ កញ្ញា ដែរឬទេ?

**ធ៖** អង្គាល់នៅតំបន់ទៅតែម្តង។

**ស៖** ក្នុងចំណោមមេដឹកនាំដែលលោកស្គាល់នៅប-២០ តើអ្នកណាជាអ្នកឡើងថ្លែងសុន្ទរកថានៅក្នុងពេលពិធីបុណ្យធំៗនោះ?

**ធ៖** កាលជំនាន់ហ្នឹង ឃើញ អ៊ំប៉ុល ពត ឡើង។

**ស៖** តើឪពុករបស់លោក និងលោកផ្ទាល់នោះធ្លាប់ចូលរួមវគ្គនយោបាយនៅបុរីកីឡាដែរឬទេ?

**ធ៖** ខ្ញុំអត់ដែរទេបាទ។ តែឪពុកខ្ញុំមិនដឹងយ៉ាង -- មិនដឹងម៉េចទេ មិនដឹងគាត់ទៅហ្នឹង ឬយ៉ាងម៉េច អត់ដឹងដែរ។

**ស៖** សូមអរគុណ។ នៅពេលដែលឪពុកលោកត្រឡប់ពីភ្នំពេញវិញ ក្រោយពេលប្រជុំរួច តើឪពុករបស់លោក តែងតែកោះប្រជុំនៅតំបន់១០៥ ដើម្បីពន្យល់ជូនកម្មាភិបាល និងសមាជិកគណៈតំបន់១០៥ អំពីសេចក្តីណែនាំផ្សេងៗដែលគាត់ទទួលបានពីកិច្ចប្រជុំនៅទីក្រុងភ្នំពេញដែរឬទេ?

[១៥:១៣:៣១]

**ធ៖** ធ្វើបាទ ឲ្យតែមកពីធ្វើការភ្នំពេញ ត្រូវតែកោះហៅខាងស្រុកមកគ្រប់តែស្រុក រាល់លើកបាទ។

**ស៖** តើលោកដឹងទេថាកិច្ចប្រជុំទាំងនោះនិយាយអំពីអ្វីដែលផ្ទុះបញ្ជាំងអំពីសេចក្តីណែនាំផ្សេងៗ ឬក៏បទបញ្ជាដែលទទួលពីទីក្រុងភ្នំពេញនោះ?

**ធ៖** អត់បានដឹងទេបាទ គ្រាន់តែឃើញចៅហ្វាយស្រុក ចៅហ្វាយអីមក ដឹងតែប៉ុណ្ណឹងបាទ។

**ស៖** ក្រៅពីឪពុករបស់លោក និងកម្មាភិបាលដែលអមដំណើរឪពុករបស់លោកទៅទីក្រុងភ្នំពេញ តើមានកម្មាភិបាលតំបន់១០៥ ផ្សេង -- កម្មាភិបាលផ្សេងទៀត ខ្ញុំចង់សំដៅថា ក្រៅពីឪពុករបស់លោកនោះ ធ្លាប់មានកម្មាភិបាលផ្សេងទៀតនៅតំបន់១០៥ នោះមកចូលរួមកិច្ចប្រជុំនៅទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** មាន១ អនុប្រធាន ហើយនិងអនុប្រធានទី១ ទី២ ភាគច្រើនទី១ និងទី២បាទ។

[១៥:១៥:១៧]

**ស៖** តើកម្មាភិបាលតំបន់១០៥ ដែលត្រូវបានកោះឲ្យមកប្រជុំនៅទីក្រុងភ្នំពេញនោះ ធ្លាប់មានថាកោះទៅហើយ មិនត្រឡប់មកតំបន់១០៥ វិញដែរឬទេ?

**ឆ៖** មាន។

**ស៖** ខ្ញុំមិនទាន់បានស្តាប់ឮការបកប្រែជាភាសាបារាំងទេ។ សូមឲ្យលោកសាក្សីឆ្លើយម្តងទៀត។

**ឆ៖** មានបាទ។

**ស៖** បើតាមលោកដឹង ព្រោះថាលោកធ្វើនៅផ្នែកទូរលេខ តើអ្នកណាជាអ្នកកោះហៅកម្មាភិបាល១០៥ ដែលមិនត្រឡប់មកវិញនោះ អ្នកណានៅមជ្ឈិមដែលជាអ្នកធ្វើទូរលេខហៅកម្មាភិបាលតំបន់១០៥ ឲ្យមកប្រជុំនៅភ្នំពេញនោះ?

**ឆ៖** ខ្ញុំមិនដឹង អត់ដឹងថាអ្នកណាទេ គ្រាន់ភាគច្រើនសរសេរតែលេខ ៨៧០១។

[១៥:១៧:០០]

**ស៖** សូមអរគុណ។ បាទ មានន័យថាទូរលេខផ្ញើពីតំបន់ទៅ៨៧០។ ខ្ញុំចង់ដឹងថាពី -- ទូរលេខមកពីមជ្ឈិម តើបុគ្គលជាក់លាក់ណានៅ៨៧០ហ្នឹង ដែលផ្ញើទូរលេខពីមជ្ឈិមទៅកាន់តំបន់របស់លោកនោះ?

**ឆ៖** ភាគច្រើនអត់មានបញ្ជាក់ឈ្មោះទេ។ ដាក់តែ៨៧០ អ៊ីចឹងទៅ។

**ស៖** សូមអរគុណ។ ខ្ញុំនឹងអានសម្រង់នៃកំណត់ហេតុរបស់លោក គឺលេខ E3/58 នេះគឺជាកំណត់ហេតុទី១ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨, ទំព័រ៤ ជាភាសាខ្មែរ ERN 00239937, បារាំងទំព័រ ៤, ភាសាអង់គ្លេសក៏ទំព័រ៤ដែរ។ នេះជាចម្លើយរបស់លោកដែលបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត៖ “ក្រៅពីនេះ នួន ជា បានផ្ញើសារអង្គុលីលេខមកឲ្យថ្នាក់តំបន់ ដូចជាតា សុភា សមាជិកតំបន់ទទួលខាងយោធា ឬប្រធានយោធាតំបន់ ឬឪពុករបស់ខ្ញុំ និងអ្នកផ្សេងៗទៀតទៅរៀនសូត្រនៅភ្នំពេញ។ ឪពុករបស់ខ្ញុំនិងតា ខាំភួន អនុតំបន់ត្រូវសម្លាប់តែម្តងនៅពេលដែលហៅទៅរៀនសូត្រលើកក្រោយ។ មុនពេលគេហៅឪពុកខ្ញុំ និងតា ខាំភួន ទៅរៀនសូត្រនោះ មានអង្គុលីលេខជាអក្សរលាតធម្មតាមិនមែនសម្ងាត់ពី នួន ជា ផ្ញើមកមន្ទីរក-១៧ ហៅអនុតំបន់ទទួលបន្ទុកខាងអប់រំឈ្មោះតា សូ គឹមអាន ហៅ ម៉ី និងចៅហ្វាយស្រុកម្នាក់ឈ្មោះចាំ ទៅរៀនសូត្រ ហើយបាត់ខ្លួនរហូតដែរ” សូមបញ្ចប់ការដកស្រង់។ តើ

លោកចាំថាលោកបានឆ្លើយបែបនេះដែរឬទេ? ហើយតើលោកដឹងដោយរបៀបណាថា នួន ជា ជាអ្នកផ្ញើលិខិតកោះហៅមកនោះ?

[១៥:១៩:៤២]

**ឆ៖** ចាំបាន។ យូរៗមានម្ដងទេ អាហ្នឹងគាត់មិនបាន -- ភាគច្រើនគឺដាក់៨៧០។ ត្រូវការហៅនេះហ្នឹង ឃើញដាក់ឈ្មោះ ដាក់តែ នួន អត់មានដាក់ នួន ជា ទេ ដាក់ នួន។ បើថាទាក់ទិននឹងរឿងសម្ភារៈប្រើប្រាស់អីៗផ្សេង គេដាក់ ហែម ក្នុងសារទូរលេខតែប៉ុណ្ណឹង។ តែយូរៗម្ដង ភាគច្រើន គឺ ៨៧០។ និយាយជាទូទៅ។

**ស៖** ពាក់ព័ន្ធនឹងការកោះហៅឲ្យ ម៉ី ហើយនិង ចាំ ទៅរៀន តើ នួន នេះជាអ្នកផ្ញើលិខិតកោះហៅមក ឬក៏ ហែម?

**ឆ៖** កាលហ្នឹង នួន។ តែហៅកម្លាំងហៅអី គឺខាង អ៊ំនួន គាត់អ្នកហៅ។

**ស៖** ចុះពាក់ព័ន្ធនឹង តាជួន តើអ្នកណាជាអ្នកកោះហៅគាត់ទៅទីក្រុងភ្នំពេញ?

**ឆ៖** ទៅមួយជំនាន់តែមួយ ទៅជាមួយគ្នាទាំងអស់។

**ស៖** តើលោកចាំទេថា តាជួន, តាម៉ី និងចាំ នោះត្រូវបានគេចាប់ខ្លួននៅពេលដែលលោកនៅតំបន់១០៥ គឺមុនពេលដែលឪពុកលោកស្លាប់?

**ឆ៖** បាទចាំបាន។

**ស៖** សម្រាប់ជាប្រតិចារឹក លោកប្រធានយើងមានឯកសារ E3/165 ដែលក្នុងឯកសារនោះមានឈ្មោះ តាជួន នៅលេខ១២៨ នៃបញ្ជីអ្នកទោស ស-២១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៧។ នៅក្នុងសំណុំរឿងក៏មានចម្លើយសារភាពនៅ ស-២១ របស់ សូ គឹមអាន ហៅអាចារ្យម៉ី ដែលចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៧៧ ដែលមានលេខយោង D175/3.78។ លោកសាក្សី ក្រៅពីកម្មាភិបាលដែលខ្ញុំបានរៀបរាប់ឈ្មោះ ហើយក៏លោកបានរៀបរាប់ឈ្មោះដោយខ្លួនឯងនោះ តើមានការចាប់ខ្លួនច្រើន ហើយបញ្ជូនទៅភ្នំពេញនៅក្នុងកងពល៩២០ នៅតំបន់១០៥ នៅពេលដែលលោកនៅទីនោះដែរឬទេ?

[១៥:២៣:១៥]

**ឆ៖** កាលជំនាន់ ឪពុកខ្ញុំនៅនោះ អត់ទាន់មានចាប់ទ្រង់ទ្រាយធំទេ មានតែក្នុងតំបន់ហ្នឹង មានតែបីរូបហ្នឹងឯង។ មានអ៊ំជួន ហ្នឹងជាប្អូនម្ដាយខ្ញុំបង្កើតក្នុងហ្នឹងដែរ។ ហើយ ពូម៉ី ហើយ ពូចាំ តែបីនាក់

ទេ។ ហើយក្រោយមកខាង៩២០ អាហ្នឹងក្រោយមកទៀត។ សូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ ខ្ញុំនឹងត្រឡប់មកនិយាយអំពីចំណុចនេះឡើងវិញ។ តើចាប់ពីពេលណាដែលលោកធ្វើការបកប្រែទូរលេខនៅតំបន់១០៥? ដូចលោកបាននិយាយពីព្រឹកមិញថា មុនខែមេសា ៧៥ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកថា មុនមេសា ៧៥ ឬក៏ក្រោយខែមេសា ៧៥?

**ឆ៖** មុនមេសា ៧៥។

**ស៖** តើឪពុកលោកទទួលទូរលេខពីមជ្ឈិមមុនឆ្នាំ៧៥ដែរឬទេ? ពេលដែលខ្ញុំនិយាយមជ្ឈិមនេះ ខ្ញុំចង់សំដៅទៅដល់កន្លែងដែលមេដឹកនាំរបបខ្មែរក្រហមរស់នៅ គឺនៅទីក្រុងភ្នំពេញ?

**ឆ៖** មុន៧៥ មានប្រើដែរបាទ។

[១៥:២៥:១០]

**ស៖** តើលោកដឹងទេថា ទូរលេខដែលលោកបកប្រែនុ៎ងគេនិយាយអំពីអ្វីខ្លះជាទូទៅ ខ្ញុំចង់ដឹងថាជាទូទៅតើខ្លឹមសារនុ៎ងយ៉ាងម៉េចខ្លះ?

**ឆ៖** ខ្លឹមសារវាធម្មតាបទបញ្ជា រាយការណ៍សភាពការណ៍ប្រចាំថ្ងៃទេភាគច្រើន អត់មានអីមតិណែនាំអីតិចតួចៗទេ ព្រោះជំនាន់នុ៎ងវានៅសង្គ្រាម ៧៥នៅ។

**ស៖** នៅសម័យនោះ ក្នុងចំណោមសេចក្តីណែនាំនោះ គេមាននិយាយអំពីខ្មាំងដែលត្រូវតែរកឱ្យឃើញទេ?

**ឆ៖** អត់មានទេបាទ តាមសារទូរលេខអត់មានទេ។

**ស៖** តើចាប់ពីពេលណាមកក្រោយឆ្នាំ៧៥មែនទេ ដែលគេចាប់ផ្តើមនិយាយអំពីខ្មាំងនោះ?

**ឆ៖** បាទ ក្រោយ៧៥។

[១៥:២៦:២៨]

**ស៖** ពាក់ព័ន្ធទៅនឹងគុណសម្បត្តិរបស់លោកជាអ្នកបកប្រែទូរលេខ តើនៅពេលណាមួយនោះលោកធ្លាប់ទៅទីក្រុងភ្នំពេញដើម្បីទៅរៀនសូត្របន្ថែមពាក់ព័ន្ធទៅនឹងកូដសម្ងាត់ទូរលេខនៅចន្លោះឆ្នាំ ៧៥ និងចុង៧៧ ដែរឬទេ?

**ឆ៖** អត់មានទេបាទ។

**ស៖** តើលោកអាចពន្យល់ដោយខ្លីជូនអង្គជំនុំជម្រះបានទេថា មានវិធីអ្វីខ្លះដែលត្រូវ -- ដែលទូរលេខត្រូវបានទទួល ហើយបន្ទាប់មកត្រូវបកប្រែនៅតំបន់១០៥នោះ? ថាតើនីតិវិធីនៃការធ្វើនោះ

យ៉ាងម៉េចដែរ នៅពេលដែលទូរលេខមកពីមជ្ឈិមហើយមកដល់តំបន់១០៥នោះ? សូមលោករៀបរាប់ពីជំហានផ្សេងនៅពេលដែលទូរលេខមកពីមជ្ឈិម ហើយមកដល់តំបន់១០៥នោះ។

[១៥:២៧:៣៥]

**ឆ៖** មកពីមជ្ឈិមមក ឬក៏យ៉ាងម៉េចេញពីមជ្ឈិមមក -- គាត់សួរទូរលេខអាម៉េចអត់យល់។ វិធីៗវាយការណ៍ ឬក៏វិធីសរសេរលេខ?

**ប្រធានអង្គជំនុំ៖**

សូមលោកតំណាងសហព្រះរាជអាជ្ញាតាំងសំណួរសាជាថ្មីម្តងទៀត។ សាក្សីមិនយល់សំណួរទេ មិនអាចឆ្លើយបានទេ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**ស៖** ចំពោះសំណួរអម្បាញ់មិញនេះ ខ្ញុំគឺចង់សំដៅទៅដល់នីតិវិធីនៅពេលដែលទូរលេខមកពីមជ្ឈិម ហើយមកដល់តំបន់១០៥ ដែលសម្រាប់ប្រគល់ជូនឪពុករបស់លោកនោះ គឺថាពីដំបូងត្រូវទទួល ហើយបន្ទាប់មកបកប្រែមុននឹងទៅឲ្យឪពុករបស់លោក តើអ៊ីចឹងមែនទេ?

[១៥:២៨:៣៥]

**លោក ផាន វ៉ាន៖**

**ឆ៖** ដំបូងអ្នកខាងវាយអង្គលីលេខ និងទទួលអង្គលីលេខនេះផ្សេង ហើយអ្នកបកសារនេះផ្សេង គឺអត់មានទាក់ទិនគ្នាទេ។ ព្រោះដើម្បីរក្សាការសម្ងាត់ហ្នឹងរវាងអ្នកទទួលទូរលេខ ហើយនិងអ្នកបកសារគេមិនឲ្យជំពាក់ជំពិនគ្នាទេ។ ហើយអ្នកបកសារគេយល់តែវិធីបកសារ។ ហើយដែលលេខកូដសម្ងាត់ដែលត្រូវលាក់ការណ៍ទៀត អាហ្នឹងទាល់តែមេឯណោះបានគេយល់ បានគេដឹង គេមានលេខសម្ងាត់របស់គេមួយជាន់ទៀត។ ឯអ្នកទទួលទូរលេខ គឺថាទូរលេខមក គេទទួលតែលេខទេ គ្នាអត់ដឹងន័យអីទេ។ ខ្ញុំបញ្ជាក់ប៉ុណ្ណឹង។

**ស៖** តើមានប្រភេទផ្សេងៗនៃទូរលេខ ឬអាចនិយាយម្តងទៀតថា តើមាន -- ម្យ៉ាងទៀតថា តើមានទូរលេខដែលអត់មានកូដ ឬក៏មានទូរលេខដែលអត់មានលេខកូន ហើយកូដធម្មតា ឬក៏កូដមានលក្ខណៈស្មុគស្មាញ តើមានច្រើនប្រភេទនៃទូរលេខអ៊ីចឹងទេ?

[១៥:២៩:៥៥]

**ឆ៖** ភាគច្រើនពីរប្រភេទបាទ។ ប្រភេទអា១០ខ្ទង់ហ្នឹង អាហ្នឹងវាអត់ស្មុគស្មាញទេ។ ហើយប្រភេទមួយទៀត១០ខ្ទង់ដែរ ប៉ុន្តែយើងមានលេខៗសារគេមកស្រាប់តែម្តង យកមកផ្ទឹម អាហ្នឹងមេនោះបានគេដឹង មានពីរប្រភេទ អ៊ីចឹង។ អាហ្នឹងស្មុគស្មាញយើងអត់យល់ដឹងដែរ។ ន័យសំខាន់ៗយើងអត់ដឹងទេអាហ្នឹង។

**ស៖** តើលោកផ្ទាល់ហ្នឹងលោកចេះដឹង លេខកូដទាំងអស់ ឬក៏មានលេខកូដណាខ្លះនោះ មានលក្ខណៈស្មុគស្មាញពេក ហើយលោកអត់យល់?

**ឆ៖** ខ្ញុំយល់តែលេខ១០ខ្ទង់ទេ គេធ្វើបង្រៀនតែលេខ១០ខ្ទង់។

[១៥:៣១:០៨]

**ស៖** តើមានកូដណាខ្លះដែលថា លោកមិនអាចយល់បាននោះ? គឺខ្ញុំចង់សំដៅថា ទូរលេខណាខ្លះ ដែលមានលក្ខណៈសម្ងាត់បំផុត ហើយលោកមិនអាចយល់បាន គឺថា ឪពុកលោកធ្លាប់បាននិយាយអំពីទូរលេខប្រភេទនេះប្រាប់លោកទេ?

**ឆ៖** អត់បាននិយាយទេ គ្រាន់តែឃើញលេខ យើងអត់ដឹងទេ យើងឃើញតែលេខ យើងបកចេញមកវាចេញជាលេខ ប៉ុន្តែគេមានអាកូដ អាលេខ ហើយនិងលេខហ្នឹង គេដឹងគ្នាគេ រវាងខាងលើនិងខាងលើ អាលេខ១។ ឧបមាថា អាលេខ១ ហ្នឹងជាស្អី? គេដឹងគ្នាគេអ៊ីចឹង ម៉ូគេផ្សេងទៀត។ នេះឧទាហរណ៍អ៊ីចឹងបាទ។

**ស៖** លោកបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត គឺឯកសារលេខ E3/58 ទំព័រ៤ជាភាសាខ្មែរ ERN 00239937, ជាភាសាបារាំង និងអង់គ្លេសទំព័រ៤។ លោកបានឆ្លើយថា "ចំពោះឯកសារសន្តិសុខនោះ ខ្ញុំផ្ញើទៅ នួន ជា ហៅ នួន ឬក៏បងធំទី២ ក៏ប៉ុន្តែទូរលេខមានលេខកូដត្រូវសរសេរជាអក្សរសម្ងាត់ ដែលខ្ញុំមិនចាំ។ ខ្ញុំមិនអាចដឹងខ្លឹមសារបានទេ គឺមានតែឪពុករបស់ខ្ញុំទេ ទើបអាចដឹងខ្លឹមសារ ព្រោះមានលេខកូដសម្ងាត់ដើម្បីអានមួយជាន់ទៀត" សូមបញ្ចប់ការដកស្រង់។ លោកសាក្សី តើលោកអាចពន្យល់បានទេថា តើលោកធ្វើយ៉ាងម៉េចដើម្បីបញ្ជូនទូរលេខផ្សេងៗ ដែលមានលេខកូដសម្ងាត់មួយជាន់ទៀត ហើយដែលលោកមិនអាចដឹងបាននោះ? សូមលោកពន្យល់ឲ្យច្បាស់ថា យ៉ាងម៉េចបានជាលោកដឹងថា ត្រូវផ្ញើជូន នួន ជា ហើយវាពាក់ព័ន្ធនឹងការងារសន្តិសុខនោះ បើលោកអត់ដឹងពីខ្លឹមសារផងនោះ?

[១៥:៣៣:៣០]

**ឆ៖** អាហ្នឹងសូមៗបញ្ជាក់អ៊ីចេះ អាលេខសម្ងាត់ហ្នឹងវាជាលេខ ដូចថាអក្សរសម្ងាត់ហ្នឹងជាលេខ ដល់ជាលេខយើងអត់ដឹងទេថា ខ្លឹមសារលេខ។ ឧបមាលេខ ១០០, ១០២ អ៊ីចឹង។ ជាន័យស្អីយើងអត់ដឹងទេ វាមានតែលេខទាំងអស់ ប៉ុន្តែចំណងជើងវាដំបូងគេជូនបងទី២ អ៊ីចឹងទៅ ហើយលេខប៉ុណ្ណេះៗ លេខហ្នឹងគាត់ទៅបកខ្លួនឯងទៅ យើងអត់មានបកឲ្យទេអាហ្នឹង។ អាហ្នឹងហៅថា អក្សរសម្ងាត់មួយជាន់ទៀត អាហ្នឹងយើងអត់យល់ទេអាហ្នឹង វាអ៊ីចឹង។ នេះសូមបញ្ជាក់ប៉ុណ្ណឹងបាទ។ តែចំណងជើងវាដូចបញ្ជាក់អំមិញអ៊ីចឹង ឧបមាថា ជូនបងស្អីអ៊ីចឹងទៅ អាហ្នឹងគេអត់លាក់ទេអាហ្នឹង តែន័យហ្នឹងវាចេញជាលេខទាំងអស់។ អាម៉្យាងទៀត ដូចថាអា១០ខ្ទង់ដែលយើងនេះហ្នឹង មតិណែនាំផ្សេងៗនោះ ឬក៏មានរបស់ មានរបរ មានសភាពការណ៍ស្អី វាចេញ យើងបកជាលេខមក វាចេញជាអក្សរៗ ប្រាប់យើងតែម្ដង ឈ្មោះ ក, ឈ្មោះ ខ, ឈ្មោះ គ អ៊ីចឹងទៅវាបកពីលេខមក វាចេញជាអក្សរប្រកបទៅ។ សូមបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណ។ ខ្ញុំនឹងសួរសំណួរបន្ថែមទៀតទៅលើទូរលេខដែលមកពីមជ្ឈិមបក្ស ឬដែលត្រូវបានផ្ញើដោយឪពុករបស់លោកពីតំបន់១០៥។ តើលោកអាចប្រាប់បានទេថានៅតំបន់១០៥ ក្រៅពីឪពុករបស់លោក តើអ្នកណាជាអ្នកមានសិទ្ធិទាក់ទងដោយផ្ទាល់តាមទូរលេខជាមួយនឹងមជ្ឈិមបក្ស? តើមានអ្នកណាម្នាក់នៅតំបន់១០៥ ក្រៅពីឪពុករបស់លោកដែលអាចទាក់ទងដោយផ្ទាល់ជាមួយមជ្ឈិមបក្សដោយទូរលេខដែរឬទេ?

[១៥:៣៥:៣១]

**ឆ៖** ជំនាន់ហ្នឹងនៅតំបន់ អត់មានទេបាទ។ បើកងពល ខាងកងពល៩២០ គេមានរបស់គេផ្សេង។ នៅតំបន់អត់មានទេ មានតែទូរលេខមានតែមួយហ្នឹងឯង។ ហ្នឹងសូមបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណ។ កងពល៩២០ មានមន្ទីរទូរលេខផងដែរ។ ដូច្នេះតើមានការផ្ញើទូរលេខទៅវិញទៅមកគ្នារវាងតំបន់១០៥ ហើយនិងទីបញ្ជាការកងពល៩២០ ដែរឬទេ?

**ឆ៖** រវាង១០៥ ហើយនិង៩២០ អត់មានទេតាមទូរលេខបាទ។

**ស៖** អម្បាញ់មិញនេះ លោកនិយាយអំពីមន្ទីរ៨៧០ របស់មជ្ឈិមបក្ស។ តើលោកដឹងទេថាមន្ទីរ ៨៧០ នេះមានមុខងារអ្វីខ្លះ?

**ឆ៖** អត់បានដឹងទេបាទ។

[១៥:៣៧:០៥]

**សៈ** ប្រសិនបើលោកមិនដឹងអំពីមុខងារទេ តើលោកដឹងទេថាកម្មាភិបាល ឬក៏មេដឹកនាំណាធ្វើការនៅមន្ទីរ៨៧០ នោះ? បានន័យថានៅពេលដែលផ្ញើសារទៅ៨៧០ តើអ្នកណានៅមន្ទីរ៨៧០ហ្នឹង ជាអ្នកទទួលសារដែលផ្ញើពីលោកទៅនោះ?

**ឆះ** ជំនាន់ហ្នឹងដឹងតែអ៊ំៗហ្នឹងហើយ។

**សៈ** នៅពេលដែលលោកដែលនិយាយអំពី អ៊ំៗ តើលោកចង់មានន័យថាយ៉ាងម៉េចអ៊ំៗហ្នឹងអ្នកណាខ្លះដែលយើងហៅថា “អ៊ំ”ៗ ហ្នឹង?

**ឆះ** ជំនាន់កម្ពុជាប្រជាធិបតេយ្យជំនាន់តែប៉ុន្មាននាក់ហ្នឹង អ៊ំៗ អ៊ំ នួន ជា, អ៊ំ ប៉ុល ពត, អ៊ំ ខៀវ សំផន ហ្នឹងខាងខ្ញុំហៅអ៊ំៗទាំងអស់។ ហ្នឹងបញ្ជាក់ប៉ុណ្ណឹងបាទ។

**សៈ** សូមអរគុណ។ តើតំបន់១០៥ ធ្លាប់ទទួលទូរលេខពី ប៉ុល ពត ផ្ទាល់ដែរឬទេ? ឬក៏តើតំបន់១០៥ ធ្លាប់ផ្ញើជូន -- ផ្ញើទូរលេខជូន ប៉ុល ពត ដោយមិនដាក់ពាក្យថា “មន្ទីរ៨៧០” ទេ គឺថាផ្ញើដាក់ឈ្មោះថា “ប៉ុល ពត” តែម្តង? ធ្លាប់មានអ៊ីចឹងទេ?

[១៥:៣៨:៤៦]

**ឆះ** អត់មានទេបាទ អត់មានដាក់ឈ្មោះអ៊ីចឹងមក អត់មាន។

**សៈ** អម្បាញ់មិញនេះលោកឆ្លើយថា នួន ជា ជាអ្នកផ្ញើលិខិតកោះហៅឲ្យចូលប្រជុំទៅកម្មាភិបាលតំបន់១០៥ ខ្ញុំបានអានសម្រង់ដែលលោកឆ្លើយថា “សារសម្ងាត់ពាក់ព័ន្ធនឹងសន្តិសុខ គឺផ្ញើទៅឲ្យ នួន ជា”។ សំណួររបស់ខ្ញុំនោះចង់ដឹងថា តើគេចាត់តាំង នួន ជា យ៉ាងម៉េចពាក់ព័ន្ធទៅនឹង -- សូមទោស តើលោកហៅ នួន ជា យ៉ាងម៉េចនៅក្នុងទូរលេខដែលផ្ញើទៅគាត់នោះ?

**ឆះ** តាមសារ? ហ្នឹងខ្មោចឪពុកខ្ញុំគាត់ហៅ“បង”។ ខ្ញុំៗមិនមែនខ្ញុំអ្នកហៅទេបាទសូមបញ្ជាក់។

[១៥:៤០:២១]

**សៈ** សូមអរគុណ។ តើ នួន ជា ផ្ញើទូរលេខទៅឲ្យតំបន់១០៥ ពាក់ព័ន្ធនឹងបញ្ហាសន្តិសុខដែរឬទេ?

**ឆះ** ខ្ញុំអត់ចាំដែរបាទ។

**សៈ** លោកប្រធានខ្ញុំសុំការអនុញ្ញាតអាននូវកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ដែលមានលេខ E3/58 ជាភាសាខ្មែរទំព័រ៤ ERN 00239937, ជាភាសាបារាំង ទំព័រ៤, ជាភាសាអង់គ្លេសក៏ទំព័រ៤ដែរ គឺសម្រង់នេះ គឺតពីអ្វីដែលខ្ញុំបានអានអម្បាញ់មិញពាក់ព័ន្ធទៅនឹងការងារសន្តិសុខដែលលោក

E1/151.1

ត្រូវផ្ញើទូរលេខជូន នួន ជា ហើយមានលេខកូដសម្ងាត់នៅពេលដែលផ្ញើចេញទៅនោះ។ ខ្ញុំសូមអាននូវសម្រង់មួយផ្សេងទៀត។ ខ្ញុំសូមដកស្រង់ "មុនពេលឪពុកខ្ញុំស្លាប់ នួន ជា តែងតែផ្តល់សេចក្តីណែនាំពាក់ព័ន្ធទៅនឹងបញ្ហាសន្តិសុខ ពាក់ព័ន្ធទៅនឹងការប្រុងប្រយ័ត្ន ខ្លាចមានខ្មាំងវៀតណាម ឬមានខ្មាំងបង្កប់អំពីមហិច្ឆតារបស់វៀតណាម ការងារសតិអារម្មណ៍ ដែលត្រូវណែនាំបន្តទៅដល់ថ្នាក់ស្រុក"។ ហើយបន្ទាប់មកទៀត មានការនិយាយអំពីលិខិតកោះហៅដែលផ្ញើជូនកម្មាភិបាលមួយចំនួនដែលត្រូវចូលរួមនៅទីក្រុងភ្នំពេញ។ ហើយយើងបានអានរួចមកហើយ ហើយកម្មាភិបាលទាំងអស់នោះមិនត្រឡប់មកវិញទេ។ ដូច្នេះតើលោកចាំទេថា នួន ជា បានណែនាំមកជាប្រចាំ អំពីការងារសន្តិសុខ ហើយនិងណែនាំឲ្យមានការប្រយ័ត្នប្រយែងខ្លាចមានខ្មាំងនៅក្នុងទូរលេខ ដែលផ្ញើជូនតំបន់១០៥ នោះ។

**ឆ៖** អាហ្នឹងចាំបាន ហ្នឹងមតិណែនាំជាធម្មតា ដូចការរំឮកអ៊ីចឹង អាហ្នឹងគេប្រើសារហ្នឹងដូចរំឭក។ សូមបញ្ជាក់ប៉ុណ្ណឹង អាហ្នឹងមានបាទ។

[១៥:៤២:៥៥]

**ស៖** តើលោកអាចបញ្ជាក់បាទថាតើការណែនាំហ្នឹងផ្ញើតាមទូរលេខ ឬក៏មានការណែនាំដែលបានប្រាប់ផ្ទាល់តែម្តងនៅក្នុងពេលប្រជុំ? តើមានការណែនាំតាមទូរលេខ ឬក៏មានការទទួលការណែនាំដោយផ្ទាល់តែម្តងនៅពេលដែលឪពុកលោកទៅទីក្រុងភ្នំពេញ ទៅចូលរួមប្រជុំនោះ?

**ឆ៖** ទៅទទួលតែម្តង ក៏ខ្ញុំមិនបានដឹងដែរ។ ប៉ុន្តែតាមទូរលេខមានការណែនាំឲ្យប្រុងប្រយ័ត្នអីៗអ៊ីចឹង អាហ្នឹងវាជាធម្មតា។ ដូចថាក្នុងកាលនោះសភាពការណ៍សង្គ្រាមវាតឹងតែង គេណែនាំពីរឿងសន្តិសុខនោះឯងបាទ។

**ស៖** សូមអរគុណ។ នៅពេលដែលលោកនិយាយអំពីការប្រយ័ត្នប្រយែងខ្លាចមានខ្មាំង តើលោកចង់និយាយអំពីអ្វី? លោកចង់មានន័យថាម៉េច ពាក្យថាប្រយ័ត្នប្រយែងនេះនៅក្នុងរបបខ្មែរក្រហមនេះតើពាក្យថាប្រយ័ត្នប្រយែងហ្នឹងមានន័យថាដូចម្តេចដែរ?

[១៥:៤៤:២២]

**ឆ៖** ជំនាន់ អាខ្មាំងវៃគ្នាតាមព្រំដែនក៏វៃ អាខ្មាំងអត់ជឿទុកចិត្តគេគ្នាហ្នឹងក៏វាច្រើនណាស់ដែរកាលពីជំនាន់នោះ។ ដូច្នេះន័យវាទាំងពីរ គេអ្នកណែនាំ។ បើនិយាយទៅវាវែងឆ្ងាយបាទ។ ពន្យល់គ្នាអារឿងខ្មាំងហ្នឹង វាច្រើនណាស់ជំនាន់ហ្នឹង។ សូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ ដោយសង្ខេប នៅពេលដែលយើងនិយាយពីខ្មាំងបង្កប់ នៅក្នុងបរិបទ

នេះ តើខ្មាំងបង្កប់នេះសំដៅលើអ្វីដែរ?

**ធ៖** អាហ្នឹងតាមការយល់របស់ខ្ញុំផ្ទាល់ទេអាហ្នឹង ដែលគាត់កំណត់ថាខ្មាំងបង្កប់ហ្នឹង ដឹង-- ប៉ុន្តែទស្សនៈខុស យល់ខុស ពីមាគ៌ារបស់គេកំណត់ហ្នឹង អាហ្នឹងគេថាខ្មាំងបាត់ហើយ ជំនាន់ហ្នឹង។ អ៊ីចឹងដក ទី១ ដកសេចក្តីទុកចិត្តលែងឲ្យធ្វើអី។ អាហ្នឹងឧទាហរណ៍ទី១។ ទី២ ប្រហែសនោះយកទៅដាក់គុកទៀត។ អាហ្នឹងគ្រាន់តែទស្សនៈទេ ការយល់ឃើញខុសគ្នា។ សូមបញ្ជាក់តែប៉ុណ្ណឹង។ អាហ្នឹងក៏ខ្មាំងដែរ។ ហ្នឹងអត់និយាយពីរឿងខ្មាំងបាញ់ យួនមករៀបព្រំដែនអី អាហ្នឹងអត់គិតទេអាហ្នឹង។ អាហ្នឹងវាខ្មាំងទៅហើយ។ វាហៅថា ខ្មាំងគ្នាឯង វាអ៊ីចឹង។ សូមបញ្ជាក់។

[១៥:៤៦:០៤]

**ស៖** តើកម្មាភិបាលនៅតំបន់១០៥មួយចំនួននោះ ត្រូវបានគេចោទថា ជាគិញ ឬក៏ជាជនក្បត់របស់បក្សដែរឬទេ?

**ធ៖** កាលហ្នឹងវា ដល់ពេលបាត់ខ្លួន ដល់ពេលមកប្រកាសថា អ្នកនេះ អ្នកនោះក្បត់ហ្នឹង គេថាក្បត់ជាតិអ៊ីចឹងម្តង។ ត្រូវជាខ្មែរ ខ្លះគេថាខ្មែរ សេ.អ៊ី.អា អ៊ីចឹងទៅ។ ដូចពូម៉ី ដូចតាជួន អីៗហ្នឹង គេខ្មែរ សេ.អ៊ី.អា អ៊ីចឹងទៅ។ ដូចពួក តាចាំ នេះគេថាខ្មែរយួនផង សេ.អ៊ី.អា អ៊ីចឹង។ នេះស្រេចតែគេថាអ៊ីចឹង។ ឮតែគេថា ដូចតែគ្នាហ្នឹងបាទ ចង់បញ្ជាក់អ៊ីចឹង។

**ស៖** សូមអរគុណដែលបានបំភ្លឺ។ តើតំបន់១០៥នេះ ធ្លាប់បានទទួលទូរលេខពី៨៧០ ពីមនុស្សម្នាក់ឈ្មោះ ឌឿន –ឌ-ឿ-ន–?

**ធ៖** ដូចអត់មានទេ ដូចអត់ចាំ។ ដូចមិនមានទេបាទ។

**ស៖** តើតំបន់១០៥ហ្នឹង ធ្លាប់បានទទួលទូរលេខពីលោក ខៀវ សំផន ដោយផ្ទាល់ដែរឬទេ?

**ធ៖** ខ្ញុំដូចអត់ច្បាស់ទេបាទ។

[១៥:៤៨:១០]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងឈលៈ**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតអានសម្រង់មួយនៃកំណត់ហេតុស្តាប់ចម្លើយដែរ គឺថាឯកសារ E3/58 នៅទំព័រទី៤ ជាភាសាខ្មែរ គឺទំព័រទី៤ដដែល ERN គឺ00239937, ជាភាសាបារាំង គឺទំព័រទី៤ ហើយភាសាអង់គ្លេសក៏ទំព័រទី៤ដែរ។ សាក្សីនិយាយដូចតទៅនេះ នៅពេលដែលគាត់ឆ្លើយទៅនឹងសំណួរសហចៅក្រមស៊ើបអង្កេត។ ខ្ញុំសូមដកស្រង់ "ប្រសិនបើការងារសម្ភារៈ សុខាភិបាល ឬក៏សង្គម

កិច្ច និងការងារក្រៅពីសន្តិសុខ គឺត្រូវវាយអក្សរលាត មិនមែនសម្ងាត់ផ្ញើទៅ ខៀវ សំផន ហៅ ហែម។ ហើយនៅពេលដែលគាត់ណែនាំចាត់ចែងត្រឡប់មកវិញ គឺគាត់ចុះហត្ថលេខា ហើយដាក់ឈ្មោះថា ហែម នេះដែរ។ ឧទាហរណ៍នៅពេលដែលគាត់ចាត់ចែងមកតំបន់ ខាងតំបន់ គឺថា ក-១៧ ត្រូវចាត់ចែងទៅខាងពាណិជ្ជកម្ម ឬសេដ្ឋកិច្ចឲ្យទៅយកសម្ភារៈនៅមជ្ឈិម ដូចជាប្រេង និងគ្រឿងចក្រ ថ្នាំពេទ្យក្រណាត់។ ចំណែកខាងមជ្ឈិមវិញ ក៏មានស្នើមកពីខាងតំបន់ទៅវិញ ដូចជាស្រូវជាដើម"។ សូមបញ្ចប់ការដកស្រង់។

**ស៖** អម្បាញ់មិញនេះ លោកក៏បានលើកឡើងដែរថា ហែម ក៏ជាអ្នកដែលទទួល ឬក៏ផ្ញើទូរលេខ តើលោកនៅធ្វើការបញ្ជាក់ការបែងចែកដែរឬទេ គឺថានៅពេលទាក់ទងនឹងសន្តិសុខ គឺ នួន ជា ជាអ្នកផ្ញើទូរលេខ ហើយនៅពេលដែលពាក់ព័ន្ធនឹងផ្នែកផ្សេងទៀតនោះ បញ្ហាផ្សេងទៀតនោះ គឺ ខៀវ សំផន ឧទាហរណ៍ជាផ្នែកសម្ភារៈជាដើមនេះ?

**លោក ផាន វ៉ាន៖**

**ផ៖** បាទ ដូចបានបញ្ជាក់ហ្នឹងហើយ ខាងសម្ភារៈហ្នឹងគឺ ជួនកាលគាត់ដាក់ឈ្មោះ ហែម អ៊ីចឹងមែនបាទ។

**ស៖** សូមអរគុណ។ ទាក់ទងនឹងសម្រង់នេះ តើតំបន់១០៥នេះ ផ្ញើស្រូវទៅមជ្ឈិមជាញឹកញាប់ដែរឬទេ?

**ផ៖** ខ្ញុំអត់ចាំដែរ ដូច១ឆ្នាំ ដូចផ្ញើបានតែពីរដងអីទេ តាមខ្ញុំចាំ។ សូមបញ្ជាក់បណ្ដឹង។

**ស៖** តើនៅក្នុងតំបន់១០៥នោះ ធ្លាប់មានបញ្ហាកង្វះអាហារ ឬក៏ទុរ្ភិក្សនៅក្នុង -- នៅតាមសហករណ៍នៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៧ ដែរឬទេ?

[១៥:៥១:៤៩]

**ផ៖** ខ្ញុំដែរ តែមិនខ្វះខ្លាំងដូចតំបន់ផ្សេងៗទៀត នៅមណ្ឌលគិរីជំនាន់ហ្នឹង។

**ស៖** ក៏ប៉ុន្តែទន្ទឹមនឹងនោះ គឺថាគេនៅតែបន្តផ្ញើស្រូវទៅភ្នំពេញ១ឆ្នាំ ពីរដងអ៊ីចឹងមែនទេ?

**ផ៖** បាទ។

**ស៖** បាទ ឥឡូវនេះ ខ្ញុំសូមបង្ហាញទូរលេខមួយចំនួនទៅលោកសាក្សី ដោយហេតុថាគាត់ធ្វើការក្នុងការបកប្រែ ឬក៏បំភ័ន្តអក្ខរៈសម្រាប់ឪពុកគាត់។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារ និងបញ្ចាំងនៅលើអេក្រង់នូវឯកសារ E3/1191 គឺ E3/1191។ ខ្ញុំសូមចាប់ផ្ដើមបញ្ចាំងឯកសារនេះមុនគេលោកប្រធាន។

[១៥:៥៣:០៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ ទូរលេខដែលខ្ញុំបង្ហាញនេះខ្លីៗទេ គឺថាប្រហែលមួយទំព័រ។ គឺថាតេឡេក្រាម E3/1196 ចុះថ្ងៃទី១២ តុលា ឆ្នាំ១៩៧៦ ផ្ញើដោយ ឡេង ជូនទៅដល់សមមិត្ត ខឿន ជាទីស្នេហា និងនឹករឭក។ ហើយទូរលេខនេះមានលេខ០០ ផ្ញើចេញពីតំបន់១០៥។ សូមដកស្រង់ "យើងទៅដល់១០៥ នៅពេលរសៀល ហើយខ្ញុំបានប្ដូរឈ្មោះខ្ញុំ ឥឡូវនេះ ចាប់ពីពេលនេះទៅខ្ញុំឈ្មោះៗ ចាន់ អ៎! ផាន បាទ សូមប្រើតាមឈ្មោះហៅថា សមមិត្តផាន ជាកំណត់...។ល។" លោកសាក្សី នេះគឺជាទូរលេខដែលត្រូវបានទទួលដោយមជ្ឈិម ហើយនិងបកប្រែនៅមជ្ឈិម តើអ្នកផ្ញើទូរលេខនេះ ដែលឈ្មោះ ឡាំង នេះជាឪពុកលោកមែនដែរឬទេ?

**លោក ផាន វ៉ាន៖**

**ផ៖** ឈ្មោះ បើថានៅមណ្ឌលគិរី មានតែឈ្មោះ ឡាំង មានតែឪពុកខ្ញុំម្នាក់គត់បាទ។ ប៉ុន្តែសារទូរលេខខ្ញុំមិនដែលបានឃើញទេ អាហ្នឹងបាទ។ ហើយការផ្លាស់ឈ្មោះនោះ ក៏ខ្ញុំអត់ចាំដែរ។

**ស៖** បើសិនជាលោកមិនបានធ្លាប់ឃើញទូរលេខនេះទេ តើចំណារផ្សេងៗនៅខាងក្រោមនេះវាដូចនឹងទូរលេខដែលលោកធ្លាប់បានបកប្រែដែរឬទេ? ឧទាហរណ៍ដូចជាខាងលើនេះ មានគេដាក់លេខដែរលេខ០០ ហើយបន្ទាប់មកទៀតហ្នឹង គឺថាអ្នកដែលគេផ្ញើទូរលេខហ្នឹងទៅ ហើយបន្ទាប់មកគឺថាតួសេចក្ដី តួសារទូរលេខហ្នឹង គឺថា ជូនពរសុខភាពល្អ និងជោគជ័យ ហើយមានកាលបរិច្ឆេទ ហើយនិងមានហត្ថលេខា ហើយក្នុងឧទាហរណ៍ក្នុងតេឡេក្រាមនេះ គឺថាឪពុកលោកតែម្ដង។ តើលោកធ្លាប់ឃើញទ្រង់ទ្រាយដូចនេះទេ ចំពោះទូរលេខដែលលោកធ្លាប់ផ្ញើចេញពីតំបន់១០៥នេះ?

[១៥:៥៦:១៩]

**ផ៖** សូមបញ្ជាក់ថ្ងៃខែ ហ្នឹងអាចបងខ្ញុំគាត់ដឹង ព្រោះ៧៦នេះវា បងខ្ញុំគាត់អ្នកធ្វើការភាគច្រើន

ព្រោះខ្ញុំជាប់តែបើកឡានបាទ។ ចង់យ៉ាងណាទៅបញ្ជាក់ជាមួយបងស្រីខ្ញុំទៅ គាត់ច្បាស់អាចលើកក្រោយបាទ។

**ស៖** បាទសូមអរគុណ។ ហើយបងប្រុសលោកហ្នឹង ឈ្មោះអ្វីដែរ?

**ឆ៖** មិនមែនបងប្រុសទេ បងស្រីបាទ។ បងស្រីឈ្មោះ ហាន ហ្នឹងបាទ។

**ស៖** បាទសូមអរគុណ។ នៅក្នុងទូរលេខនេះ ឡាំង ដែលជាឪពុកលោកនោះចាប់ពីពេលហ្នឹងទៅ គាត់ត្រូវ -- គេត្រូវហៅគាត់ថា ផាន ហើយគាត់និយាយទៀតថា ចាប់ពីពេលនេះទៅត្រូវប្រើឈ្មោះហ្នឹងដើម្បីហៅគាត់ ទាក់ទងជាមួយគាត់។ តើលោកធ្លាប់ឮឈ្មោះ ឆាន ហ្នឹងទេ ដែលឈ្មោះ ឆាន ដែលមាននៅក្នុងទូរលេខហ្នឹង?

**ឆ៖** ឆាន ឬ ផាន បាទ? ឈ្មោះ ផាន បាទ។

**ស៖** ជាភាសាអង់គ្លេស គឺសរសេរថា ឆាន ហើយជាបារាំង ជាបារាំងនោះជួនកាល ប៉ាន ហើយម្តងទៀតនោះ ឈ្មោះ ឆាន។ ខ្ញុំមិនដឹងថា មានបញ្ហាបកប្រែជាសរសេរ ឬយ៉ាងម៉េចទេ ក៏ប៉ុន្តែសរសេរជាខ្មែរហ្នឹង ឃើញដូចគ្នារហូតទេ សរសេរដូចគ្នាទេ។ អ៊ីចឹង ខ្ញុំសូមឲ្យអានកថាខណ្ឌទី២ ដែលមានឈ្មោះហ្នឹងសរសេរ។ អ៊ីចឹងត្រូវយកឈ្មោះហ្នឹងតែម្តងទៅ។ អ៊ីចឹងឈ្មោះ ឆាន ហ្នឹងពិតជាឈ្មោះឪពុករបស់លោកមែនទេ?

**ឆ៖** ឈ្មោះ ផាន ហ្នឹង ឈ្មោះត្រកូលៗដែលហៅ ឪពុកខ្ញុំហ្នឹង គេហៅ ផាន ដែរ ជីតាខ្ញុំនោះ។ សូមបញ្ជាក់ប៉ុណ្ណឹងបាទ។ តែឪពុកដាក់ ឆាន ដូចអត់ៗមានទេ តែចង់ច្បាស់ ដូចថា ចាំសួរបងខ្ញុំសិនពីព្រោះសារទូរលេខអា៧៦ ហ្នឹងគាត់អ្នកនៅជាប់។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹងបាទ។

[១៥:៥៩:១៧]

**ស៖** បាទ សូមអរគុណ។ បាទ ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារមួយទៀត ដែលជាទូរលេខមានលេខ E3/112 -- 1192 (សូមទោស) ដែលកាលបរិច្ឆេទ ដូចគ្នាគឺថា ថ្ងៃទី១២ តុលា ១៩៧៦ គឺថាមានតែមួយទំព័រទេ ហើយដែល "ផ្ញើដោយ ឡាំង ទៅបង នួន ជាទីស្នេហា"។ យើងដឹងហើយថា សាក្សីនេះមិនដែលបានឃើញឯកសារនេះទេ ព្រោះថាចុះថ្ងៃដូចគ្នា ក៏ប៉ុន្តែទោះជាយ៉ាណាក្តីមានសំណួរមួយចំនួនដែលយើងអាចចោទសួរទៅគាត់បាន ដោយសារគាត់ធ្លាប់ធ្វើការផ្នែកទូរលេខនេះ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

បាទ លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនេះទៅលើអេក្រង់ ហើយទៅដល់សាក្សី

ហើយនិងសូមអនុញ្ញាតចោទសំណួរមួយចំនួនទៅដល់សាក្សីនេះផងដែរលោកប្រធាន។

[១៦:០១:០០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។

**ស៖** នេះគឺជាទូរលេខ លោកសាក្សីគឺនេះគឺជាទូរលេខដែលផ្ញើដោយ ឡាំង តើនេះឈ្មោះ ឡាំង នេះជាឪពុកលោកដែរឬទេ គាត់ចុះហត្ថលេខាលើទូរលេខនេះ?

**លោក ផាន វ៉ាន៖**

**ផ៖** បាទ។

**ស៖** ហើយ "ផ្ញើជូនទៅបងនួន ជាទីស្នេហា និងនឹករឭក"។ អម្បាញ់មិញនេះលោកនិយាយថា "នួន នេះគឺ នួន ជា"។ ឥឡូវលោកបញ្ជាក់បានទេថា នួន នេះ ពិតជា នួន ជា នៅក្នុងទូរលេខយើងនេះ?

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប មានការតវ៉ាពីលោកមេធាវី នួន ជា។ សូមអញ្ជើញលោកមេធាវី!

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាប្រហែលជាសំណួរទី១ ថាតើសាក្សីស្គាល់ឯកសារហ្នឹងដែរឬអត់? បើសិនជាគាត់ថាអត់ទេ ប៉ុន្តែនៅក្នុងនេះឃើញថា ការបកប្រែ គឺមិនឃើញថាសាក្សីឆ្លើយបែបនោះទេ។ ហើយតាមពិតយើង -- គាត់ស្គាល់ឈ្មោះឪពុកគាត់គឺជាការពិត គឺត្រូវតែស្គាល់។

ប៉ុន្តែថាតើគាត់ស្គាល់ឯកសារនេះពីមុន ឬពីមុន? នោះគឺថាជាបញ្ហាដែលត្រូវចោទនោះបាទ។

[១៦:០៣:០៧]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធានអម្បាញ់មិញនេះ ខ្ញុំហាក់ដូចជាពន្យល់ពីមូលហេតុហើយៗ គឺថាដោយចុះថ្ងៃដូចគ្នាទូរលេខនេះ គឺដូចទូរលេខមុនដែរ គឺអ៊ីចឹងគឺបងស្រីគាត់ជាអ្នកបំភ័ន្តអក្ខរៈទូរលេខនេះ។ ខ្ញុំដឹងហើយថា

សាក្សីនេះមិនបានឃើញទូរលេខនេះទេ ក៏ប៉ុន្តែខ្ញុំចង់ដឹងថាតើសាក្សីនេះអាចបញ្ជាក់អំពីរបៀបដែលគាត់និយាយទៅកាន់ នួន ជា។ ឧទាហរណ៍ដូចជាការប្រើពាក្យថា "ជូនបង នួន ជា ជាទីស្នេហានឹករឭក" ជាដើមនេះ។

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

បាទ អ៊ីចឹងតើគឺថាយើងក៏អាចដឹងដែរថា កូនក្ដីរបស់ខ្ញុំ នួន ជា។ ហើយយើងក៏ដឹងដែរថា សាក្សីគាត់ដឹងឪពុកគាត់ឈ្មោះអី។ ដូច្នេះ ប៉ុន្តែនៅក្នុងឯកសារនេះ -- ហើយមិនបានសួរទៅសាក្សីថា តើគាត់ស្គាល់ បានឃើញឯកសារនោះដែរឬទេ? ដូច្នេះគឺសហព្រះរាជអាជ្ញា គឺសួរសំណួរបែបនុំងផ្សេងទៅទាំងស្រុង។ ដូច្នេះហើយ ហើយដោយសារពេលនីមួយៗ បើសិនជាក្រៅពីវិសាលភាពនៃសាក្សី ជាពិសេសនៅពេលនោះ តើខ្ញុំមិនឃើញថាមានសារៈសំខាន់អីដែលត្រូវសួរសាក្សីឲ្យបញ្ជាក់នោះទេ។

[១៦:០៤:៣២]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំសួរសំណួរនេះទៅសាក្សី ប៉ុន្តែលោកប្រធាន ខ្ញុំដឹងថាអ្នកណាក៏ដឹងចម្លើយដែរ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ឥឡូវលោកសាក្សី លោកធ្លាប់ឃើញទូរលេខនេះទេ?

**លោក ផាន វ៉ាន៖**

**ឆ៖** ទូរលេខនេះអត់ឃើញទេ ប៉ុន្តែទម្រង់ៗ គឺត្រឹមត្រូវបាទ។ ទម្រង់ របៀបសរសេរ គឺត្រឹមត្រូវប៉ុន្តែចុងឆ្នាំ៧៦ហ្នឹង បងខ្ញុំគាត់អ្នកជាប់ធ្វើ ព្រោះខ្ញុំជាប់ទៅបើកឡានជំនាន់ហ្នឹង។ បងខ្ញុំគាត់មកជួយការងារខាងហ្នឹង។

**ស៖** សូមអរគុណ។ នៅពេលដែលលោកទទួលបន្ទុកខាងបំភ័ន្តអក្ខរៈទូរលេខនេះ លោកនិយាយថាបងស្រីរបស់លោក ធ្វើការជាមួយឪពុករបស់លោកក្នុងរយៈពេលខ្លី ផ្នែកទូរលេខនេះ។ តើនៅពេលដែលលោកធ្វើការផ្នែកហ្នឹងដែរនេះ តើលោកនៅចាំពីរបៀបដែលគាត់ហៅ នួន ជា ដែរឬទេ ពេលដែលគាត់សរសេរទូរលេខទៅ នួន ជា គាត់ហៅ នួន ជា យ៉ាងម៉េចដែរ?

**ឆ៖** ហៅដូចក្នុងសារដែលឃើញទម្រង់ហ្នឹងបាទ គាត់ហៅ "បង"។

**ស៖** សូមអរគុណ។ នៅចំណុចទី២នៃទូរលេខនេះ គឺថាមានសរសេរដូចតទៅនេះ "យើងខ្ញុំបានចាត់តាំងក្រុមពាណិជ្ជមួយក្រុមប្រចាំភ្នំពេញ។ សមមិត្តជួន ទទួល"។ តើ ជួន នេះគឺជា ជួន ដែលយើង

បាននិយាយពីមុនហ្នឹង គឺថាដែលជាសមាជិកគណៈពាណិជ្ជកម្មនៅតំបន់១០៥ហ្នឹង តើ ជួន ហ្នឹងមែនទេ?

**ឆ៖** បាទ ជួន ហ្នឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែកនៅថ្ងៃពុធ ទី១២ ខែធ្នូ ឆ្នាំ២០១២ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។

សវនាការនៅថ្ងៃពុធ ថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មសាក្សី ផាន វ៉ាន ហៅ ខាំ ផាន់ ហើយនិងធ្វើសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងបណ្ដឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-1 តាមមធ្យោបាយសោតទស្សន៍។ សូម ហើយនិងផ្ដើមការសួរដេញដោលដោយក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមុនភាគីដទៃទៀតនៃរឿងក្ដី។ សូមភាគីនិងសាធារណជនជ្រាប។

[១៦:០៧:២៧]

លោក ផាន វ៉ាន ការស្ដាប់សក្ខីកម្មរបស់លោក នៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះនឹងបន្តធ្វើដំណើរការស្ដាប់សក្ខីកម្មរបស់លោកនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះកោះអញ្ជើញលោកមកផ្ដល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកទៀត ថ្ងៃពុធ ទី១២ ខែធ្នូ ឆ្នាំ២០១២។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញ។ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញនៅព្រឹកថ្ងៃស្អែក ឲ្យបាន នៅវេលាម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងឲ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាល បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំ។ ដោយឡែកលោក អៀង សារី ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានពីចម្ងាយ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៦ នាទី)*